**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជតក

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 28-Oct-21, 13:56
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# សំណើសុំដីកាបង្គាប់បន្ទាន់ ដើម្បីការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើជាតំណាង ដោយប្រសិទ្ធភាព និងជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌

---

ដាក់ដោយ៖

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Megan HIRST

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

Laure DESFORGES
Isabelle DURAND
Emmanuel ALTIT
Martine JACQUIN
Daniel LOSQ
Christine MARTINEAU

នៅចំពោះមុខ៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele MWACHANDE- MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

| | | |
|---|---|---|
| ឡោ ជុនធី | Lyma NGUYEN | ចៅក្រម Maureen HARDING CLARK |
| ម៉ុច សុវណ្ណារី | Mahesh RAI | ចៅក្រម យ៉ា ណារិន |
| ស៊ិន សុវ៉ន | Nushin SARKARATI | **ផ្ញើជូន៖** |
| សំ សុគង់ | | **ការិយាល័យសហព្រះរាជអាជ្ញា** |
| វ៉ែន ពៅ | | ជា លាង |
| ទី ស្រ៊ីនណា | | Brenda J. HOLLIS |
| | | **ជនជាប់ចោទ៖** |
| | | ខៀវ សំផន |
| | | **សហមេធាវីការពារក្តី៖** |
| | | គង់ សំអុន |
| | | Anta GUISSÉ |

## ១. សេចក្តីផ្តើម

1. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (“សហមេធាវីនាំមុខ”) ស្នើសុំបន្ទាន់ឱ្យអង្គជំនុំជម្រះតុលាការកំពូល (“អង្គជំនុំជម្រះ”) សម្រេចទៅលើសិទ្ធិចម្បងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើជាតំណាងដោយប្រសិទ្ធភាព និងជំនុំជំម្រះក្តីដោយយុត្តិធម៌ ដោយបង្គាប់ឱ្យការិយាល័យរដ្ឋបាល (“OA”) ដើម្បី (i) ទទួលស្គាល់នូវអាណត្តិរបស់សហមេធាវីនាំមុខ អនុលោមតាមវិធាន ១២*ស្ទួនពីរ* និង (ii) ធានាអំពីធនធានសម្រាប់ការអនុវត្តការងារគ្រប់យ៉ាងស្ថិតក្នុងអាណត្តិរបស់ខ្លួន ចំពោះពេលវេលាដែលនៅសេសសល់នៃសំណុំរឿង ០០២។

2. សហមេធាវីនាំមុខកត់សម្គាល់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលបានសម្រេចនៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០២១ ដែលបានបញ្ជាក់ថា អង្គជំនុំជម្រះមិនមានយុត្តាធិការទៅលើសេចក្តីសម្រេចរដ្ឋបាលនៅក្នុងដែននៃសិទ្ធិអំណាចរបស់ការិយាល័យរដ្ឋបាលឡើយ[1] ។ ក៏ប៉ុន្តែ បញ្ហាដែលបានលើកឡើងនៅក្នុងសំណើនេះ មិនមានចារិតលក្ខណៈជារដ្ឋបាលនោះទេ។ វាពាក់ព័ន្ធទៅនឹងសិទ្ធិជាសំខាន់របស់ដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធានផ្ទៃក្នុង។ ការការពារសិទ្ធិទាំងនោះ និងការជំនុំជំម្រះក្តីដោយភាពយុត្តិធម៌ក្នុងអំឡុងពេលបណ្តឹងសាទុក្ខស្ថិតក្នុងរង្វង់ (និងទាំងស្រុង) នៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះតាមមូលហេតុដែលត្រូវបានពន្យល់ដូចផ្នែកទី ២ ខាងក្រោម ។

3. តាមសេចក្តីសម្រេចចុះថ្ងៃទី ០១ ខែ តុលា (មូលហេតុដែលបានផ្តល់នៅថ្ងៃទី ១១ ខែ តុលា) ការិយាល័យរដ្ឋបាល កំណត់ការយល់ឃើញបែបចង្អៀត និងមិនត្រឹមត្រូវចំពោះអាណត្តិរបស់សហមេធាវីនាំមុខ។ ផ្អែកតាមការបកស្រាយដែលយល់ច្រឡំចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធានផ្ទៃក្នុង ការិយាល័យដ្ឋបាលបានកាត់បន្ថយធនធានរបស់សហមេធាវីអន្តរជាតិនាំមុខ ដោយបញ្ចប់ការងាររបស់ទីប្រឹក្សាអន្តរជាតិដែលជាអ្នកបានធ្វើការងារនៅក្នុងពេលជំនុំជម្រះក្តី និងការអនុវត្តសំណង។ ចំពោះការទទួលស្គាល់ឧបសគ្គថវិកា សហមេធាវីអន្តរជាតិនាំមុខ បានស្នើមធ្យោបាយដោយថា ទីប្រឹក្សាអន្តរជាតិអាចបន្តការងារ*ដោយផ្អែកលើមូលដ្ឋានចំណាយអព្យាក្រឹត្យ* ដូច្នេះក្រុមការងារអាចរក្សាធនធានដើម្បីបំពេញការងារស្នូលបន្តទៀត។ សំណើនេះត្រូវបានបដិសេធចោល។ ការបាត់បង់ទីប្រឹក្សាអន្តរជាតិនេះ នឹងកាត់បន្ថយសមត្ថភាពការងាររបស់ក្រុមការងារយ៉ាងខ្លាំង ហើយធ្វើឱ្យការតំណាងដើមបណ្តឹងរដ្ឋប្បវេណីដោយប្រសិទ្ធភាព (ក៏ដូចជា

[1] ឯកសារ F69/1 សេចក្តីសម្រេចលើសំណើបន្ទាន់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដាក់សារណាមួយភាសា និងការពន្លឿនកាលវិភាគដាក់សារណា, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០២១, ទំព័រ ២ ។

ការជំនុំជម្រះក្ដីដោយភាពយុត្តិធម៌) មិនអាចទៅរួចឡើយ។ ការបកស្រាយដោយយល់ច្រឡំរបស់ការិយល័យរដ្ឋបាលចំពោះអាណត្តិរបស់សហមេធាវីនាំមុខ ក៏ធ្វើឱ្យសំណើសុំទាក់ទងធនធានផ្សេងទៀត មានការសង្ស័យផងដែរ។ បើទោះបីជាការដាក់សារណាបណ្ដឹងសាទុក្ខបានបញ្ចប់ទៅក្ដី ក៏អាណត្តិរបស់សហមេធាវីនាំមុខ ត្រូវការចាំបាច់សម្រាប់ជំហានបន្ត ហើយទាំងនេះទាមទារឱ្យមានកម្រិតធនធានអប្បបរមាមួយ និងការចងចាំរួម។

4. សេចក្ដីសម្រេចរបស់ការិយាល័យរដ្ឋបាល គឺផ្អែកលើការយល់ខុសទៅលើអាណត្តិរបស់សហមេធាវីនាំមុខ (ផ្នែកទី ៦) បដិសេធធនធានចាំបាច់សម្រាប់ធ្វើជាតំណាងដោយប្រសិទ្ធភាពមិនសមហេតុផល (ផ្នែកទី ៧) និងរំលោភលើការរំពឹងទុកស្របច្បាប់របស់សហមេធាវីនាំមុខ (ផ្នែកទី ៨) ។

5. សហមេធាវីនាំមុខ មានភាពស្ទាក់ស្ទើរក្នុងការដាក់ឯកសារនេះ ដោយដឹងអំពីបន្ទុកការងារដែលអង្គជំនុំជម្រះត្រូវប្រឈម។ ទោះជាយ៉ាងណាក៏ដោយ សហមេធាវីនាំមុខគ្មានជម្រើសណាមួយដែលត្រូវបានផ្ដល់ដោយការិយាល័យរដ្ឋបាលនោះទេ ជាពិសេសពាក់ព័ន្ធនឹងសេចក្ដីជូនដំណឹងដ៏ខ្លី ពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចរបស់ការិយាល័យរដ្ឋបាល និងផលប៉ះពាល់ដែលមិនអាចស្ដារឡើងវិញបានទៅលើប្រសិទ្ធភាពនៃការតំណាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

## ២. អង្គហេតុ

6. បច្ចុប្បន្ន សហមេធាវីនាំមុខត្រូវបានគាំទ្រដោយទីប្រឹក្សាផ្នែកច្បាប់អន្តរជាតិម្នាក់ (រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១) និងបុគ្គលិកជាតិពីរនាក់[2]។

7. នៅថ្ងៃអង្គារ ទី២១ ខែកញ្ញា ឆ្នាំ២០២១ សហមេធាវីអន្តរជាតិនាំមុខ (“ILCL”) បានដាក់សំណើសុំធនធានប្រចាំត្រីមាសរបស់ខ្លួនទៅការិយាល័យរដ្ឋបាល (“អនុស្សរណៈទីមួយរបស់សហមេធាវីអន្តរជាតិនាំមុខ”) ដោយពន្យល់ពីបន្ទុកការងាររបស់ខ្លួន និងតម្រូវការផ្នែកធនធានសម្រាប់ត្រីមាសបន្ទាប់ និងរយៈពេលសេសសល់នៃសំណុំរឿង[3]។ បើទោះបីជាសារណាបណ្ដឹងសាទុក្ខត្រូវបាន

[2] ធនធានទីប្រឹក្សាផ្នែកច្បាប់ជាន់ទាបអន្តរជាតិរយៈពេលខ្លីបន្ថែម ត្រូវបានផ្ដល់ជូនសម្រាប់រយៈពេលដ៏មមាញឹកក្នុងអំឡុងពេលដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០២ ដែលអំឡុងពេលចុងក្រោយ គឺសម្រាប់ខែកក្កដា-សីហា ឆ្នាំ២០២១។

[3] ឧបសម្ព័ន្ធ ក ៖ អនុស្សរណៈទីមួយរបស់សហមេធាវីអន្តរជាតិនាំមុខ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ (“អនុស្សរណៈទីមួយរបស់សហមេធាវីអន្តរជាតិនាំមុខ”)។

បញ្ចប់ក្ដី ហើយភាគីដទៃអាចពុំសូវរវល់ក្ដី សម្រាប់សហមេធាវីនាំមុខ ទំហំការងារសំខាន់ៗដែលនៅសេសសល់ ត្រូវបន្តធ្វើរួមមាន ៖ (i) កិច្ចប្រជុំជាមួយដើមបណ្ដឹងរដ្ឋប្បវេណី (ii) ការដាក់សំណើសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ (iii) ការដាក់សំណើសុំលើការអនុវត្តសំណង (iv) សកម្មភាពទាក់ទងនឹងកេរ្តិ៍ដំណែល រួមមានការចូលរួមជាមួយសហអ្នកធ្វើរបាយការណ៍ ស្ដីពីមុខងារដែលសេសសល់ទាក់ទិនទៅនឹងជនរងគ្រោះ "សហអ្នកធ្វើរបាយការណ៍"[4] និងការធានាបាននូវព័ត៌មានត្រឹមត្រូវទាក់ទងនឹងការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅលើគេហទំព័ររបស់តុលាការ (v) ការពិនិត្យឡើងវិញ និងការរក្សាទុកឯកសាររបស់សហមេធាវីនាំមុខក្នុងបណ្ណសារ (រួមទាំងការវាយតម្លៃអំពីបុព្វសិទ្ធិវិជ្ជាជីវៈផ្លូវច្បាប់)។ ថ្វីបើយ៉ាងនេះក្ដី មានការបញ្ជាក់យ៉ាងច្បាស់ចំពោះសហមេធាវីអន្តរជាតិនាំមុខថា ខ្លួនត្រូវបានរំពឹងថានឹងកាត់បន្ថយធនធានជារួម។ ស្របតាមការពិភាក្សាពីមុនជាមួយការិយាល័យរដ្ឋបាល សហមេធាវីអន្តរជាតិនាំមុខបានស្នើឱ្យបន្តការងាររបស់ទីប្រឹក្សាផ្នែកច្បាប់របស់ខ្លួន ទោះបីម៉ោងធ្វើការរបស់ខ្លួន ត្រូវបានកាត់បន្ថយក៏ដោយ។ នេះជាមធ្យោបាយដ៏មានប្រសិទ្ធតម្លៃមួយក្នុងការបង្កើនធនធានដែលមាន ដូច្នេះ ការងារសំខាន់ៗដែលអាក់សកម្ម អាចត្រូវបានដោះស្រាយ។ រហូតមកដល់ពេលនេះ ការិយាល័យរដ្ឋបាលបានគាំទ្រវិធីសាស្ត្រនេះ[5]។

8. នៅថ្ងៃព្រហស្បតិ៍ ទី ២៣ ខែ កញ្ញា ការិយាល័យរដ្ឋបាលបានឆ្លើយតបដោយអនុស្សរណៈមួយ ("អនុស្សរណៈទីមួយរបស់ការិយាល័យរដ្ឋបាល")[6]។ ការិយាល័យរដ្ឋបាលបានយល់ស្របថា ការងារធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ និងការធ្វើរបាយការណ៍អំពីការអនុវត្តសំណង គឺស្ថិតនៅក្នុងអាណត្តិរបស់សហមេធាវីនាំមុខ ប៉ុន្តែបានបញ្ជាក់ពីទស្សនៈបណ្ដោះអាសន្នរបស់ខ្លួនថា ភារកិច្ចផ្សេងៗទៀតដែលបានរៀបរាប់នៅក្នុងអនុស្សរណៈទីមួយរបស់ការិយាល័យរដ្ឋបាល មិនស្ថិតនៅក្នុងអាណត្តិរបស់សហមេធាវីនាំមុខឡើយ ហើយដូច្នេះមិនគួរផ្ដល់ប្រាក់កម្រៃទេ។ អនុស្សរណៈទីមួយរបស់ការិយាល័យរដ្ឋបាល ក៏បានចោទសួរផងដែរ ថាតើការងាររបស់សហមេធាវីនាំមុខ គួរត្រូវបានបែងចែករវាងសហមេធាវីអន្តរជាតិនាំមុខ និងទីប្រឹក្សាដែរឬយ៉ាងណា ជាពិសេស ពាក់ព័ន្ធទៅនឹងការពិតដែលថា មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី "អាចជួយការងាររបស់សហមេធាវីនាំមុខបាន"

---

[4] សូមមើលឧបសម្ព័ន្ធ ខ ៖ សេចក្ដីអំពាវនាវឱ្យមានការចូលរួមចំណែកផ្ដល់យោបល់ស្ដីពីមុខងារដែលនៅសេសសល់ដែលពាក់ព័ន្ធនឹងជនរងគ្រោះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។

[5] សូមមើលសេចក្ដីលម្អិតខាងក្រោមនៅត្រង់ចំណុចទី ៨ ។

[6] ឧបសម្ព័ន្ធ គ ៖ អនុស្សរណៈទីមួយរបស់ការិយាល័យរដ្ឋបាល ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ("អនុស្សរណៈទីមួយរបស់ការិយាល័យរដ្ឋបាល")។

។ ការិយាល័យរដ្ឋបាល បានស្នើឱ្យសហមេធាវីអន្តរជាតិនាំមុខផ្តល់ទស្សនៈរបស់ខ្លួនលើបញ្ហាទាំងនេះ។

9. នៅថ្ងៃពុធ ទី ២៩ ខែ កញ្ញា សហមេធាវីអន្តរជាតិនាំមុខបានផ្ញើអនុស្សរណៈមួយបន្ថែមទៀតទៅការិយាល័យរដ្ឋបាល ដោយឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងនៅក្នុងអនុស្សរណៈទីមួយរបស់ការិយាល័យរដ្ឋបាល ("អនុស្សរណៈទីពីររបស់សហមេធាវីអន្តរជាតិនាំមុខ")[7]។

10. នៅល្ងាច ថ្ងៃសុក្រ ទី ០១ ខែ តុលា សហមេធាវីអន្តរជាតិនាំមុខ ត្រូវបានជូនដំណឹងដោយការិយាល័យរដ្ឋបាលថា ការិយាល័យរដ្ឋបាលបានសម្រេចផ្តល់*ម៉ោងបំពេញការងារ* ដល់ខ្លួន*ច្រើនជាងម៉ោង*ដែលបានស្នើសុំ ប៉ុន្តែត្រូវបញ្ឈប់តំណែងទីប្រឹក្សារបស់ខ្លួន៖

១. ចំនួនម៉ោងបំពេញការងារអតិបរមារបស់លោក/លោកស្រី ត្រូវបានអនុម័តរហូតដល់ ១០០% សម្រាប់ខែតុលា វិច្ឆិកា និងខែធ្នូ។ សកម្មភាពផ្សព្វផ្សាយ ដែលត្រូវបានធ្វើឡើងក្នុងការពិគ្រោះយោបល់ជាមួយ និងក្នុងការសម្របសម្រួលដល់ដើមបណ្តឹងរដ្ឋប្បវេណី និងសកម្មភាពដែលទាក់ទងនឹងការតំណាង គឺអាចទទួលបានប្រាក់កម្រៃ។ ប្រសិនបើមាន សកម្មភាពទាំងនេះត្រូវតែបញ្ជាក់លម្អិតឱ្យបានច្បាស់លាស់នៅក្នុងតារាងម៉ោងបំពេញការងាររបស់លោក/លោកស្រី។ ការងារដែលទាក់ទងនឹងគេហទំព័រ ការបិទបញ្ចប់/ការរក្សាទុកក្នុងបណ្ណសារ និង"កេរដំណែល" (រួមទាំងការឆ្លើយតបទៅនឹងសហចៅក្រមរបាយការណ៍ស្តីពីជនរងគ្រោះ) មិនទទួលបានកម្រៃនោះទេ។

២. ទីប្រឹក្សាផ្នែកច្បាប់ត្រូវបានបន្តនៅក្រោមលក្ខខណ្ឌតែមួយ ដែលយ៉ាងយូរបំផុត គឺនៅត្រឹមខែតុលា។

៣. ភាពចាំបាច់នៃការគាំទ្រផ្នែកច្បាប់បន្ថែមដល់សហមេធាវីនាំមុខត្រូវមានភាពសមហេតុផលឆ្ពោះទៅមុខ ដោយយោងតាមតំរូវការផ្នែកតុលាការជាក់ស្តែងទាក់ទងនឹងអាណត្តិរបស់សហមេធាវីនាំមុខ។ ការគាំទ្រក្នុងទម្រង់ជាទីប្រឹក្សា អាចត្រូវបានផ្តល់ជូនដោយផ្អែកលើមូលដ្ឋានដែលបានកំណត់ (ដែលអាចផ្តល់ជូនបាន) អាស្រ័យលើយុត្តិកម្មគ្រប់គ្រាន់[8]។

11. ភ្លាមៗនោះ សហមេធាវីអន្តរជាតិនាំមុខ បានស្នើសុំការបញ្ជាក់បំភ្លឺ ជាពិសេសថាតើមានការផ្តល់ប្រឹក្សាថ្មីដែរឬទេ បើទោះបីជានៅក្នុងលក្ខខណ្ឌផ្សេងក្តី ឬថាតើធនធានសម្រាប់ការផ្តល់ប្រឹក្សា នឹង

---

[7] ឧបសម្ព័ន្ធ ឃ ៖ អនុស្សរណៈទីពីររបស់សហមេធាវីនាំមុខអន្តរជាតិ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ("អនុស្សរណៈទីពីររបស់សហមេធាវីនាំមុខអន្តរជាតិ")។

[8] ឧបសម្ព័ន្ធ ង ៖ ការឆ្លើយឆ្លងអ៊ីមែលរវាងការិយាល័យរដ្ឋបាល និងសហមេធាវីនាំមុខអន្តរជាតិ ទំព័រ ៣-៤ (អ៊ីមែលពីការិយាល័យរដ្ឋបាលផ្ញើជូនសហមេធាវីនាំមុខអន្តរជាតិ ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១)។

ត្រូវបញ្ចប់នៅខែតុលា ឬយ៉ាងណា[9]។ សំណើសុំការឆ្លើយតបបន្ថែមមួយទៀត ត្រូវបានផ្ញើនៅថ្ងៃចន្ទ ទី០៤ ខែ តុលា[10]។ គ្មានការឆ្លើយតបណាមួយត្រូវបានទទួលនោះឡើយ។

12. នៅថ្ងៃអង្គារ ទី០៥ ខែ តុលា សហមេធាវីអន្តរជាតិនាំមុខបានផ្ញើអនុស្សរណៈមួយបន្ថែមទៀតទៅការិយាល័យរដ្ឋបាល ដោយស្វែងរកការពិចារណាឡើងវិញ ("អនុស្សរណៈទីបីរបស់សហមេធាវីអន្តរជាតិនាំមុខ")[11]។ សហមេធាវីអន្តរជាតិនាំមុខ បានកត់សម្គាល់ថា ក្នុងករណីមានការឆ្លើយតបបែបអវិជ្ជមាន ប្រការចាំបាច់គឺត្រូវលើកយកបញ្ហានេះមកពិភាក្សានៅក្នុងអង្គជំនុំជម្រះ និងថាពេលវេលាសម្រាប់ដោះស្រាយបញ្ហានេះ គឺខ្លីណាស់។ សហមេធាវីអន្តរជាតិនាំមុខបានស្នើសុំឱ្យមានការឆ្លើយតប និងផ្តល់ហេតុផលសមស្របនៅត្រឹមថ្ងៃសុក្រទី០៨ ខែ តុលា។

13. នៅល្ងាចថ្ងៃទី០៥ ខែតុលា មន្ត្រីនៃការិយាល័យរដ្ឋបាល ដែលទទួលខុសត្រូវបានឆ្លើយតបដោយបញ្ជាក់ថា គាត់ "រំពឹងថានឹងមានការឆ្លើយតបចំពោះ [សហមេធាវីអន្តរជាតិនាំមុខ] នៅសប្តាហ៍ក្រោយ"[12]។

14. នៅថ្ងៃទី០៦ ខែតុលា សហមេធាវីអន្តរជាតិនាំមុខ បានផ្ញើអ៊ីមែលជាថ្មីម្តងទៀត ដើម្បីស្វែងរកការបញ្ជាក់បំភ្លឺយ៉ាងខ្លី ថាតើធនធានសម្រាប់ការផ្តល់ការប្រឹក្សារបស់គាត់ត្រូវបានបញ្ចប់ ឬយ៉ាងណា ដោយរង់ចាំហេតុផលពេញលេញ ដើម្បីឱ្យគាត់អាចរៀបចំការងារក្រុមរបស់គាត់ឱ្យបានសមស្របបំផុត[13]។ គ្មានការឆ្លើយតបណាមួយត្រូវបានទទួលនោះឡើយ។

15. នៅថ្ងៃទី ០៨ ខែ តុលា សហមេធាវីអន្តរជាតិនាំមុខ បានផ្ញើអ៊ីមែលទៅការិយាល័យរដ្ឋបាលម្តងទៀតដោយបញ្ជាក់ថា សហមេធាវីនាំមុខ មានបំណងដាក់ឯកសារទៅអង្គជំនុំជម្រះ និងចោទសួរ

---

[9] ឧបសម្ព័ន្ធ ង ៖ ការឆ្លើយឆ្លងអ៊ីមែលរវាងការិយាល័យរដ្ឋបាល និងសហមេធាវីនាំមុខអន្តរជាតិ ទំព័រ ៣ (អ៊ីមែលពីសហមេធាវីនាំមុខអន្តរជាតិ ផ្ញើជូនការិយាល័យរដ្ឋបាល ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០២១)។

[10] ឧបសម្ព័ន្ធ ង ៖ ការឆ្លើយឆ្លងអ៊ីមែលរវាងការិយាល័យរដ្ឋបាល និងសហមេធាវីនាំមុខអន្តរជាតិ ទំព័រ ២-៣ (អ៊ីមែលពីសហមេធាវីនាំមុខអន្តរជាតិ ផ្ញើជូនការិយាល័យរដ្ឋបាល ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០២១)។

[11] ឧបសម្ព័ន្ធ ច ៖ អនុស្សរណៈទីបីរបស់សហមេធាវីអន្តរជាតិនាំមុខ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១ ("អនុស្សរណៈទីបីរបស់សហមេធាវីអន្តរជាតិនាំមុខ")។

[12] ឧបសម្ព័ន្ធ ង ៖ ការឆ្លើយឆ្លងអ៊ីមែលរវាងការិយាល័យរដ្ឋបាល និងសហមេធាវីអន្តរជាតិនាំមុខ ទំព័រ ២ (អ៊ីមែលពីការិយាល័យរដ្ឋបាល ផ្ញើជូនសហមេធាវីអន្តរជាតិនាំមុខ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១)។

[13] ឧបសម្ព័ន្ធ ង ៖ ការឆ្លើយឆ្លងអ៊ីមែលរវាងការិយាល័យរដ្ឋបាល និងសហមេធាវីអន្តរជាតិនាំមុខ ទំព័រ ១-២ (អ៊ីមែលពីសហមេធាវីអន្តរជាតិ នាំមុខ ផ្ញើជូនការិយាល័យរដ្ឋបាល ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០២១)។

ថា តើការិយាល័យរដ្ឋបាលយល់ព្រមរក្សាទុក្ខធនធានទីប្រឹក្សាក្នុងអំឡុងពេលមានភាពចម្រូងចម្រាស់ ឬយ៉ាងណា។ នៅក្នុងអ៊ីមែលដដែលនេះ សហមេធាវីអន្តរជាតិនាំមុខ បានបញ្ជាក់ថា ការខកខានក្នុងការផ្លាស់ប្តូរកាលៈទេសៈទាំងនេះ នៅត្រឹមថ្ងៃចន្ទ ខ្លួននឹងផ្តល់ភារកិច្ចដល់ទីប្រឹក្សារបស់ខ្លួនដោយបិទបញ្ចប់ ហើយរៀបចំអ៊ីមែល និងឯកសាររបស់គាត់ ព្រមទាំងស្នើឱ្យការិយាល័យរដ្ឋបាលបញ្ជាក់ថា ការិយាល័យរដ្ឋបាលនឹងផ្តល់ប្រាក់កម្រៃដល់សហមេធាវីអន្តរជាតិនាំមុខក្នុងការការដឹកនាំ និងត្រួតពិនិត្យភារកិច្ចនោះ[14]។ គ្មានការឆ្លើយតបណាមួយត្រូវបានទទួលនោះឡើយ។

16. នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០២១ ការិយាល័យរដ្ឋបាលបានផ្ញើអនុស្សរណៈមួយដោយផ្តល់ហេតុផលសម្រាប់សេចក្តីសម្រេចនៅថ្ងៃទី ១ ខែ តុលា និងបដិសេធក្នុងការពិចារណាម្តងទៀត ("អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល")[15]។

17. នៅល្ងាចថ្ងៃទី ១២ ខែ តុលា សហមេធាវីនាំមុខបានដាក់សំណើបន្ទាន់របស់ខ្លួន ដោយសុំដាក់ឯកសារតែមួយភាសា និងសុំការពន្លឿនកាលបរិច្ឆេទដាក់ឯកសារ ហើយបានផ្ញើច្បាប់ចម្លងជូនទៅអង្គជំនុំជម្រះ និងភាគី[16]។

18. នៅថ្ងៃទី ១៨ ខែ តុលា អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចបដិសេធសំណើចោល[17]។

19. ដូចគ្នាដែរ នៅថ្ងៃទី ១៨ ខែ តុលា ទីប្រឹក្សារបស់សហមេធាវីអន្តរជាតិនាំមុខ បានទទួលអ៊ីម៉ែលមួយដោយជូនដំណឹងមកគាត់ថា គាត់នឹងត្រូវបញ្ចប់ការងារនៅថ្ងៃទី ៣១ ខែ តុលា។ សហមេធាវីអន្តរជាតិនាំមុខ មិនបានទទួលការឆ្លើយតបណាមួយទៅនឹងអ៊ីម៉ែលរបស់ខ្លួន នៅថ្ងៃទី ២, ៤, ៦ និងទី ៨ ខែតុលា ឆ្នាំ ២០២១ នោះឡើយ។

---

[14] ឧបសម្ព័ន្ធ ង ៖ ការឆ្លើយឆ្លងអ៊ីមែលរវាងការិយាល័យរដ្ឋបាល និងសហមេធាវីអន្តរជាតិនាំមុខ ទំព័រ ១ (អ៊ីមែលពីសហមេធាវីអន្តរជាតិនាំមុខ ផ្ញើជូនការិយាល័យរដ្ឋបាល ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១)។

[15] ឧបសម្ព័ន្ធ ឆ ៖ អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ ("អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល")។

[16] ឯកសារ **F69** សំណើបន្ទាន់របស់សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំដាក់ឯកសារតែមួយភាសា និងសុំការពន្លឿនកាលបរិច្ឆេទដាក់ឯកសារ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១។ សំណើនេះត្រូវបានជូនដំណឹងនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១។

[17] ឯកសារ F69/1 សេចក្តីសម្រេចលើសំណើបន្ទាន់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដាក់សារណាមួយភាសា និងការពន្លឿនកាលវិភាគដាក់សារណា, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០២១, ទំព័រ ២ ។

## ៣. ក្របខ័ណ្ឌគតិយុត្តិពាក់ព័ន្ធ

20. សហមេធាវីនាំមុខ ពឹងផ្អែកជាពិសេសទៅលើវិធាន ១២ *ស្ទួនពីរ* វិធាន ២៣ (៣) និងវិធាន ១២ ដែលកំណត់ពីក្របខ័ណ្ឌសម្រាប់ការធ្វើជាតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងទំនាក់ទំនងរបស់សហមេធាវីនាំមុខ ជាមួយការិយាល័យរដ្ឋបាល។

## ៤. សិទ្ធិអំណាចរបស់អង្គជំនុំជម្រះក្នុងការកំណត់លើបញ្ហានេះ

21. ក្នុងករណីណាក៏ដោយ វាច្បាស់ណាស់ថា អង្គជំនុំជម្រះបានលើកយកករណីដែលមានសិទ្ធិអំណាច និងភារកិច្ចជាប់ពាក់ព័ន្ធក្នុងការធានាការជំនុំជម្រះដោយយុត្តិធម៌។ វាត្រូវបានបង្កើតឡើងយ៉ាងល្អទាំងតុលាការនេះ[18] និងតុលាការព្រហ្មទណ្ឌដទៃទៀត[19] ដែលអំណាចនេះរួមមានដោះស្រាយបញ្ហានៃការផ្ដល់ធនធាន ដែលនេះមានផលប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ និង/ឬភាពត្រឹមត្រូវនៃដំណើរការនីតិវិធីរបស់ភាគី។ នៅ អ.វ.ត.ក សិទ្ធិអំណាចនោះត្រូវបានអនុវត្តង

[18] សូមមើលជាពិសេស ៖ **សំណុំរឿង ០០៤ -** ឯកសារ **D304/1** ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបង្គាប់ឱ្យអង្គភាពគាំពារការការពារក្ដីផ្ដល់ធនធានបន្ថែម ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ ជាពិសេសនៅត្រង់កថាខណ្ឌ ៦-៧។ **សំណុំរឿង ០០៤**-ឯកសារ **D304/4** ដីកាសម្រេចថែមទៀតលើសំណើរបស់ អោ អាន សុំបង្គាប់ឱ្យអង្គភាពគាំពារការការពារក្ដីផ្ដល់ធនធានបន្ថែម ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ជាពិសេសនៅត្រង់កថាខណ្ឌ ១៨។ ស.ច.ស បានលើកយោងដល់សេចក្ដីសម្រេចដែលពាក់ព័ន្ធពីតុលាការ ICTY។ សូមមើលជាពិសេស ៖ រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Šešelj* សំណុំរឿងលេខ IT-03-67-R33B សំណៅកោសលុបជាសាធារណៈនៃ“សេចក្ដីសម្រេចស្ដីពីសារណារបស់តុលាការរដ្ឋបាល អនុលោមតាមវិធាន ៣៣(ខ) ទាក់ទងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើថវិកាមេធាវីការពារក្ដី” ដែលចេញនៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១១ កថាខណ្ឌ ១៩-២០។ រឿងក្ដី *រដ្ឋអាជ្ញាតទល់នឹង Karadžić* សំណុំរឿងលេខ IT-95-5-1- PT សេចក្ដីសម្រេចលើញត្តិរបស់ជនជាប់ចោទស្នើសុំមធ្យោបាយគ្រប់គ្រាន់ និងសមភាពនៃគោលការណ៍តទល់ក្ដី៖ អនុទីប្រឹក្សាច្បាប់ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ កថាខណ្ឌ ១២។

[19] បន្ថែមទៅលើកសំណុំរឿងនៅតុលាការ ICTY ដែលបានដកស្រង់ខាងលើ សូមមើលឧទាហរណ៍: SCSL, *រដ្ឋអាជ្ញា ទទល់នឹង Brima*, SCSL04-16-PT, Brima - សេចក្ដីសម្រេចលើសំណើរបស់អ្នកដាក់ពាក្យសុំប្រឆាំងនឹងការបដិសេធដោយអ្នកការពារក្ដីសំខាន់ស្ដីទី ដើម្បីបញ្ចូលកិច្ចសន្យាសម្រាប់ការងាររបស់ទីប្រឹក្សា ចុះថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០០៤ កថាខណ្ឌ ២៩-៧១ ។ *រដ្ឋអាជ្ញា តទល់នឹង Sesay, Kallon និង Gbao*, SCSL-04-15-T, សេចក្ដីសម្រេចលើពាក្យសុំទី I របស់ផ្នែកការបារក្ដី Sesay - ធនធានភសភា ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៧ ទំព័រ ៣-៤។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Šešelj*, IT-03-67-PT, សេចក្ដីសម្រេចលើហិរញ្ញវត្ថុនៃផ្នែកការពារក្ដីរបស់ជនជាប់ចោទ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ កថាខណ្ឌ ៣៣-៣៧។ តុលាការ ICC *រដ្ឋអាជ្ញា តទល់នឹង Bemba Gombo* ច្បាប់កោសលុប នៃ “សេចក្ដីសម្រេចលើជំនួយការផ្នែកច្បាប់សម្រាប់ជនជាប់ចោទ”, ICC-01/05-01/08-567-Red ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១០៦។

ដែលៗដោយសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) ក្នុងអំឡុងពេលដំណាក់កាលមុនជំនុំជម្រះ[20] ។ នៅក្នុងសំណុំរឿងបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងក៏បានលើកឡើងពីបញ្ហានៃការផ្តល់ធនធានដល់មេធាវីការពារក្តីជាមួយការិយាល័យរដ្ឋបាលផងដែរ ដើម្បីធានាពីការជម្រះក្តីដោយយុត្តិធម៌[21] ។

22. សំណុំរឿង ០០២/០២ គឺនៅចំពោះមុខអង្គជំនុំជម្រះ។ វិធានផ្ទៃក្នុងដែលអនុវត្តបានចំពោះអង្គជំនុំជម្រះសាលាដំបូង *ក្នុងករណីសមស្រប* គឺអាចអនុវត្តបានចំពោះអង្គជំនុំជម្រះ[22]។ សិទ្ធិអំណាចដែលមានជាប់មកជាមួយ ដើម្បីរក្សាសិទ្ធិរបស់ភាគី និងភាពត្រឹមត្រូវនៃដំណើរការនីតិវិធី ដែល ស.ច.ស យល់ឃើញថាពួកគាត់មានក្នុងអំឡុងពេលស៊ើបអង្កេត[23] បច្ចុប្បន្នក៏អង្គជំនុំជម្រះត្រូវមានផងដែរ។ ជាការពិត អង្គជំនុំជម្រះបានទទួលស្គាល់ ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី ថា “អង្គជំនុំ

---

[20] សូមមើល ជាពិសេស ៖ **សំណុំរឿង ០០៤** - ឯកសារ **D304/1** ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបង្គាប់ឱ្យអង្គភាពគាំពារការការពារក្តីផ្តល់ធនធានបន្ថែម ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ ជាពិសេសនៅត្រង់កថាខណ្ឌ ៦-៧។ **សំណុំរឿង ០០៤**-ឯកសារ **D304/4** ដីកាសម្រេចថែមទៀតលើសំណើរបស់ អោ អាន សុំបង្គាប់ឱ្យអង្គភាពគាំពារការការពារក្តីផ្តល់ធនធានបន្ថែម ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ជាពិសេសនៅត្រង់កថាខណ្ឌ ១៨។ **សំណុំរឿង ០០៤**-ឯកសារ **D304/7** ដីកាសម្រេចលើសំណើរបស់អោ អាន សុំបង្គាប់ឱ្យអង្គភាពគាំពារការការពារក្តីផ្តល់ធនធានបន្ថែម ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦។ **សំណុំរឿង ០០៤**-ឯកសារ **D312/1** ដីកាសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ ទាក់ទិននឹងធនធានរបស់ក្រុមមេធាវីការពារក្តី ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៦។ **សំណុំរឿង ០០៤**-ឯកសារ **D312/4** ដីកាសម្រេចទី ២ លើសំណើបន្ទាន់របស់ យឹម ទិត្យ ទាក់ទងនឹងធនធានបន្ថែមរបស់មេធាវីការពារក្តី ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦។ **សំណុំរឿង ០០៤**-ឯកសារ **D304/11** ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំបន្តផ្តល់ធនធានចាំបាច់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦។ **សំណុំរឿង ០០៤**-ឯកសារ **D321/1** ដីកាសម្រេច លើសំណើបន្ទាន់ស្តីពីការបំពេញការងារពីចម្ងាយ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ជាពិសេសនៅត្រង់កថាខណ្ឌ ៩។

[21] ឯកសារ **E320/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង៖ សេចក្តីសម្រេចបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ៧។ ឯកសារ **E369** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង៖ សំណើសុំការបំភ្លឺអំពីធនធានបន្ថែមសម្រាប់ក្រុមមេធាវីការពារក្តីក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥។ ឯកសារ **E369/2** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង៖ សំណើសុំការបំភ្លឺអំពីធនធានបន្ថែមសម្រាប់ក្រុមមេធាវីការពារក្តីក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១៥។ ឯកសារ **E363/3** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ កថាខណ្ឌ ៣៨។

[22] វិធាន ១០៤ *ស្ទួន* នៃវិធានផ្ទៃក្នុង។

[23] សូមមើលដីកាសម្រេចដែលបានយោងខាងលើនៅក្នុងជើងទំព័រ ១៨។

ជម្រះមានភារកិច្ចធានាថា សិទ្ធិរបស់ពួកគាត់ត្រូវបានគោរព ដើម្បីការពារសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីទាំងមូល”[24]។

23. បន្ថែមពីលើសិទ្ធិអំណាចដែលមានជាប់មកជាមួយរបស់អង្គជំនុំជម្រះ ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ មានការកំណត់ឡើងយ៉ាងត្រឹមត្រូវផងដែរថា នៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ អង្គជំនុំជម្រះមានសិទ្ធិពិនិត្យឡើងវិញ និងបដិសេធចោលសេចក្តីសម្រេចរដ្ឋបាលដែលអ្នកធ្វើសេចក្តីសម្រេច ៖

(ក) ខកខានពុំបានប្រតិបត្តិតាម [...] លក្ខខណ្ឌគតិយុត្តិ [...] ឬ

(ខ) ខកខានពុំបានគោរពច្បាប់មូលដ្ឋានណាមួយនៃយុត្តិធម៌ធម្មជាតិ ឬធ្វើសកម្មភាពប្រកបដោយភាពយុត្តិធម៌ខាងនីតិវិធីចំពោះបុគ្គលដែលរងផលប៉ះពាល់ដោយសេចក្តីសម្រេចនេះ ឬ

(គ) បានពិចារណាទៅលើសម្ភារៈដែលមិនពាក់ព័ន្ធ ឬខកខានពុំបានពិចារណាទៅលើសម្ភារៈដែលពាក់ព័ន្ធ ឬ

(ឃ) សម្រេចថា ពុំអាចមានជនដែលមានសុភវិនិច្ឆ័យណាម្នាក់ ដែលបានដោះស្រាយបញ្ហានេះឱ្យបានត្រឹមត្រូវនោះឡើយ (លក្ខណៈវិនិច្ឆ័យ“មិនសមហេតុផល”) [វង់ក្រចៀបដើម][25]។

24. សហមេធាវីនាំមុខទទួលស្គាល់ថា ចំពោះមុខតុលាការមួយចំនួន ការលើកលែងទៅលើសិទ្ធិអំណាចនៃការជម្រះក្តីដោយយុត្តិធម៌របស់អង្គជំនុំជម្រះដែលបានលើកឡើង មាននៅតាមវេទិកាផ្សេងទៀត (ឧទាហរណ៍ អាណត្តិប្រធានាធិបតី) ត្រូវបានផ្តល់ជូនយ៉ាងច្បាស់លាស់ជាមួយនឹងយុត្តាធិការលើប្រភេទបញ្ហាជាក់លាក់ ៖ ក្នុងករណី អង្គជំនុំជម្រះដែលបានលើកឡើង អាចត្រឹមតែធ្វើអន្តរាគមន៍ប៉ុណ្ណោះ បន្ទាប់ពីសំណងទាំងអស់ផ្សេងទៀត ត្រូវបានប្រើប្រាស់អស់[26] ។ នៅ អ.វ.ត.ក វិវាទទាក់ទងនឹងការផ្តល់ធនធានដល់មេធាវីការពារក្តី ជាញឹកញាប់ត្រូវបានដោះស្រាយដោយ “ចៅក្រម

[24] ឯកសារ **F65** សេចក្តីសម្រេចលើសំណើសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំការពន្យារពេលសវនាការលើ បណ្តឹងសាទុក្ខ និងសេចក្តីបង្គាប់ពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ កថាខណ្ឌ ៥១។

[25] រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Karadžić* សំណុំរឿងលេខ IT-95-5/18-T សេចក្តីសម្រេចលើការស្នើសុំសើរើឡើងវិញនូវសេចក្តីសម្រេចរបស់ប្រធានការិយាល័យរដ្ឋបាល និងសុំការច្រានចោលទាំងស្រុង ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ កថាខណ្ឌ ៤។

[26] តុលាការ ICTY រដ្ឋអាជ្ញា តទល់នឹង *Blagojević*, IT-02-60-AR73.4 ហេតុផលជាសាធារណៈ និងកោសលុបសម្រាប់សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ ដោយ Vidoje Blagojević ដើម្បីជំនួសក្រុមការពារក្តីរបស់គាត់ ចុះថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣។ STL, *រដ្ឋអាជ្ញា តទល់នឹង Ayyash et al.*, STL-11-01/PT/PTJ សេចក្តីសម្រេចលើវេទិកាពិនិត្យសេចក្តីសម្រេចរបស់មន្ត្រីចុះបញ្ជីទាក់ទងនឹងការចាត់តាំងធនធានមនុស្សក្នុងស្រុក ចុះថ្ងៃទី០៩ ខែវិច្ឆកា ឆ្នាំ២០១២ កថាខណ្ឌ ២៩។

រដ្ឋបាល” ដែលត្រូវបានតែងតាំងជាពិសេស[27] ។ ទោះយ៉ាងណាក៏ដោយ នីតិវិធីនោះមានចែងនៅក្នុងប្រការនៃកិច្ចសន្យាសេវាកម្មច្បាប់ ដែលជំនួយការអង្គការសហប្រជាជាតិសម្រាប់ការជំនុំជម្រះខ្មែរក្រហម ចុះកិច្ចសន្យាជាមួយសហមេធាវីការពារក្ដីអន្តរជាតិ[28] ។ គ្មានកិច្ចសន្យាសេវាកម្មច្បាប់សមមូលសម្រាប់សហមេធាវីអន្តរជាតិនាំមុខនោះឡើយ។ ដូច្នេះ ប្រសិនបើអង្គជំនុំជម្រះមិនត្រូវបានផ្ដល់សិទ្ធិអំណាចដើម្បីដោះស្រាយបញ្ហានេះទេ សហមេធាវីនាំមុខ នឹងពុំទទួលបានសំណងនោះទេ។ លទ្ធផលអាចថា ការិយាល័យរដ្ឋបាលមិនបានត្រួតពិនិត្យ សូម្បីតែអ្វីដែលខ្លួនកំពុងតែបកស្រាយខុសទៅលើអាណត្តិរបស់ភាគី ក្រោមវិធានផ្ទៃក្នុងនៅក្នុងមធ្យោបាយបែបនេះ ព្រោះវាធ្វើឱ្យអន្តរាយដល់ការតំណាងដោយប្រសិទ្ធភាព និងការជំនុំជម្រះក្ដីដោយយុត្តិធម៌។ ដូចនៅតុលាការពិសេសចំពោះករណី Sierra Leone បានពន្យល់ថា ដំណោះស្រាយបែបនោះគួរតែត្រូវបានបដិសេធចោល ពីព្រោះវានឹងផ្ដល់អភ័យឯកសិទ្ធិផ្នែករដ្ឋបាលរបស់តុលាការប្រកបដោយប្រសិទ្ធភាព ហើយមានន័យថាមិនមានយន្តការណាមួយដើម្បីពិនិត្យ និងទប់ស្កាត់អំពើបំពាន ការប្រព្រឹត្ត ឬការសម្រេចដែលធ្វើឡើងដោយមន្ត្រីរដ្ឋបាលរបស់យើងនោះឡើយ[29]។

## ៥. សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការទទួលបានភាពយុត្តិធម៌ និងការតំណាងប្រកបដោយប្រសិទ្ធភាព

25. ដើមបណ្ដឹងរដ្ឋប្បវេណី គឺជាភាគីនៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក[30] និងមានសិទ្ធិទទួលបានភាពយុត្តិធម៌នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនោះ ស្របតាមមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរ

[27] សូមមើលឧទាហរណ៍៖ ចៅក្រមរដ្ឋបាលអង្គការសហប្រជាជាតិ សំណុំរឿងលេខ UNAKRT/UNAJ/SCC/2019/1 សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ជាបន្ទាន់របស់សហមេធាវីការពារក្ដី ខៀវ សំផន នៃសេចក្ដីសម្រេចរបស់អង្គភាពគាំពារការការពារក្ដី ដែលបដិសេធការជ្រើសរើសទីប្រឹក្សាផ្នែកច្បាប់អន្តរជាតិ (កំរិត ៣) ចូលជាធរមានចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៩។

[28] មាត្រា ១១.១ នៃកិច្ចសន្យាសេវាកម្មច្បាប់។ សូមមើល *ឯកសារយោងខាងលើនេះ* កថាខណ្ឌ ២៨។ ច្បាប់ចម្លងនៃគំរូកិច្ចសន្យាសេវាកម្មច្បាប់ឃើញមាននៅក្នុងសំណុំរឿង ជាឯកសារ **E320/2//2/1.1**។

[29] SCSLរឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Brima*, SCSL04-16-PT, Brima - សេចក្ដីសម្រេចទៅលើសំណើអ្នកដាក់ពាក្យសុំប្រឆាំងទៅនឹងការបដិសេធដោយអ្នកការពារក្ដីចម្បងស្ដីទី ដើម្បីបញ្ចូលកិច្ចសន្យាសេវាកម្មផ្លូវច្បាប់សម្រាប់ការចាត់តាំងទីប្រឹក្សា ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០០៤ កថាខណ្ឌ ៦៧ ។

[30] វិធានផ្ទៃក្នុង វិសោធនកម្មលើកទី៩ សន្ទានុក្រម។ **សំណុំរឿង ០០១**-ឯកសារ **F28** សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៤៨៨។

ជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[31]។ នាពេលថ្មីៗនេះ អង្គជំនុំជម្រះបានរំលឹកឡើងវិញថា "ដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគីស្នូលនៃកិច្ចដំណើរការនីតិវិធី ហើយតុលាការគប្បីធានាថា សិទ្ធិរបស់ពួកគាត់ត្រូវបានគោរព"[32]។

26. ក្នុងចំណោមសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ដើមបណ្តឹងរដ្ឋប្បវេណី គឺសិទ្ធិទទួលបានការតំណាងតាមផ្លូវច្បាប់[33]។ សិទ្ធិនេះរួមបញ្ចូលទាំងលក្ខខណ្ឌតម្រូវ ដែលថាការតំណាងបែបនេះមានប្រសិទ្ធភាព [34]។

27. ការតំណាងដោយប្រសិទ្ធភាព ទាមទារឱ្យមានធនធានគ្រប់គ្រាន់ដើម្បីអនុវត្តការងារសំខាន់ៗ និងបំពេញនូវកាតព្វកិច្ចវិជ្ជាជីវៈ។ ផលប៉ះពាល់នៃការសម្រេចរបស់ការិយាល័យរដ្ឋបាល គឺបន្ថយពីមនុស្សពីរនាក់ទៅមួយនាក់ នៅក្នុងក្រុមសហមេធាវីអន្តរជាតិនាំមុខ ដោយដកសមាជិកស្នូល ដែលជាអ្នកបានបំពេញការងារជូនក្រុមតាំងពីដំណាក់កាលជំនុំជម្រះក្តី និងនីតិវិធីសំណងមក។ តាមហេតុផលដែលបានពន្យល់ខាងក្រោម ការកាត់បន្ថយធនធានមនុស្សនេះ នឹងធ្វើឱ្យមិនអាចទៅរួចឡើយសម្រាប់សហមេធាវីនាំមុខ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការអនុវត្តការងារសំខាន់ៗទាំង

---

[31] ឯកសារ **F26/2/2** សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលារបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សួរដេញដោលសាក្សី SCW-5 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ កថាខណ្ឌ ៧។

[32] ឯកសារ **F65** សេចក្តីសម្រេចលើសំណើសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំការពន្យារពេលសវនាការលើ បណ្តឹងសាទុក្ខ និងសេចក្តីបង្គាប់ពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ កថាខណ្ឌ ៥១។

[33] **សំណុំរឿង ០០១**-ឯកសារ **F28** សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៤៨៨-៤៨៩។

[34] សូមមើលឧទាហរណ៍ ៖ តុលាការសិទ្ធិមនុស្សអឺរ៉ុប *រឿងក្តី Artico តទល់នឹង អ៊ីតាលី* សំណុំរឿងលេខ ៦៦៩៤/៧៤ សាលក្រម ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៨០ កថាខណ្ឌ ៣៣ (អត្ថបទដកស្រង់ពីសំណុំរឿងក្នុងឯកសារ **F40/1.1.1.5**)។ "តំណាងប្រកបដោយប្រសិទ្ធភាព" ក៏ជាស្តង់ដារដែលត្រូវបានប្រើនៅក្នុងគម្រោងជំនួយផ្នែកច្បាប់របស់មេធាវីការពារក្តីផងដែរ។ សូមមើល ឧបសម្ព័ន្ធ ជ ៖ គម្រោងជំនួយផ្នែកច្បាប់នៅ អ.វ.ត.ក (ធ្វើវិសោធនកម្មក្នុងខែធ្នូ ឆ្នាំ២០១៤) កថាខណ្ឌ ឃ(១) និងច(១៤)។ សូមមើលផងដែរ កថាខណ្ឌ ង(១) ដែលសំដៅទៅលើ "ការការពារក្តីប្រកបដោយប្រសិទ្ធភាព"។ នៅក្នុងបរិបទនៃ សេចក្តីសម្រេចរបស់ចៅក្រមរដ្ឋបាលនាពេលថ្មីៗនេះ ការិយាល័យរដ្ឋបាល (អង្គភាពគាំពារការការពារក្តី) ហាក់ដូចជាទទួលស្គាល់ថា ការទទួលខុសត្រូវរបស់ខ្លួននៅក្នុងបរិបទនៃការផ្តល់ធនធាន គឺដើម្បីធានាឱ្យមានការតំណាងប្រកបដោយប្រសិទ្ធភាពយ៉ាងហោចណាស់នៅផ្នែកការពារក្តី ៖ សូមមើលចៅក្រមរដ្ឋបាលអង្គការសហប្រជាជាតិ សំណុំរឿងលេខ UNAKRT/UNAJ/SCC/2019/1 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់សហមេធាវីការពារក្តី ខៀវ សំផន នៃសេចក្តីសម្រេចរបស់អង្គភាពគាំពារការការពារក្តី ដែលបដិសេធការជ្រើសរើសទីប្រឹក្សាផ្នែកច្បាប់អន្តរជាតិ (កម្រិត ៣) ចូលជាធរមានចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ៨៥។

អស់ដែលចាំបាច់សម្រាប់ការតំណាងដោយប្រសិទ្ធភាពតាំងពីមុន និងក្រោយពេលដែលសាលដីកាស្ដាពរចេញ រួមមានការងារសម្របសម្រួលជាមួយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ធានាឱ្យមានការប្រជុំជាមួយដើមបណ្ដឹងរដ្ឋប្បវេណី និងតាមដានព័ត៌មានដែលជាលទ្ធផលពីការប្រជុំ ហើយអនុវត្តការងារដាក់សារណាសំខាន់ៗ។

## ៦. កំហុសឆ្គងផ្នែកអង្គច្បាប់ក្នុងសេចក្ដីសម្រេចរបស់ការិយាល័យរដ្ឋបាល

28. ប្រព័ន្ធតែមួយគត់នៃ អ.វ.ត.ក សម្រាប់ការតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គឺត្រូវបានបង្កើតឡើងដោយវិធានផ្ទៃក្នុង ជាពិសេសវិធាន ១២ *ស្ទួនពីរ* និង វិធាន ២៣ (៣)។ ទំនាក់ទំនងរវាងសហមេធាវីនាំមុខ និងការិយាល័យរដ្ឋបាល គឺមានចែងនៅក្នុងវិធាន ១២ ។ សេចក្ដីសម្រេចរបស់ការិយាល័យរដ្ឋបាល មានការយល់ខុសទៅនឹងវិសាលភាព និងលក្ខណៈនៃប្រព័ន្ធនេះ នៅក្នុង បីប្រការ។ ការដាក់ជូនចំណុចខាងក្រោមនេះ ពន្យល់អំពីកំហុសឆ្គងនីមួយៗ និងពីរបៀបដែលកំហុសឆ្គងទាំងនោះធ្វើឱ្យអន្តរាយដល់សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការតំណាងដោយប្រសិទ្ធភាព និងការជំនុំជម្រះក្ដីដោយយុត្តិធម៌។

### ក. ទំនាក់ទំនងរវាងសហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

29. ការិយាល័យរដ្ឋបាលហាក់ទទួលស្គាល់ថា សហមេធាវីនាំមុខ មានកិច្ចការជាច្រើនដែលត្រូវធ្វើ[35] ប៉ុន្តែប្រកាន់គោលជំហរថា ទីប្រឹក្សាអន្តរជាតិគឺមិនចាំបាច់នោះទេ ព្រោះអាចពឹងពាក់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបាន។ ដូច្នេះ ជាឧទាហរណ៍ ការិយាល័យរដ្ឋបាលលើកឡើងថា “យោងតាមកំណត់ត្រារបស់យើង សហមេធាវីនាំមុខត្រូវបានគាំទ្រដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ១៨ នាក់ ដែល ៩ នាក់ជាមេធាវីបរទេស”[36] និងសួរថា “ហេតុអ្វីក្រុមមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះ...មិនអាចផ្ដល់សេវាគាំទ្របានគ្រប់គ្រាន់”[37]។

---

[35] តម្រូវការរៀបចំដាក់ឯកសារស្ដីពីការចាត់ចំណាត់ថ្នាក់ឡើងវិញ និងការអនុវត្តសំណង និងតម្រូវការរៀបចំ និងត្រួតពិនិត្យដំណើរការនៃកិច្ចប្រជុំជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ហាក់ដូចជាត្រូវបានទទួលយក ៖ ឧបសម្ព័ន្ធ ង៖ សារអេឡិចត្រូនិចឆ្លើយឆ្លងរវាងការិយាល័យរដ្ឋបាល និងសហមេធាវីអន្តរជាតិនាំមុខ ទំព័រ ៣-៤ (សារអេឡិចត្រូនិចពីការិយាល័យរដ្ឋបាល ផ្ញើជូនសហមេធាវីអន្តរជាតិនាំមុខ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០២១)។

[36] ឧបសម្ព័ន្ធ ឆ ៖ អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៨។

[37] ឧបសម្ព័ន្ធ ឆ ៖ អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៩។

30. ក្នុងអនុស្សរណៈទីពីររបស់ខ្លួន សហមេធាវីអន្តរជាតិនាំមុខបានពន្យល់ពីភាពខុសគ្នារវាងការផ្ទេរការងារឱ្យទីប្រឹក្សា និងការស្វែងរកធាតុចូលពីមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ១២*ស្ទួនពីរ* (៦) នៃវិធានផ្ទៃក្នុង[38]៖

> ទំនាក់ទំនងរបស់ខ្ញុំជាមួយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដូចមានចែងក្នុងវិធានផ្ទៃក្នុង មិនមែនជាការចាត់តាំងនោះទេ។ ខ្ញុំអាចមិនដាក់កិច្ចការឱ្យពួកគេ ហើយពួកគេមិនមានភារៈទទួលខុសត្រូវចំពោះរូបខ្ញុំឡើយ។ នេះជាទំនាក់ទំនងមួយដែលខុសប្លែកពីទំនាក់ទំនងរបស់ខ្ញុំជាមួយទីប្រឹក្សាដែលធ្វើការក្នុងផ្នែកនេះ ព្រោះថា ទីប្រឹក្សាទាំងនោះត្រូវទទួលខុសត្រូវចំពោះរូបខ្ញុំ លើការងាររបស់ពួកគេ។

31. ទទ្បីករណ៍នេះ ហាក់មិនត្រូវបានពិចារណាដិតដល់ដោយការិយាល័យរដ្ឋបាលនោះទេ។ ការិយាល័យរដ្ឋបាលឆ្លើយតបថា "ផ្ទុយពីការលើកឡើងរបស់អ្នក ដែលថា វិធានផ្ទៃក្នុងមិនផ្ដល់តួនាទីឱ្យសហមេធាវីនាំមុខ ចាត់តាំងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី វិធាន ១២*ស្ទួនពីរ* (៦) នៃវិធានផ្ទៃក្នុងតម្រូវឱ្យសហមេធាវីនាំមុខ "*សម្របសម្រួល*សកម្មភាពរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងទម្រង់ជា [...] ការគាំទ្រ" [ការគូសបញ្ជាក់ប្រភពដើម][39]។ ដូច្នេះ ការិយាល័យរដ្ឋបាលចង់មានន័យថា ការសម្របសម្រួលគឺស្មើនឹងការត្រួតត្រា។ នេះជាការយល់ច្រឡំចំពោះទំនាក់ទំនងរវាងសហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

32. សហមេធាវីនាំមុខមិនបានត្រួតត្រា ឬបង្គាប់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីឡើយ។ វិធាន ១២*ស្ទួនពីរ* (៦) នៃវិធានផ្ទៃក្នុង ចែងថា ការគាំទ្រ ត្រូវ "មានការព្រមព្រៀងគ្នា"។

33. ចំណុចនេះមានន័យថា សហមេធាវីនាំមុខមិនអាចបង្គាប់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីឱ្យធ្វើសកម្មភាពមួយ ដូចជា ការរៀបចំសេចក្ដីព្រាង ឬការស្វែងរកឯកសារក្នុង Zylab បានឡើយ។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអាចយល់ព្រមជួយ នៅពេលពួកគេទំនេរ ប៉ុន្តែចំណុចនេះគឺខុសគ្នាពីការមានសមាជិកក្រុមម្នាក់ ដែលមានកាតព្វកិច្ចធ្វើការងារទៅតាមការតម្រូវ។ ក្នុងការអនុវត្ត សហមេធាវីនាំមុខសម្របសម្រួលជាមួយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីស្វែងរកការព្រមព្រៀងទៅលើការដាក់សារណា។ សហមេធាវីនាំមុខ ក៏ចូលរួមរៀបអង្គាសថវិកា និងសម្របសម្រួលជាមួយអង្គភាពគាំពារជនរងគ្រោះដើម្បីរៀបចំការប្រជុំដើមបណ្តឹងរដ្ឋប្បវេណី ដែលស្មើ

[38] ឧបសម្ព័ន្ធ ឃ ៖ អនុស្សរណៈទីពីររបស់សហមេធាវីអន្តរជាតិនាំមុខ កថាខណ្ឌ ៣១។

[39] ឧបសម្ព័ន្ធ ឆ ៖ អនុស្សារណៈទីពីររបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ១០។

តែការប្រជុំទាំងអស់ត្រូវបានអនុវត្តដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយមានកាផ្តល់ជូននូវសារគន្លឹះៗ និងបណ្តុំនៃមតិយោបល់ និងការណែនាំពីសហមេធាវីនាំមុខ។ តួនាទីដែលអនុវត្តដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានលក្ខណៈសំខាន់ចំពោះការបំពេញមុខងារតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែវាមិនដូចគ្នាទៅនឹងតួនាទីដែលអនុវត្តដោយទីប្រឹក្សាច្បាប់អន្តរជាតិនៅក្នុងក្រុមការងាររបស់សហមេធាវីនាំមុខនោះឡើយ។

34. ក្រៅពីនេះ មានហេតុផលច្បាស់លាស់ដែលបញ្ជាក់ថាតើហេតុអ្វីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ (ឬសមាជិកក្រុមម្នាក់) មិនអាចដើរតួនាទីសមមូលនឹងទីប្រឹក្សាបាន។ ការជួយជ្រោមជ្រែងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ១២*ស្ទួនពីរ* (៦)នៃវិធានផ្ទៃក្នុង ជាការបម្រើឱ្យផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ តាមន័យជាក់ស្តែង មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចលើកឡើងនូវវិធីសាស្ត្រមួយស្តីពីការដាក់ឯកសារ ឬគោលជំហរ ឬបង្ហាញទស្សនៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះបញ្ហាណាមួយ។ ទោះជាយ៉ាងណា គោលជំហរនោះពាក់ព័ន្ធនឹងកូនក្តីជាក់លាក់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ ទោះបីជាបុគ្គលម្នាក់ក្នុងក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីណាមួយ អាច និងមាន ឆន្ទៈជួយជ្រោមជ្រែងជាប្រចាំលើកិច្ចការរបស់សហមេធាវីនាំមុខក៏ដោយ ក៏បញ្ហាគឺថាតើចំណុចនេះនឹងធ្វើឱ្យសហមេធាវីនាំមុខ ងាកទៅរកគោលជំហររបស់អនុក្រុមណាមួយនៃដើមបណ្តឹងរដ្ឋប្បវេណី ឬទេ។ វិធីសាស្ត្រដ៏យុត្តិធម៌មួយ គឺការតម្រូវឱ្យមានការបែងចែកស្មើគ្នានូវចំនួនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីឱ្យបំពេញតួនាទីនេះ។ បញ្ហាប្រឈមជាក់ស្តែងក្នុងការគ្រប់គ្រងសេណារីយ៉ូនេះ រួមទាំងការផ្អែកតាមកត្តាជាក់ស្តែងដែលនឹងលើកមកបង្ហាញក្នុងកថាខណ្ឌខាងក្រោម មានទំហំធំធេង។

35. តាមពិត ការិយាល័យរដ្ឋបាលមើលរំលងចំណុចដែលកិច្ចការសម្របសម្រួលមិនជួយសន្សំពេលវេលាដូចការផ្ទេរកិច្ចការ។ ផ្ទុយទៅវិញ ការសម្របសម្រួល*ទាមទារ* ពេលវេលា។ ការស្វែងរក ទស្សនៈយល់ឃើញរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជាសកម្មភាពមួយដែលចំណាយពេលវេលារបស់សហមេធាវីនាំមុខ។ កិច្ចការនេះទាមទារការរៀបចំឯកសារ និងទំនាក់ទំនងដើម្បីពន្យល់ពីវិធីសាស្ត្រដែលស្នើឡើង ការឆ្លើយឆ្លងមតិយោបល់តាមអ៊ីមែល និងការផ្ញើសារ ការសម្របសម្រួលតាមល្វែងម៉ោង និងមានបុគ្គលិកពហុភាសាដើម្បីរៀបចំកិច្ចប្រជុំអនឡាញ ដែលជាញឹកញាប់ អ្នកចូលរួមមានការលំបាកក្នុងការបកប្រែ និងកិច្ចពិភាក្សាផ្ទៃក្នុងជាបន្តបន្ទាប់ស្តីពីរបៀបដោះស្រាយការខ្វែងយោបល់គ្នា។ ច្បាស់ណាស់ថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់មិន

អាចបំពេញការងារសម្របសម្រួលបែបអព្យាក្រឹតនេះបានឡើយ។ ប៉ុន្តែចំណុចសំខាន់គឺ វិធីសាស្ត្រដែលស្នើឡើងដោយការិយាល័យរដ្ឋបាល ដែលថាការងារស្នូលរបស់សហមេធាវីនាំមុខត្រូវបានបំពេញដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងតម្រូវឱ្យការសម្របសម្រួលយ៉ាងច្រើនអនេក។ វិធីសាស្ត្រនេះមិនបានជួយសម្រាលបន្ទុកការងារយ៉ាងច្រើនរបស់សហមេធាវីនាំមុខនោះទេ ប៉ុន្តែវាបានបន្ថែមបន្ទុកការងារទៅវិញ។

36. សហមេធាវីអន្តរជាតិនាំមុខ ក៏បានផ្តល់ជូនការិយាល័យរដ្ឋបាលនូវហេតុផលជាក់ស្តែងបន្ថែមទៀតពីអ្វីដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនស្ថិតក្នុងតួនាទីដែលត្រូវបានអនុវត្តក្នុងពេលបច្ចុប្បន្នដោយទីប្រឹក្សាអន្តរជាតិ រួមទាំងការខ្វះខាតធនធានរបស់ពួកគេ[40]។ អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល ទាត់ចោលការពិចារណាជាក់ស្តែងទាំងនេះដោយសារវាមិនពាក់ព័ន្ធ។ ការិយាល័យរដ្ឋបាលបានចោទសួរសំណួរ ថាតើមាន "*អសមត្ថភាព*ដែលមិនអាចគ្រប់គ្រងបានក្នុងការផ្តល់សេវាគាំទ្រ[41]" មែនទេ ហើយលើកឡើងថា "កម្រិតនៃការផ្តល់ថវិការបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺមិនពាក់ព័ន្ធទៅនឹងការវាយតម្លៃតួនាទីរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលកំណត់ក្នុងវិធាននៃផ្ទៃក្នុង ៖ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលខុសត្រូវដូចគ្នាចំពោះអង្គជំនុំជម្រះវិសាមញ្ញ និងកូនក្តីរបស់ពួកគេដោយមិនគិតពីកម្រិតនៃប្រាក់ឈ្នួលរបស់ពួកគេឡើយ[42]"។

37. វិធីសាស្ត្រដែលបានបង្ហាញក្នុងអំណះអំណាងទាំងនេះគឺជាការនិម្មិត។ វិធីសាស្ត្រនេះសន្មតថាដោយសារតែមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតែងតាំង គេអាចច្រានចោលតថភាពជាក់ស្តែង។ នោះជាវិធីសាស្ត្រដែលតុលាការសិទ្ធិមនុស្សបានបដិសេធចោលក្នុងការលើកឡើងថាសិទ្ធិទទួលបានភាពជាតំណាងស្របច្បាប់ ត្រូវតែមានប្រសិទ្ធភាព និងមិនមែនត្រឹមតែជាទ្រឹស្តីនោះទេ។ ក្នុងរឿងក្តី *Artico តទល់នឹង អ៊ីតាលី* អ៊ីតាលីលើកឡើងថា ការតែងតាំងមេធាវីការពារក្តីម្នាក់បានកំណត់ពីកាតព្វកិច្ចរបស់មេធាវីនោះ។ តុលាការសិទ្ធិមនុស្សអឺរ៉ុប បានពន្យល់ថា ៖

> ...[អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស] គ្មានគោលបំណងធានាសិទ្ធិដែលជាទ្រឹស្តី ឬជាការបំភាន់នោះទេ ប៉ុន្តែមានគោលបំណងធានាសិទ្ធិដែលជាក់ស្តែង និងមានប្រសិទ្ធភាព។ នេះជាការពិតសម្រាប់

---

[40] ឧបសម្ព័ន្ធ ឃ៖ អនុស្សរណៈទីពីររបស់សហមេធាវីអន្តរជាតិនាំមុខ កថាខណ្ឌ ៣២-៣៤ ។

[41] ឧបសម្ព័ន្ធ ឆ៖ អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ១០ ។

[42] ឧបសម្ព័ន្ធ ឆ៖ អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ១១ ។

សិទ្ធិរបស់មេធាវីការពារក្តី ផ្អែកតាមគោលការណ៍ដ៏សំខាន់ក្នុងសង្គមប្រជាធិបតេយ្យមួយ តាម រយៈសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលពួកគេទទួលបាន...។ ដូចអ្វីដែលប្រតិភូរបស់គណៈកម្មការនេះបានគូសបញ្ជាក់យ៉ាងត្រឹមត្រូវ មាត្រា ៦ កថាខណ្ឌ ៣ (មាត្រា ៦-៣-គ) លើកឡើងពី "ជំនួយ" មិនមែន "ការតែងតាំង" នោះទេ។ ជាថ្មីម្តងទៀត ការតែងតាំងមិនធានានូវជំនួយដែលមានប្រសិទ្ធភាពឡើយ ព្រោះមេធាវីដែលត្រូវបានតែងតាំងឱ្យផ្តល់ជំនួយផ្លូវច្បាប់ អាចទទួលមរណភាព ឈឺធ្ងន់ ត្រូវបានរារាំងក្នុងរយៈពេលយូរមិនឱ្យបំពេញតួនាទី ឬគេចវេសពីភារកិច្ចរបស់ខ្លួន។ ប្រសិនបើត្រូវបានជូនដំណឹងអំពីស្ថានភាពនេះ អាជ្ញាធរត្រូវផ្លាស់ប្តូរមេធាវីថ្មី ឬជំរុញឱ្យមេធាវីនោះបំពេញកាតព្វកិច្ចរបស់ខ្លួន។ ការអនុវត្តការបកស្រាយបែបរឹតត្បិតរបស់ រដ្ឋាភិបាល នឹងនាំទៅរកលទ្ធផលដែលមិនសមហេតុផល និងមិនស៊ីសង្វាក់គ្នានឹងខ្លឹមសារក្នុងកថាខណ្ឌរង (គ) (មាត្រា ៦-៣-គ) និងរចនាសម្ព័ន្ធនៃមាត្រា ៦ (មាត្រា ៦) ទាំងមូល។ ក្នុងករណីជាច្រើន ជំនួយផ្លូវច្បាប់ដោយមិនយកប្រាក់កម្រៃអាចប្រែជាអសារបង់ទៅវិញ[43]។

38. ដូច្នេះ ការិយាល័យរដ្ឋបាលមានការយល់ច្រឡំក្នុងផ្នែកជាច្រើនពាក់ព័ន្ធនឹងតួនាទីរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ទីមួយ ការិយាល័យរដ្ឋបាលភាន់ច្រឡំក្នុងការអះអាងថា សហមេធាវីនាំមុខមានអំណាច*ក្នុងផ្លូវច្បាប់* ក្នុងការតម្រូវឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើការងារឱ្យសហមេធាវីនាំមុខ។ ទីពីរ ការិយាល័យរដ្ឋបាលបានប្រព្រឹត្តកំហុសក្នុងការច្រានចោល*កត្តាជាក់ស្តែង* ពាក់ព័ន្ធដែលបង្ហាញថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនអាចដើរតួនាទីដូចទីប្រឹក្សាអន្តរជាតិក្នុងក្រុមរបស់សហមេធាវីនាំមុខ និងថា ការប៉ុនប៉ងពឹងផ្អែកលើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងបន្ថែមបន្ទុកការងារ និងប្រើប្រាស់ធនធានយ៉ាងច្រើនរបស់ក្រុមសហមេធាវីនាំមុខ។

## ខ. ព្រំដែនកំណត់នៃអាណត្តិ ឬការផ្តល់ធនធានដែលពាក់ព័ន្ធនឹងការណែនាំផ្នែកតុលាការ

39. សេចក្តីសម្រេចរបស់ការិយាល័យរដ្ឋបាលចាត់ទុកថា កិច្ចការមួយចំនួនស្ថិតនៅក្រៅអាណត្តិរបស់សហមេធាវីនាំមុខ (ឬយ៉ាងហោចណាស់ មិនត្រូវទទួលបានធនធាន[44]) ព្រោះកិច្ចការទាំងនេះមិន

---

[43] តុលាការសិទ្ធិមនុស្សអឺរ៉ុប *រឿងក្តី Artico តទល់នឹង អ៊ីតាលី* សំណុំរឿងលេខ ៦៦៩៤/៧៤ សាលក្រម ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៨០ កថាខណ្ឌ ៣៣ (អត្ថបទដកស្រង់ពីសំណុំរឿង ក្នុងឯកសារ **F40/1.1.1.5**)។

[44] មិនច្បាស់ ១០០% នោះទេថាតើការិយាល័យរដ្ឋបាលប្រកាន់យកជម្រើសមួយណា។ អនុស្សរណៈទីមួយរបស់ការិយាល័យរដ្ឋបាលចាត់ទុកថា ការងារធ្វើចំណាត់ប្រភេទឯកសារឡើងវិញស្ថិតក្នុងអាណត្តិរបស់សហមេធាវីនាំមុខ (កថាខណ្ឌ ៦) ប៉ុន្តែអនុ

ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីតុលាការ ឬសេចក្ដីណែនាំជាក់លាក់។ ចំណុចនេះស្ដែងឡើងតាមពីរវិធីផ្សេងៗគ្នា ៖

(១) មានការលើកឡើងថា មិនគួរផ្ដល់ធនធានសម្រាប់កិច្ចការដែល "ផ្ដួចផ្ដើមឡើងដោយខ្លួនឯង ឬមានលក្ខណៈបន្តជាប់ និងគ្មានកាលបរិច្ឆេទកំណត់ផ្នែកតុលាការ"[45] និង

(២) ទីពីរ តួនាទីរបស់សហមេធាវីនាំមុខត្រូវបានលើកឡើងថា "កម្រិតត្រឹមការអនុវត្តកិច្ចដំណើរការនីតិវិធី" ក្រោមការត្រួតពិនិត្យដោយអង្គជំនុំជម្រះពាក់ព័ន្ធ[46]" ឬ "កម្រិតត្រឹមការងារតុលាការជាក់ស្ដែង"[47]។

## *១) ការងារ "ដែលផ្ដួចផ្ដើមឡើងដោយខ្លួនឯង"*

40. ការិយាល័យរដ្ឋបាលទំនងជាយល់ឃើញថា ការិយាល័យរដ្ឋបាលមិនគួរផ្ដល់ធនធានសម្រាប់ការងារដែលមិនត្រូវបានបង្គាប់យ៉ាងច្បាស់លាស់ និងជាក់លាក់ដោយអង្គជំនុំជម្រះ (ឬត្រូវបានតម្រូវតាមការសន្មត ជាក់លាក់ និងច្បាស់លាស់ដោយវិធានផ្ទៃក្នុងណាមួយ ជាជាងវិធាន ១២*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង)[48]។ ពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ការិយាល័យរដ្ឋបាលលើកឡើងថា "ការិយាល័យរដ្ឋបាលមិនទទួលបានការជូនដំណឹងពីអង្គជំនុំជម្រះតុលាការកំពូលស្ដីពីការងារដែលត្រូវបានស្នើឡើងដោយភាគី នៅពេលនេះទេ"[49]។

41. គោលជំហរនេះគឺគ្មានមូលដ្ឋានផ្លូវច្បាប់នោះទេ និងធ្វើឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងលើផលវិបាករបស់វា។ គោលជំហរនេះបញ្ជាក់ថា ធនធាននឹងមិនត្រូវបានប្រើប្រាស់ក្នុងបណ្ដឹងដែលផ្ដួចផ្ដើមឡើងដោយភាគីមួយនៅពេលដែលភាគីនោះយល់ថាចាំបាច់។ ចំណុចនេះផ្ទុយស្រឡះពីការ អនុវត្តនាពេលបច្ចុប្បន្ន។ម្យ៉ាងវិញទៀត គោលជំហរនេះរឹតត្បិតយ៉ាងខ្លាំងលើលទ្ធភាពរបស់មេធាវីក្នុងការផ្ដល់ភាពជាតំណាងប្រកបដោយប្រសិទ្ធភាព។

---

ស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល លើកឡើងថាមិនធានាការផ្ដល់ធនធាននោះទេ មួយផ្នែកដោយសារតែវាជា "ការផ្ដួច ផ្ដើមឡើងដោយខ្លួនឯង" និងមិនត្រូវបាន "ស្នើសុំពីភាគីដោយអង្គជំនុំជម្រះតុលាការកំពូលនៅពេលនេះ" (កថាខណ្ឌ ១៥)។

[45] ឧបសម្ព័ន្ធ ឆ ៖ អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ១៥។

[46] ឧបសម្ព័ន្ធ ឆ ៖ អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ២៥។

[47] ឧបសម្ព័ន្ធ ឆ ៖ អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ២៦។

[48] ឧបសម្ព័ន្ធ ឆ ៖ អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ១៥។

[49] *ដូចដើងទំព័រខាងលើ*។

42. ក្នុងសាលាក្តីផ្សេងទៀត មានយន្តការសម្រាប់ការដកយកកម្រៃផ្តល់ជំនួយផ្នែកច្បាប់ ក្នុងករណីដែលអង្គជំនុំជម្រះមួយសម្រេចថា ការដាក់ឯកសារដែលផ្តួចផ្តើមឡើងដោយមេធាវីគឺ "ឥតបានការ" ឬ "ជាការរំលោភបំពានដំណើរការ"[50]។ អំណាចនោះជាការអនុញ្ញាត ដែលអនុវត្តដោយចៅក្រម និងត្រូវអនុវត្ត "ដោយប្រុងប្រយ័ត្ន"[51]។ អ្វីដែលការិយាល័យរដ្ឋបាលលើកឡើង គឺហួសពីអ្វីដែលលើកឡើងខាងលើ។ ការលើកឡើងនោះគឺ ការិយាល័យរដ្ឋបាលអាចដកយកធនធានក្នុងការដាក់ឯកសារ*ណាមួយ* (ឬការងារផ្សេងទៀត) ដែលផ្តួចផ្តើមឡើងដោយមេធាវី។ វាជាការលំបាកក្នុងការប៉ាន់ប្រមាណថាតើមេធាវីម្នាក់អាចបំពេញកាតព្វកិច្ចផ្នែកក្រមសីលធម៌ ដើម្បីបម្រើផលប្រយោជន៍របស់កូនក្តីក្នុងកាលៈទេសៈទាំងនេះបានដែរ ឬទេ ព្រោះជាញឹកញាប់ ការធ្វើដូច្នេះទាមទារការលើកឡើងនូវបញ្ហាដែលអង្គជំនុំជម្រះមិនបានដឹង ដោយគ្មានការដាក់ឯកសារពីភាគី។ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ៖

> ...នេះជាកាតព្វកិច្ចរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការការពារអត្ថប្រយោជន៍ជនរងគ្រោះ និងទាញចំណាប់អារម្មណ៍របស់អង្គជំនុំជម្រះទៅលើការរំលោភបំពានណាមួយ ឬការធ្វើឱ្យប៉ះពាល់ដល់សិទ្ធិត្រឹមត្រូវតាមច្បាប់ទាំងនោះ[52]។

43. ក្រៅពីនេះ ដោយសារតែការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") មិនជាប់ជំពាក់នឹងបញ្ហានៃការផ្តល់ប្រាក់ឈ្នួលតាមម៉ោងដោយការិយាល័យរដ្ឋបាល វិធីសាស្ត្រនេះនឹងបង្កើតឱ្យមានអតុល្យភាពយ៉ាងខ្លាំងក្នុងកិច្ចដំណើរការនីតិវិធីនេះ។ វិធីសាស្ត្រនេះអាចធ្វើឱ្យមានការពន្យារពេល ប្រសិនបើភាគីរង់ចាំដីកាដាក់លាក់ មុននឹងលើកយកបញ្ហារបស់ខ្លួនដាក់ជូនអង្គជំនុំជម្រះ ទោះបីជាភាគីទាំងនោះដឹងថា កិច្ចការមួយចំនួនគឺជាការចាំបាច់ក៏ដោយ។

---

[50] សូមមើល ឧទាហរណ៍ វិធាន ៧៣ (ឃ) វិធានរបស់ ICTY ស្តីពីនីតិវិធី និងភស្តុតាង។ វិធាន ៧៣ (ច) វិធានរបស់ ICTR ស្តីពីនីតិវិធី និងភស្តុតាង។ វិធាន ១២៦ (ឆ) វិធានរបស់ STL ស្តីពីនីតិវិធី និងភស្តុតាង។ វិធាន ៤៦ (គ) វិធានរបស់ RSCSL ស្តីពីនីតិវិធី និងភស្តុតាង។

[51] ICTR *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kanyarukiga* សំណុំរឿងលេខ ICTR-2020-78-R11*ស្ទួន* សេចក្តីសម្រេចស្តីពីសំណើសុំឱ្យទទួលយក ភស្តុតាងបន្ថែម ថ្ងៃទី១ ខែសីហា ឆ្នាំ២០០៨ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ កថាខណ្ឌ ១២។

[52] **សំណុំរឿង ០០៤/០២-ឯកសារ E004/2/6** សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលចាត់វិធានការចាំបាច់ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទទួលបានតំណាងផ្លូវច្បាប់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០៤/០២ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ កថាខណ្ឌ ២៣។

44. សហមេធាវីនាំមុខ មិនបានដឹងពីមូលដ្ឋានផ្លូវច្បាប់ណាមួយនៅចំពោះមុខតុលាការនេះ ឬការអនុវត្តរបស់សាលាក្តីអន្តរជាតិមួយផ្សេងទៀតដែលគាំទ្រវិធីសាស្ត្រនេះឡើយ។

## *២) ការងារ "ក្រៅតុលាការ"*

45. លើសពីនេះ ការិយាល័យរដ្ឋបាលប្រកាន់គោលជំហរថា អាណត្តិរបស់សហមេធាវីនាំមុខ ត្រូវបានកំណត់ត្រឹមតែ "ការងាររបស់តុលាការ"[53]។ គោលជំហរនេះត្រូវបានលើកឡើងដើម្បីគាំទ្រសេចក្តីសម្រេចរបស់ខ្លួនក្នុងការមិនផ្តល់ធនធាន "ការងារដែលទាក់ទងនឹងគេហទំព័រ ការបិទបញ្ចប់/ការរក្សាទុកក្នុងបណ្ណសារ និង"កេរ្តិ៍ដំណែល" (រួមទាំងការឆ្លើយតបទៅនឹងសហអ្នកធ្វើរបាយការណ៍ស្តីពីជនរងគ្រោះ)" [54]។

46. តុលាការអនុវត្តការងាររបស់ខ្លួន មិនត្រឹមតែតាមរយៈការដាក់ឯកសារ ការបើកសវនាការ និងការចេញសេចក្តីសម្រេចរបស់តុលាការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសកម្មភាពដែលពាក់ព័ន្ធផងដែរ។ ការងារទាំងនេះរួមបញ្ចូលទាំងការផ្តល់ព័ត៌មានសាធារណៈ និងអ្វីដែលគេហៅថា ការគាំទ្រ "ក្រៅតុលាការ" សម្រាប់ជនរងគ្រោះ។ ទោះយ៉ាងណា ការញែកឱ្យដាច់ណាត់ពីគ្នារវាងសកម្មភាពរបស់តុលាការ និងសកម្មភាពក្រៅតុលាការ គឺជារឿងសិប្បនិម្មិត។ តុលាការ គឺជាស្ថាប័នជំនុំជម្រះក្តី។ ការបើកសវនាការ គឺជាការងារចាំបាច់ចំពោះអាណត្តិនោះ ប៉ុន្តែការងារផ្សព្វផ្សាយជាសាធារណៈស្តីពីសវនាការ និងលទ្ធផលនៃការជំនុំជម្រះក៏ចាំបាច់ផងដែរ។ ដូចគ្នានេះដែរ មុខងារផ្សេងទៀតដែលចាំបាច់សម្រាប់សវនាការ ការដាក់ឯកសារ និងការចេញសេចក្តីសម្រេច គឺពិបាកបំបែកចេញពីការងារនោះណាស់ ៖ ដំណើរការមូលដ្ឋានទិន្នន័យសំណុំរឿង ការគ្រប់គ្រងមន្ទីរឃុំឃាំង ឬការថែទាំអគារតុលាការ អាចត្រូវបានពិពណ៌នាក្នុងវិសាលភាពមួយថាជាការងារ "របស់តុលាការ" តាមរបៀបដែរការងារទាំងនោះត្រូវបានអនុវត្តដើម្បីឱ្យភាគី និងចៅក្រមធ្វើការដាក់សារណា និងចេញសេចក្តីសម្រេច។ ការងារទាំងអស់នេះត្រូវបានគេសន្មតថាចាំបាច់សម្រាប់ការអនុវត្តអាណត្តិរបស់តុលាការ បើមិនដូច្នោះទេពួកគាត់នឹងមិនទទួលបានប្រាក់កម្រៃឡើយ។

---

[53] ឧបសម្ព័ន្ធ ឆ ៖ អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ១៥, ២៥-២៦។ សូមមើលផងដែរ ឧបសម្ព័ន្ធ គ៖ អនុស្សរណៈទីមួយរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៤,៧។

[54] ឧបសម្ព័ន្ធ ង ៖ ការឆ្លើយឆ្លងអ៊ីមែលរវាងការិយាល័យរដ្ឋបាល និងសហមេធាវីអន្តរជាតិនាំមុខ ទំព័រ ៣-៤ (អ៊ីមែលពីការិយាល័យរដ្ឋបាលផ្ញើជូនសហមេធាវីអន្តរជាតិនាំមុខ ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១)។ សូមមើលផងដែរ ឧបសម្ព័ន្ធ ឆ ៖ អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ២៤-២៧។

47. ទោះបីជាអាចញែកពីភាពខុសគ្នា រវាងកិច្ចការដែលទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងសកម្មភាព "របស់តុលាការ" និងសកម្មភាពផ្សេងទៀតក៏ដោយ ក៏សហមេធាវីនាំមុខ មិនទទួលយកថា អាណត្តិរបស់ខ្លួនត្រូវបានកំណត់ត្រឹមតែជាការងាររបស់តុលាការនោះដែរ។ នៅពេលសន្និដ្ឋានដោយសមហេតុផល វិធីសាស្ត្រនេះមានន័យថា សហមេធាវីនាំមុខ នឹងមិនត្រូវបានផ្តល់បៀវត្សរ៍សម្រាប់ពេលវេលាដែលបានប្រើក្នុងការទាក់ទងជាមួយអង្គភាពគាំពារជនរងគ្រោះ ("VSS") លើបញ្ហាដើមបណ្តឹងរដ្ឋប្បវេណី ឬដោះស្រាយបញ្ហារដ្ឋបាលជាមួយផ្នែកផ្សេងៗរបស់ការិយាល័យរដ្ឋបាល ដូចជា ផ្នែកកុំព្យូទ័រ សេវាកម្មទូទៅ ការធ្វើដំណើរ ធនធានមនុស្ស ឬសន្តិសុខ។

48. ផ្នែកមួយ ដែលត្រូវបានការិយាល័យរដ្ឋបាលកំណត់ថាជាការងារ "ក្រៅតុលាការ" ទាក់ទងនឹងមុខងារដែលនៅសេសសល់របស់តុលាការ និង "កេរ្តិ៍ដំណែល" ។ ជាឧទាហរណ៍ ការងាររបស់ការិយាល័យរដ្ឋបាល មានការជាប់ពាក់ព័ន្ធនឹងធាតុចូលក្នុងកិច្ចពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិសម្រាប់សេចក្តីព្រាងនៃកិច្ចព្រមព្រៀង ស្តីពីមុខងារដែលនៅសេសសល់ ដែលត្រូវបានអនុម័តដោយមហាសន្និបាតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ ("សេចក្តីព្រាងនៃកិច្ចព្រមព្រៀង")[55]។ ការងារនេះក៏ពាក់ព័ន្ធនឹងកិច្ចពិភាក្សាអំពីការថែទាំ និងការចូលពិនិត្យមើលបណ្ណសាររបស់ អ.វ.ត.ក។ ទាំងនេះគឺជាបញ្ហាផលប្រយោជន៍ដ៏សំខាន់របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ជាការពិត គម្រោងសំណងមួយនៃគម្រោងសំណងជាច្រើនក្នុងសំណុំរឿង ០០២/០២ ស្វែងរកការបង្កើនលទ្ធភាពទទួលបានសម្ភារៈ អ.វ.ត.ក ជាសាធារណៈ[56]។ ដើមបណ្តឹងរដ្ឋប្បវេណីក៏មានការចាប់អារម្មណ៍ច្បាស់លាស់ក្នុងការធានាថា មានប្រព័ន្ធដែលកំពុងដំណើរការដើម្បីការពារ និងទ្រទ្រង់សមិទ្ធផលរបស់តុលាការ ដែលជាចំណុចស្នូលនៃកិច្ចពិភាក្សាទាក់ទងនឹង "កេរ្តិ៍ដំណែល"។

---

55 សេចក្តីព្រាងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់ទោសក្រោមច្បាប់កម្ពុជានៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យស្តីពីការរៀបចំអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 75/257, A/RES/75/257 B, សេចក្តីសម្រេចដែលមហាសន្និបាតបានអនុម័តនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មុខងារបន្ទាប់បន្សំ។

56 ឯកសារ **E465** សាលក្រម កថាខណ្ឌ ៤៤២៩, ៤៤៦១ ("អង្គជំនុំជម្រះយល់ស្របជាមួយសហមេធាវីនាំមុខថា ការបំពេញចិត្តជាសំណងរួមបញ្ចូលទាំង "ការបញ្ជាក់ការពិត ការបង្ហាញការពិតពេញលេញ និងជាសាធារណៈ ការរំលឹក និងការគោរពដល់ជនរងគ្រោះ និងការដាក់បញ្ចូលការពិពណ៌នាដ៏ត្រឹមត្រូវអំពីឧក្រិដ្ឋកម្មទាំងឡាយទៅក្នុងសម្ភារអប់រំនៅគ្រប់កម្រិត"។ ឯកសារ **E457/6/2/1** បណ្តឹងទាមទារចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណងនៅក្នុងសំណុំរឿង ០០២/០២ ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ កថាខណ្ឌ ៤៧-៤៩។

49. នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ សហអ្នកធ្វើរបាយការណ៍ បានចេញផ្សាយការអំពាវនាវមួយសុំឱ្យចូលរួមផ្តល់គំនិត ពាក់ព័ន្ធនឹងមុខងារដែលនៅសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ[57]។ ការអំពាវនាវនោះបានពន្យល់ថា សហអ្នកធ្វើរបាយការណ៍ត្រូវបានស្នើដោយការិយាល័យរដ្ឋបាល ដើម្បីរាយការណ៍នៅត្រឹមថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២១។ សហអ្នកធ្វើរបាយការណ៍ បានអំពាវនាវស្នើសុំធាតុចូលសម្រាប់គោលបំណងបង្កើតរបាយការណ៍នោះ។ គំនិតផ្តួចផ្តើមនេះមានការពាក់ព័ន្ធខ្លាំងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី[58]។ ដើមបណ្តឹងរដ្ឋប្បវេណីមានចំណាប់អារម្មណ៍ពិសេសមួយចំនួនទៅលើវិធីដែលអនុវត្តមុខងារដែលសេសសល់របស់ អ.វ.ត.ក ពាក់ពាក់ព័ន្ធនឹងជនរងគ្រោះ។ ចំណាប់អារម្មណ៍ទាំងនេះរួមមានទាំងការធានាថា ចំណាត់ការដែលត្រូវបានធ្វើឡើង មិនរារាំងដល់តម្លៃរបស់គម្រោងផ្តល់សំណង និងការជំរុញឱ្យមានគំនិតផ្តួចផ្តើមនានា ដើម្បីបន្តធ្វើឱ្យគម្រោងផ្តល់សំណងដែលកំពុងដំណើរការមាននិរន្តរភាព (ដូចជាតួនាទីរបស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់)។ ដូចទៅនឹងជនរងគ្រោះទាំងអស់ដែរ ដើមបណ្តឹងរដ្ឋប្បវេណីចាប់អារម្មណ៍លើរបៀបដែលមុខងារដែលសេសសល់ណាមួយត្រូវបានធ្វើឡើង ដូចជាវិធីដែលគោរពតាមការចង់បានរបស់ពួកគេ និងសុខុមាលភាព និងភាពឯកជនរបស់ពួកគេ និងចំណាប់អារម្មណ៍ទៅលើការណ៍ដែលបញ្ហាទាំងនេះត្រូវបានគេទទួលដឹងឮ។ សហមេធាវីនាំមុខបានធ្វើសេចក្តីសន្និដ្ឋានផ្លូវការមួយទៅកាន់សហចៅក្រមរបាយការណ៍[59]។ ទោះជាយ៉ាងណា សេចក្តីសន្និដ្ឋាននោះអាចមានកម្រាស់តែពីរទំព័រ

---

[57] **ឧបសម្ព័ន្ធ ខ៖** ការអំពាវនាវឱ្យមានការចូលរួមចំណែកជាគំនិត មុខងារដែលនៅសេសសល់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពាក់ (.ក.ត.វ.អ) ព័ន្ធជនរងគ្រោះ។

[58] សហអ្នកធ្វើរបាយការណ៍លើកឡើងយ៉ាងច្បាស់ថា អាណត្តិរបស់ពួកគេមិនកំណត់ត្រឹមដើមបណ្តឹងរដ្ឋប្បវេណីឡើយ ប៉ុន្តែរួមបញ្ចូលទាំងជនរងគ្រោះទាំងអស់។ ទោះជាយ៉ាងណា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់គឺជាជនរងគ្រោះ បើទោះជាជនរងគ្រោះទាំងអស់មិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីក្តី។ សហចៅក្រមរបាយការណ៍ស្នើជាពិសេសសុំឱ្យមានការចូលរួមចំណែកនានា “ដោយពន្យល់ថា តើគំនិតផ្តួចផ្តើមដែលស្នើឡើងមានអត្ថន័យ និងជាជំនួយរយៈពេលវែងដោយរបៀបណាចំពោះដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះនៃរបបខ្មែរក្រហម និងសាធារណជនទូទៅ”) *(គូសបញ្ជាក់បន្ថែម)*។

[59] ឧបសម្ព័ន្ធ ឈ៖ សេចក្តីសន្និដ្ឋានរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (CPLCLS) ផ្ញើទៅកាន់សហចៅក្រមរបាយការណ៍អំពីមុខងារដែលសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១។

ប៉ុណ្ណោះ[60] ហើយមានធាតុចូលសំខាន់ផ្សេងទៀត ដែលមានការសង្ឃឹមថានឹងត្រូវបានផ្ដល់ជូនតាមរយៈមធ្យោបាយផ្សេងទៀត។

50. វាក៏ទំនងផងដែរថា ការចូលរួមរបស់សហមេធាវីនាំមុខក្នុងដំណើរការនេះមានតម្លៃចំពោះសហអ្នកធ្វើបាយការណ៍ (ហើយដូច្នេះក៏មានតម្លៃផងដែរចំពោះការិយាល័យរដ្ឋបាល)។ នៅក្នុងតុលាការ សហមេធាវីនាំមុខស្ថិតក្នុងចំណោមមនុស្ស ដែលមានចំណេះដឹងពិសេសពាក់ព័ន្ធនឹងប្រធានបទនេះ។ សហមេធាវីនាំមុខ មិនត្រឹមតែបានប្រមូលព័ត៌មានពីជនរងគ្រោះ (ដែលជាដើមបណ្ដឹងរដ្ឋប្បវេណី) អំពីគំនិតផ្ដួចផ្ដើមរបស់តុលាការ ដែលពួកគេនឹងផ្ដល់តម្លៃ សហមេធាវីនាំមុខ (ហើយជាពិសេសទីប្រឹក្សាអន្តរជាតិរបស់គេ) ថែមទាំងស្ថិតនៅចំណុចកណ្ដាលនៃដំណើរការសំណង និងមានការយល់ដឹងស៊ីជម្រៅអំពីដំណើរការនេះដែលអនុវត្តនៅទីនេះផងដែរ។

51. សកម្មភាព "ក្រៅតុលាការ" មួយផ្សេងទៀតរបស់ការិយាល័យរដ្ឋបាល គឺការផ្ដល់ព័ត៌មានជូនសាធារណៈជនអំពីតុលាការតាមរយៈគេហទំព័ររបស់តុលាការ។ គេហទំព័រនេះរួមមានព័ត៌មានទូទៅអំពី អ.វ.ត.ក ប៉ុន្តែក៏មានព័ត៌មានអំពីប្រធានបទជាក់លាក់ផងដែរ ដូចជាអំពីដើមបណ្ដឹងរដ្ឋប្បវេណីជាដើម។ ចាប់តាំងពីឆ្នាំ២០១៩ មក សហមេធាវីនាំមុខ បានរៀបចំផែនការធ្វើបច្ចុប្បន្នភាព និងធ្វើព័ត៌មាននេះឱ្យកាន់តែស៊ីជម្រៅ ដើម្បីឱ្យប្រជាជនស្វែងយល់អំពីតួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងអាចចូលមើលព័ត៌មានអំពីការចូលរួមចំណែករបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំពោះ អ.វ.ត.ក។

52. សហមេធាវីនាំមុខកត់សម្គាល់ថា ទាំងអស់នេះគឺជាសកម្មភាពរបស់ *អ.វ.ត.ក*។ ទាំងអស់នេះប៉ះពាល់ដោយផ្ទាល់ដល់ចំណាប់អារម្មណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹង អ.វ.ត.ក ។ ដូច្នេះ សហមេធាវីនាំមុខចាត់ទុកថា វាស្ថិតក្នុងអាណត្តិរបស់ខ្លួនក្នុងការចូលរួមជាមួយតុលាការពាក់ព័ន្ធនឹងបញ្ហាទាំងនេះ។ តួនាទីផ្ទុយ នឹងមានន័យថា វាមិនមែនជាផ្នែកមួយនៃការងាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការចូលរួមជាមួយសកម្មភាពរបស់ការិយាល័យរដ្ឋបាលណាមួយ ដែលមិនពាក់ព័ន្ធនឹងការដាក់ឯកសារ ឬសវនាការ ទោះបីជាសកម្មភាពរបស់ការិយាល័យរដ្ឋបាលប៉ះពាល់ដល់សិទ្ធិដែលមានសារៈសំខាន់របស់ភាគីក៏ដោយ។ សហមេធាវីនាំមុខ នឹងមិនត្រូវបានផ្ដល់ធនធាន និងផ្ដល់ប្រាក់ឈ្នួលសម្រាប់ចំណាត់ការនានាដូចជា៖ ការសម្របសម្រួលជាប្រចាំជាមួយអង្គភាពគាំពារ

[60] ឧបសម្ព័ន្ធ ខ៖ ការអំពាវនាវឱ្យមានការចូលរួមចំណែកជាគំនិត មុខងារដែលនៅសេសសល់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពាក់ (.ក.ត.វ.អ) ព័ន្ធជនរងគ្រោះ។ ("ការចូលរួមចំណែកគួររួមមាន៖ ទម្រង់រួមទូលាយ (២) មិនលើសពីពីរ) ទំព័រជាភាសាអង់គ្លេស និងឬ បី/ទំព័រជាភាសាខ្មែរ"...)។

ជនរងគ្រោះ ការកែតម្រូវការរាយការណ៍នៃសេចក្ដីថ្លែងការណ៍កិច្ចការសាធារណៈ[61] ការតស៊ូមតិពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសម្ភារៈ ឯកសារពាក់ព័ន្ធនឹងកូនក្ដីរបស់ពួកគេ (រួមទាំងលទ្ធភាពទទួលបានឯកសារពាក់ព័ន្ធនឹងកូនក្ដីរបស់ពួកគេ) និងការទាក់ទងគ្នាប្រចាំថ្ងៃជាមួយបុគ្គលិករបស់ការិយាល័យរដ្ឋបាលអំពីការិយាល័យ ឧបករណ៍បច្ចេកវិទ្យាព័ត៌មានវិទ្យា ការដឹកជញ្ជូន ។ល។

53. វិធីសាស្ត្របែបនេះ គឺសិប្បនិម្មិតយ៉ាងពិតប្រាកដ។ ភាគីចូលរួមជាប្រចាំក្នុងទិដ្ឋភាពនៃការងារ "ក្រៅតុលាការ" របស់ការិយាល័យរដ្ឋបាល។ ជាការពិត យើងត្រូវបាន *ការិយាល័យរដ្ឋបាល* ស្នើសុំឱ្យធ្វើបែបនេះ៖ ជាឧទាហរណ៍ តាមរយៈការចូលរួមក្នុងសន្និសីទសារព័ត៌មាន ឬការរួមចំណែកក្នុងការដាក់ស្នើថវិកា និងរបាយការណ៍ប្រចាំត្រីមាស។ ការិយាល័យរដ្ឋបាល បានស្វែងរកយ៉ាងពិតប្រាកដនូវធាតុចូលពីសហមេធាវីនាំមុខ (ក្នុងចំណោមអ្នកផ្សេងទៀត) ដើម្បីជួយធ្វើផែនទី ឯកសាររបស់ អ.វ.ត.ក សម្រាប់គោលបំណងកេរដំណែល[62]។ វិធីសាស្ត្រនោះពិតជាត្រឹមត្រូវ។ ជំហានជាក់លាក់ ដែលត្រូវអនុវត្តដោយការិយាល័យរដ្ឋបាល មានការពាក់ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណី ហើយពួកគាត់គួរត្រូវបានតំណាងលើបញ្ហាទាំងនោះ។

54. អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល ទាក់ទងនឹងភាពផ្ទុយគ្នាលើគោលជំហររបស់ខ្លួនតាមរយៈការញែកការងារដែលត្រូវបានស្នើឡើងដោយការិយាល័យរដ្ឋបាល ចេញពីការងារផ្សេងទៀត។ ការងារដែលការិយាល័យរដ្ឋបាលស្នើឡើង គឺទទួលបានបៀវត្សរ៍ ចំណែកការងារផ្សេងទៀត មិនទទួលបានបៀវត្សរ៍ឡើយ។ ការធ្វើបែបនេះមិនអើពើថា សារៈសំខាន់នៃការងាររបស់សហមេធាវីនាំមុខ គឺជាតំណាងផ្លូវច្បាប់ ហេតុដូច្នេះហើយការងារនេះផ្ដោតលើការលើកកម្ពស់នៃផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីជាជាងការងាររបស់ការិយាល័យរដ្ឋបាល។ ការងារត្រូវតែទទួលបានបៀវត្សរ៍ ដោយផ្អែកលើថាតើវាចាំបាច់ និងសមស្របសម្រាប់ការតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីប្រកបដោយប្រសិទ្ធភាពដែរឬទេ ដោយមិនគិតពីថាតើវាត្រូវបានស្នើឡើង ឬចាត់ទុកថាជាការចង់បានរបស់ការិយាល័យរដ្ឋបាល។ ប្រការនេះតម្រូវឱ្យមានដោយស្វ័យភាពរបស់សហ

---

[61] ជាចំណាត់ការមួយដែលត្រូវបានធ្វើឡើងនាពេលថ្មីៗនេះដោយសហព្រះរាជអាជ្ញាអន្តរជាតិ៖ ឧបសម្ព័ន្ធ ញ៖ សូមមើលសេចក្ដីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១។

[62] ឧបសម្ព័ន្ធ ដ ៖ អនុស្សរណៈពីការិយាល័យរដ្ឋបាល ការធ្វើផែនទីឯកសាររៀបចំក្នុងកិច្ចប្រជុំរបស់ អ.វ.ត.ក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩។

មេធាវីនាំមុខ ដែលមានចែងក្នុងវិធាន ១២ នៃវិធានផ្ទៃក្នុង និងដោយគោលការណ៍ទូទៅនៃឯករាជ្យភាពរបស់មេធាវី[63]។

55. សហមេធាវីនាំមុខកត់សម្គាល់ថា ការទទួលស្គាល់ថាសកម្មភាពជាក់លាក់ណាមួយស្ថិតនៅក្នុងអាណត្តិរបស់ខ្លួន មិននាំឱ្យមានការសន្និដ្ឋានថា សកម្មភាពបែបនេះត្រូវផ្តល់ប្រាក់កម្រៃដោយគ្មានដែនកំណត់នោះទេ។ ការិយាល័យរដ្ឋបាលនៅតែអាចកំណត់ពីទំហំការងារដែលចាំបាច់ និងសមស្របសម្រាប់ការធ្វើតំណាងប្រកបដោយប្រសិទ្ធភាព។ ទោះយ៉ាងណា ការិយាល័យរដ្ឋបាល អាចនឹងមិនបដិសេធនូវការផ្តល់ធនធានទាំងអស់សម្រាប់ការងារបែបនេះ ដោយកំណត់មិនត្រឹមត្រូវនូវអាណត្តិសហមេធាវីនាំមុខនោះឡើយ។

## គ. លក្ខណៈនៃកាតព្វកិច្ចក្រមសីលធម៌ និងទំនាក់ទំនងជាមួយការផ្តល់ធនធាន

56. ការិយាល័យរដ្ឋបាល ក៏ព្យាយាមបង្រួមវិសាលភាពនៃអាណត្តិរបស់សហមេធាវីនាំមុខដោយលើកហេតុផលថា (i) សហមេធាវីនាំមុខមិនមានជាប់ការតព្វកិច្ច មេធាវី-កូនក្តី ជាមួយដើមបណ្តឹងរដ្ឋប្បវេណីឡើយ (ii) ថ្វីបើសហមេធាវីនាំមុខជាប់ពាក់ព័ន្ធ អនុលោមតាមកាតព្វកិច្ចនេះ វាគឺជាការសម្រេចចិត្តឯកឯង ជាជាងអ្វីដែលមានភាពចាំបាច់ ហើយដូច្នេះមិនចាំបាច់តម្រូវឱ្យមានធនធានផ្តល់ដោយការិយាល័យរដ្ឋបាលឡើយ។ អំណះអំណាងទាំងពីរនេះ គឺខុសតែម្តង។

### *១) ទំនាក់ទំនងរបស់ មេធាវី-កូនក្តី កើតមានរវាងសហមេធាវីនាំមុខ និងដើមបណ្តឹងរដ្ឋប្បវេណី*

57. ការិយាល័យរដ្ឋបាលលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណីមិនមែនជាកូនក្តីរបស់សហមេធាវីនាំមុខ[64] ជាក់ស្តែង ដើម្បីប្រកាន់ជំហរថា សហមេធាវីនាំមុខ មិនមានកាតព្វកិច្ចសីលធម៌ចំពោះដើមបណ្តឹងរដ្ឋប្បវេណីនោះទេ[65]។ ចំណុចនេះមានសារៈសំខាន់ ដោយសារគោលជំហររបស់ការិយាល័យ

[63] សូមមើលបន្ថែមនៅ មាត្រា ៥ នៃក្រមសីលធម៌វិជ្ជាជីវៈមេធាវីរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (ដកស្រង់នៅលើសំណុំឯកសារ **E314/5/1.1.1**) គោលការណ៍អន្តរជាតិស្តីពីក្រមវិជ្ជាជីវៈ គោលការណ៍ ១ [ឯកសារភ្ជាប់ ១] ។

[64] ឧបសម្ព័ន្ធ ធ៖ អនុស្សារណៈទីពីររបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ២២ បានបញ្ជាក់ថា “ការិយាល័យរដ្ឋបាលមិនទទួលយកគំនិតដែលថាដើមបណ្តឹងរដ្ឋប្បវេណី *ក៏ដូចជាតាំងពីចំណុចចាប់ផ្តើម* មិនមែនជាកូនក្តីរបស់សហមេធាវីនាំមុខឡើយ” [បញ្ជាក់ប្រភពច្បាប់ដើម] ។ សហមេធាវីនាំមុខមិនយល់ពីការយោងទៅពាក្យ “ចំណុចចាប់ផ្តើម” នោះទេ។

[65] ចំណុចត្រូវបានធ្វើឡើងនៅក្នុងការយោងទៅលើផ្នែកនៃអនុស្សារណៈទីពីររបស់សហមេធាវីអន្តរជាតិនាំមុខដែលនិយាយពីកាតព្វកិច្ចវិជ្ជាជីវៈដែលចងភ្ជាប់ទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីដោយសហមេធាវីនាំមុខ។ ឧបសម្ព័ន្ធ ធ៖ អនុស្សារណៈទីពីររបស់

រដ្ឋបាល គឺធ្លាប់ផ្ដល់ទឡ្ហីករណ៍ថា សកម្មភាពជាក់លាក់ទាំងឡាយមិនចាំបាច់ការងារផ្លូវច្បាប់ពីសហមេធាវីនាំមុខឡើយ ហើយដូច្នេះមិនត្រូវការមានធនធាននោះទេ។

58. គោលបំណងសម្រាប់ការតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក គឺមានលក្ខណៈដាច់ដោយឡែក (*sui generis*) និងត្រូវបានបង្កើតឡើងក្នុងអំឡុងពេលការងាររបស់តុលាការ។ ជាដំបូង ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានតំណាងដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតែមួយគត់។ សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំពោះការតំណាងផ្លូវច្បាប់ដោយប្រសិទ្ធភាព ត្រូវបានអនុវត្តតាមរយៈមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតែមួយគត់។ នៅក្នុងវិសោធនកម្មវិធានផ្ទៃក្នុងនៅខែ កុម្ភៈ ឆ្នាំ ២០១០ បានណែនាំអំពីប្រព័ន្ធបច្ចុប្បន្ននៃការតំណាងផ្លូវច្បាប់ពីរជាន់។ ការផ្លាស់ប្ដូរត្រូវបានលើកឡើង ដើម្បីឱ្យមានការលើកទឹកចិត្តដោយដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើននៅក្នុងសំណុំរឿង ០០២ និងតម្រូវការដើម្បីឱ្យ "មានប្រសិទ្ធភាព" នៃការចូលរួម[66]។

59. សំខាន់ វិសោធនកម្មទាំងនេះ ត្រូវបានបញ្ជាក់ជាពិសេសថាមានគោលបំណង "លើកកំពស់គុណភាពតំណាងដើមបណ្ដឹងរដ្ឋប្បវេណី"[67] ។ ដូច្នេះ វាត្រូវបានយល់ឃើញថា វិសោធនកម្មមិនបានបន្ថយសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការមានតំណាងផ្លូវច្បាប់ដោយប្រសិទ្ធភាពឡើយ។ វាចម្លែក ប្រសិនបើកិច្ចប្រជុំពេញអង្គបានស្វែងរកដើម្បី "ធ្វើឱ្យកាន់តែប្រសើរឡើង" ការតំណាងដោយណែនាំរចនាសម្ព័ន្ធឆ័ត្រនៃសហមេធាវីនាំមុខ *ដែលមិនជាប់កាតព្វកិច្ចសីលធម៌ដូចគ្នាចំពោះដើមបណ្ដឹងរដ្ឋប្បវេណី* នោះ។ ប្រសិនបើវាជាករណីបែបហ្នឹង ដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចពឹងផ្អែកលើករណីយុទ្ធសាស្ត្រ ការដាក់ឯកសារ និងការតស៊ូមតិដែលត្រូវបានអនុវត្តនៅក្នុងផលប្រយោជន៍ល្អបំផុតរបស់ពួកគេបានយូរទៀតនោះទេ ព្រមទាំងមេធាវីធ្វើការសម្រេចចិត្តក្នុងនាមពួកគេ ក៏មិនជាប់កាតព្វកិច្ចរក្សាការសម្ងាត់ដែរ។ ដើម្បីឱ្យមានតួនាទីក្នុងការសម្រេចចិត្តនៅក្នុងការតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានអនុវត្តដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលជាអ្នកមិនជាប់កាតព្វកិច្ចនេះ នឹងអន្តរាយខ្លាំងទៅលើសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំពោះការតំណាង

---

ការិយាល័យរដ្ឋបាល កថាខណ្ឌ ២២ និងជើងទំព័រលេខ ៥១ ដែលយោងទៅឧបសម្ព័ន្ធ ឃ៖ អនុស្សារណៈទីពីររបស់សហមេធាវីអន្តរជាតិនាំមុខ កថាខណ្ឌ ២, ៧-៩ និង៣០។

[66] ឧបសម្ព័ន្ធ ឈ៖ សេចក្ដីប្រកាសព័ត៌មានរបស់ អវតក អំពីកិច្ចប្រជុំពេញអង្គលើកទី៧ នៃការសេចក្ដីសន្និដ្ឋានរបស់ អវតក ចុះថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ២០១០។ សូមមើលផងដែរ សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១១០៩-១១១០។

[67] *ដូចជើងទំព័រខាងលើ*។

ដោយប្រសិទ្ធភាព។ វាក៏អន្តរាយដល់ "តុល្យភាពរវាងសិទ្ធិរបស់ភាគី" ផងដែរ នៅពេលដែលជនសង្ស័យ និងជនជាប់ចោទ ត្រូវបានទទួលសិទ្ធិនាំមុខដល់មេធាវីដែលចងភ្ជាប់ពួកគេតាមកាតព្វកិច្ចនេះ[68] ។

60. ដូច្នេះ សហមេធាវីនាំមុខពិចារណា ជាពិសេសនៅពេលបានអាននៅក្នុងខ្លឹមសារ ថា "ការតំណាងផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណី"[69] និង "ធានាឱ្យមានប្រសិទ្ធភាពអំពីការរៀបចំការតំណាងដើមបណ្តឹងរដ្ឋប្បវេណី"[70] នៅក្នុងវិធានផ្ទៃក្នុង សំដៅលើទំនាក់ទំនងនៃការតំណាងតាមផ្លូវច្បាប់រវាងសហមេធាវីនាំមុខ និងដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសាលាដំបូង ក៏បានប្រកាន់យកទស្សនៈដែលថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបាន*តំណាងដោយ*សហមេធាវីនាំមុខ[71] ។

61. ការសន្និដ្ឋាន ដែលសហមេធាវីនាំមុខមានទំនាក់ទំនងនៃការតំណាងផ្លូវច្បាប់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី ហើយចងភ្ជាប់ពួកគេនូវកាតព្វកិច្ចសីលធម៌ គឺមិនត្រូវបានប៉ះពាល់ដោយការពិតដែលថា ក្របខ័ណ្ឌច្បាប់របស់តុលាការ ក៏បានរួមបញ្ចូលតួនាទីសម្រាប់មេធាវីតំណាងដើមបណ្តឹរដ្ឋប្បវេណីផងដែរ។ ប្រព័ន្ធដែលបានបែងចែកការតំណាងតាមផ្លូវច្បាប់ គឺមិនត្រូវបានស្គាល់ឡើយ[72] ហើយនៅក្នុងប្រព័ន្ធទាំងនេះ មេធាវីទាំងពីរផ្នែក គឺត្រូវបានចូលរួមក្នុងការតំណាងតាមផ្លូវច្បាប់ជូនកូនក្តី ហើយក៏ជាប់កាតព្វកិច្ចវិជ្ជាជីវៈជាមួយកូនក្តីផងដែរ។

### *២) អនុលោមភាពជាមួយកាតព្វកិច្ចសីលធម៌តាមអាណត្តិ និងតាមផ្នែកនៃការតំណាងដោយប្រសិទ្ធភាព*

---

[68] វិធាន ២១ (១) (ក) នៃវិធានផ្ទៃក្នុង។

[69] វិធាន ១២ *ស្ទួនពីរ* (៥) (ក)។ សូមមើលផងដែរ វិធាន ២៣(៣) នៃវិធានផ្ទៃក្នុង។

[70] វិធាន ១២ *ស្ទួនពីរ* (១) នៃវិធានផ្ទៃក្នុង។

[71] ឯកសារ **E74** អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបុងទៅនឹងសំណើសុំលេខ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 ក្រោយកិច្ចប្រជុំរៀបចំសវនាការថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ២។

[72] សូមមើលឧទាហរណ៍ពីតួនាទីរបស់មេធាវីនៅក្នុងប្រព័ន្ធ អង់គ្លេ ដែលជាធម្មតាទទួលអំណាចដើម្បីធ្វើសកម្មភាពតាមរយៈមេធាវីដែលទទួលសិទ្ធិតំណាងដោយអាណត្តិជូនកូនក្តី។ ការបែងចែកតួនាទីនៅក្នុងការតំណាងផ្នែកច្បាប់នេះ មានច្រើននៅក្នុងយុត្តាធិរបស់រដ្ឋឯករាជ្យ រួមមាននៅចក្រភពអង់គ្លេស អៀកឡង់ អូស្ត្រាលី ញូហ្សីលែន អាហ្វ្រិកខាងត្បូង និងហុងកុង។

62. ការស្នើសុំធនធានរបស់សហមេធាវីអន្តរជាតិនាំមុខ បានប៉ាន់ប្រមាណទៅលើបន្ទុកការងារ ដោយពិចារណាលើសកម្មភាពដែលតម្រូវឱ្យធ្វើសម្រាប់ការអនុលោមតាមកាតព្វកិច្ចវិជ្ជាជីវៈ។ អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាលប្រកាន់គោលជំហរថា៖

> ប្រសិនបើសហមេធាវីអន្តរជាតិនាំមុខមានទស្សនៈថា ការងារមួយចំនួនមានភាពចាំបាច់ដោយសារកាតព្វកិច្ចវិជ្ជាជីវៈរបស់ពួកគេចំពោះការិយាល័យរបស់ខ្លួន ដើមបណ្តឹងរដ្ឋប្បវេណី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឬអង្គជំនុំជម្រះវិសាមញ្ញ ពួកគេធ្វើសកម្មភាពបែបនេះទៅតាមឆន្ទានុសិទ្ធិផ្ទាល់របស់ខ្លួន។ ទោះជាយ៉ាងណា *ការចំណាយ* លើសកម្មភាពបែបនេះមិនអាចធ្វើបានឡើយ ប្រសិនបើសកម្មភាពទាំងនេះមិនស្ថិតនៅក្នុងដែនកំណត់នៃការចាត់តាំងរបស់ពួកគេដូចដែលត្រូវបានកំណត់ដោយកិច្ចប្រជុំពេញអង្គ។ [ការគូសបញ្ជាក់ប្រភពដើម][73]

63. គោលជំហរនេះមិនអើពើនឹងចំណុចដែលថា កាតព្វកិច្ចក្រមសីលធម៌ជាច្រើនដែលលើកឡើងនេះ ក៏ជាផ្នែកជាក់លាក់មួយនៃក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក ផងដែរ។ ឧទាហរណ៍ត្រូវបានលើកឡើងដោយការិយាល័យរដ្ឋបាល គឺជាការយោងរបស់សហមេធាវីអន្តរជាតិនាំមុខអំពីកាតព្វកិច្ចនៃការរក្សាការសម្ងាត់[74]។ កាតព្វកិច្ចនោះក៏មានក្នុងវិធានផ្ទៃក្នុង ២២(៣) ផងដែរ ហើយដូចនេះ "ត្រូវបានចែងយ៉ាងច្បាស់ដោយកិច្ចប្រជុំពេញអង្គ"។

64. ប៉ុន្តែជាមូលដ្ឋាន សហមេធាវីនាំមុខមានក្តីបារម្ភដោយសារការយល់ខុសអំពីតួនាទីរបស់ពួកគេ។ ការបំពេញកាតព្វកិច្ចវិជ្ជាជីវៈទាំងអស់ ក្នុងនាមជាអ្នកតំណាងផ្នែកច្បាប់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី *គឺជា* ដែនកំណត់របស់សហមេធាវីនាំមុខ។ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានការតំណាងប្រកបដោយប្រសិទ្ធភាព នឹងក្លាយជាការបោកបញ្ឆោត ប្រសិនបើការធានាវិជ្ជាជីវៈមួយចំនួនដែលត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យការធ្វើជាតំណាងមានប្រសិទ្ធភាព មិនត្រូវបានចាត់ទុកថាជាផ្នែកមួយនៃការងាររបស់មេធាវីដែលតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

65. ដូច្នេះ កិច្ចការមួយចំនួន (ដូចជាការរៀបចំផែនការ ការរក្សាទុកឯកសារក្នុងបណ្ណសារ និងសកម្មភាពបិទបញ្ចប់ ដើម្បីធានាការសម្ងាត់នៃឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមគោលការណ៍បុព្វសិទ្ធិ ឬភាពសម្ងាត់វិជ្ជាជីវៈ) ស្ថិតក្នុងអាណត្តិនេះ ពីព្រោះកិច្ចការទាំងនេះមានភាព

---

[73] ឧបសម្ព័ន្ធ ឆ៖ អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ២៨។

[74] ឧបសម្ព័ន្ធ ឆ៖ អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល ជើងទំព័រ ៦២ ដែលសំដៅដល់ ឧបសម្ព័ន្ធ ឃ៖ អនុស្សរណៈទីពីររបស់សហមេធាវីនាំមុខអន្តរជាតិ កថាខណ្ឌ ២៤។

ចាំបាច់សម្រាប់ការតំណាងក្រុមសីលធម៌វិជ្ជាជីវៈប្រកបដោយប្រសិទ្ធភាព។ កិច្ចការទាំងនេះគឺជាកិច្ចការគ្រប់គ្រង និងការរក្សាទុកឯកសារ (ហើយដូច្នេះ ធានាបានការប្រគល់ជូនដ៏សមស្របនូវកំណត់ត្រាដែលធ្វើឡើងដោយសមាជិកក្រុមការងារដែលត្រូវចាកចេញពីតំណែង)។

## ឃ. ឥទ្ធិពលនៃកំហុសឆ្គងទាំងនេះទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី

66. កំហុសឆ្គងដែលបានបកស្រាយខាងលើ បានធ្វើឱ្យការិយាល័យរដ្ឋបាលកាត់បន្ថយបន្ទុកការងារដែលត្រូវបានអនុវត្តក្នុងនាមឱ្យដើមបណ្តឹងរដ្ឋប្បវេណី ខណៈដែលការប៉ាន់ស្មានលើធនធានដែលមានហួសពីការពិត (ដោយសន្មត់ថាសមត្ថភាពក្នុងការទាមទារ និងត្រួតពិនិត្យដែលផ្តល់ពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី)។ តាមរយៈនៃកំហុសឆ្គងទាំងនេះ ការិយាល័យរដ្ឋបាលបានសន្និដ្ឋានដោយមិនត្រឹមត្រូវថា បន្ទុកការងាររបស់សហមេធាវីនាំមុខ អាចត្រូវបានអនុវត្តជាមួយក្រុមដែលបានកាត់បន្ថយបាន ហើយដោយគ្មានការចងចាំដែលរក្សាទុករបស់ទីប្រឹក្សាអន្តរជាតិ។ នោះវាមិនជាករណីនោះទេ សម្រាប់មូលហេតុដែលត្រូវបានរៀបចំបន្ថែមដូចខាងក្រោម។

## ៦. ការបដិសេធនៃធនធានចាំបាច់ដោយគ្មានហេតុផល

67. សហមេធាវីនាំមុខនៅតែរក្សាជំហរថា ធនធាននានាដែលបានស្នើសុំ គឺមានភាពចាំបាច់ និងសមស្របសម្រាប់ការធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងមានប្រសិទ្ធភាព។ បើទោះបីជាការិយាល័យរដ្ឋបាល អាចនឹងជឿជាក់ថា បន្ទុកការងារ ត្រូវកាត់បន្ថយជាស្វ័យប្រវត្តិនៅដំណាក់កាលនីតិវិធីបច្ចុប្បន្នក៏ដោយ ក៏ខ្លួនមិនអាចសន្មត់ថា ករណីនេះវាកើតឡើងចំពោះគ្រប់ភាគីនោះដែរ។ បន្ទុកការងារនៅតែមានច្រើន។ ក្រៅពីបញ្ហានានាដែលបានរៀបរាប់លម្អិតខាងលើ នៅមានការងារធំៗជាច្រើនទៀតដែលត្រូវបំពេញក្នុងឆ្នាំ២០២១ និងឆ្នាំ២០២២ ដែលការិយាល័យរដ្ឋបាលហាក់ដូចជាទទួលស្គាល់ថា វាស្ថិតនៅក្នុងអាណត្តិការងាររបស់សហមេធាវីនាំមុខ។ ការងារទាំងនេះរួមមាន៖ (១) ការជួបប្រជុំឱ្យបានច្រើនតាមដែលអាចធ្វើបានជាមួយដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣៨៦៥ នាក់ ឬសមាជិកគ្រួសាររបស់ពួកគេដែលរស់រានមានជីវិត ទៅតាមកាលបរិច្ឆេទកំណត់ចាប់ពីថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០២១[75] (២) ការពិនិត្យទៅលើសម្ភារៈក្នុងសំណុំរឿង ពាក់

[75] សហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បាននិងកំពុងធ្វើការជាមួយគ្នាអស់រយៈពេល ១ខែ ដើម្បីធានាឱ្យមានថវិកាពីខាងក្រៅដើម្បីប្រជុំជាមួយដើមបណ្តឹងរដ្ឋប្បវេណី និងដើម្បីពិភាក្សាលើសំណួរគន្លឹះៗជាមួយពួកគេ រួមទាំងការចែករំលែកព័ត៌មានបច្ចុប្បន្នភាពអំពីបណ្តឹងសាទុក្ខ និងស្វែងរកគំនិតអំពីព័ត៌មានផ្ទាល់ខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីណាដែលរសើបដែលមាននៅក្នុងសំណុំរឿង។ ការផ្តល់ថវិកាត្រូវបានធានា ហើយសហមេធាវីនាំមុខកំពុងសម្របសម្រួលការប្រជុំចំនួន ១៣ កន្លែង

ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណី និងសារណានានាពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឡើងវិញទៅលើសម្ភារៈទាំងនោះ (៣) ការប្រមូលផ្ដុំ និងការបញ្ចូលព័ត៌មានស្ដីពីការអនុវត្តគម្រោងផ្ដល់សំណងដើម្បីរាយការណ៍ជូនអង្គជំនុំជម្រះ[76]។ ការកាត់បន្ថយអាណត្តិ និងធនធានរបស់អង្គភាព នាំឱ្យមានផលវិបាកជាក់ស្ដែងទៅលើសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះការតំណាងដោយប្រសិទ្ធភាព។ ការងារនេះមិនអាចអនុវត្តទៅបានដោយពុំមានការចូលរួមជាប្រចាំពីមន្ត្រីប្រឹក្សាអន្តរជាតិបានឡើយ។

68. ព័ត៌មានបន្ថែមទៀតស្ដីពីកាតព្វកិច្ចពាក់ព័ន្ធនានា មានបញ្ចូលនៅក្នុងអនុស្សរណៈទីមួយរបស់សហមេធាវីអន្តរជាតិនាំមុខ[77] ហើយនឹងមិនលើកឡើងជាថ្មីទៀតទេ។ ទោះជាយ៉ាងណាក្ដី ពាក់ព័ន្ធនឹងអនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល យើងសូមលើកឡើងនូវចំណុចមួយចំនួនដូចជា៖

(i) ការងារមានច្រើន។ សម្រាប់ភាគីអន្តរជាតិ មានការងារច្រើនដែលបុគ្គលិកតែម្នាក់មិនអាចបំពេញអស់។ ជារួម មានការងារច្រើនដែលបុគ្គលិកបួននាក់ក៏មិនអាចបំពេញអស់។ ស្ថានភាពនេះនៅតែកើតមានដដែល ទោះបីមានការពន្យារថិរវេលាដើម្បីបំពេញការងារក៏ដោយ។ គោលដៅគឺត្រូវបំពេញទៅតាមកាតព្វកិច្ចទាំងអស់មុនពេលចេញសាលដីកាស្ថាពរ។ ការងារនេះមិនអាចបញ្ចប់ទៅបានដោយគ្មានមន្ត្រីប្រឹក្សាអន្តរជាតិឡើយ។

(ii) កាតព្វកិច្ចទាំងនោះតម្រូវឱ្យមានជំនាញផ្សេងៗ។ ជំនាញទាំងនេះរួមមាន៖ យុទ្ធសាស្ត្រ ការវិភាគផ្នែកច្បាប់ ការតាក់តែងសេចក្ដីព្រាងឯកសារ ការអានឯកសារឡើងវិញ ជំនាញភាសា

---

ខុសគ្នា សម្រាប់មេធាវីចំនួន ៨ រូប ដើម្បីជួបកូនក្ដីចំនួន ២៦០ រូប ដែលនឹងអនុវត្តពីថ្ងៃទី ២៩ ខែ តុលា រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២១។ អង្គភាពសហមេធាវីនាំមុខ ជាអ្នកត្រួតពិនិត្យការចុះបេសកកម្មទាំងនេះ រៀបចំព័ត៌មានសំខាន់ៗដើម្បីចែករំលែកជូនដើមបណ្ដឹងរដ្ឋប្បវេណី និងប្រមូលបញ្ចូលគ្នានូវលទ្ធផលដែលទទួលបានពីការប្រឹក្សាជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីកំណត់ពីយុត្តិសាស្ត្រឆ្ពោះទៅមុខបន្ត។

[76] ការរាយការណ៍របៀបនេះត្រូវបានធ្វើឡើងនៅក្នុងសំណុំរឿង ០០២/០១។ ឯកសារ **E218/7/9** សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការអនុវត្តសំណងតាមផ្លូវតុលាការសម្រាប់សំណុំរឿង ០០២/០១ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧។ ឯកសារ **E218/7/10** អនុស្សរណៈពីសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីផ្ញើជូនចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង និងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការធ្វើបច្ចុប្បន្នភាពអំពីសំណងនៅក្នុងសំណុំរឿង ០០២/០២ គម្រោងទី១៖ ទិវាជាតិនៃការចងចាំ និងគម្រោងទី៣៖ ការសាងសង់ស្តូបនៅរាជធានីភ្នំពេញសម្រាប់រម្លឹកដល់ជនរងគ្រោះដោយសារការជម្លៀសដោយបង្ខំ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨។

[77] ឧបសម្ព័ន្ធ ក៖ អនុស្សរណៈទី១ របស់សហមេធាវីនាំមុខអន្តរជាតិ ទំព័រ ២-៧។ ឧបសម្ព័ន្ធ ច៖ អនុស្សរណៈទី៣ របស់សហមេធាវីនាំមុខអន្តរជាតិ ទំព័រ ២-៣។

អង់គ្លេស/ខ្មែរ/បារាំង ការគ្រប់គ្រងព័ត៌មាន ការស្រាវជ្រាវ ផ្នែកទំនាក់ទំនងជាមួយម្ចាស់ជំនួយ ការសម្របសម្រួលដែគួរនៅមូលដ្ឋាន ការសម្របសម្រួលរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ផ្នែកភស្តុភារ និងកិច្ចការផ្សេងៗទៀត។ សមាជិកផ្សេងៗក្នុងក្រុមការងារមានជំនាញផ្សេងៗគ្នា។ ហេតុនេះ សម្រាប់ការងារពេញម៉ោង បុគ្គលិកពីរនាក់បំពេញការងារមានប្រសិទ្ធភាពជាងបុគ្គលិកតែម្នាក់។

(iii) ដូចគ្នានេះដែរ កាតព្វកិច្ចទាំងនេះសមស្របចំពោះសមាជិកក្រុមការងារដែលមានកម្រិតអតីតភាពខុសៗគ្នា។ ប្រសិទ្ធផលជាអតិបរមា និងការចំណាយថវិកាសាធារណៈប្រកបដោយការទទួលខុសត្រូវ គឺសំដៅឆ្ពោះទៅធានាថា ការងារតូចតាចនានាមិនត្រូវបំពេញដោយសមាជិកក្រុមការងារដែលមានអតីតភាពយូរទេ ហេតុនេះគួររក្សាទុកឱ្យមានសមាជិកក្រុមការងារដែលមានកម្រិតខុសៗគ្នា (ទាំងការប្រើប្រាស់ភាសាខ្មែរ និងភាសាអង់គ្លេស)។

69. ការវាយតម្លៃរបស់សហមេធាវីនាំមុខចំពោះធនធានដែលចាំបាច់សម្រាប់ការងារនេះ ជាការវាយតម្លៃបែបអភិរក្ស។ ពួកគេបានដាក់សំណើមួយដែលការិយាល័យរដ្ឋបាលអាចទទួលយកបាន ទោះបីវាអាចចំណាយពេលខ្លះក៏ដោយ។ ការពិត ដោយសារធនធានមានភាពខ្វះខាត សហមេធាវីនាំមុខមានការលំបាកក្នុងការអនុវត្តផ្នែកខ្លះនៃអាណត្តិការងាររបស់ខ្លួន នៅពេលបំពេញការងារនៅក្នុងដំណើរការបណ្តឹងសាទុក្ខ[78]។ ការងារនោះត្រូវចាំរហូតដល់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខចប់សព្វគ្រប់។ នាពេលនេះ សហមេធាវីនាំមុខបានស្នើសុំបំពេញការងារនោះ នៅពេលកំពុងរង់ចាំសាលដីកា។ ទោះជាយ៉ាងណាក្តី សហមេធាវីនាំមុខមិនអាចសម្រេចទៅតាមគោលដៅនេះបានទេ ប្រសិនបើគ្មានមន្ត្រីប្រឹក្សាខាងភាគីអន្តរជាតិ។

70. សហមេធាវីនាំមុខក៏ពិចារណាឃើញថា ជាការចាំបាច់ដែលត្រូវបញ្ចេញប្រតិកម្មទៅនឹងកំហុសឆ្គងនានានៃការផ្តល់សំអាងហេតុរបស់ការិយាល័យរដ្ឋបាល ពាក់ព័ន្ធនឹងធនធានចាំបាច់ ដើម្បីដោះស្រាយបន្ទុកការងារនេះ ដូចខាងក្រោម៖

**ក. ធនធានខាងភាគីជាតិ**

[78] ចំណុចនេះហាក់ដូចជាទទួលយកដោយការិយាល័យរដ្ឋបាល៖ ឧបសម្ព័ន្ធ គ៖ អនុស្សរណៈទី១ របស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៥។

71. ការិយាល័យរដ្ឋបាលមានកំហុសឆ្គងក្នុងការលើកឡើងថា ភាពខ្វះខាតផ្នែកធនធានត្រូវបានដោះស្រាយដោយការចូលរួមពាក់ព័ន្ធរបស់ភាគីជាតិ។ ការិយាល័យរដ្ឋបាលលើកឡើងដោយប្រយោលថា សំណើសុំធនធានរបស់សហមេធាវីអន្តរជាតិនាំមុខពុំបានគិតដល់ភាគីជាតិនៅក្នុងក្រុមសហមេធាវីនាំមុខទេ ដោយសារពួកគេ "ពុំបានទទួលការជូនដំណឹងនៅក្នុងលិខិតប្រាស្រ័យទាក់របស់[លោកស្រី]"[79]។ ចំណុចនេះមិនត្រឹមត្រូវទេ។ ធនធានរបស់ភាគីជាតិក៏ត្រូវបានទទួលការយកចិត្តទុកដាក់ដែរ ដោយសន្មតថាមានគ្រប់គ្រាន់ហើយ។ សំណើរបស់សហមេធាវីអន្តរជាតិនាំមុខសម្រាប់ត្រីមាសនេះ ព្រមទាំងសំណើទាំងអស់ពីមុនៗមក ត្រូវបានដាក់ជូនត្រឹមតែ UNAKRT ប៉ុណ្ណោះ ទាក់ទិននឹងធនធាននានាដែលចាំបាច់សម្រាប់ភាគីអន្តរជាតិ ដោយមានការសន្មតថាធនធានខាងភាគីជាតិពុំមានការប្រែប្រួលទេ។

72. ទោះបីភាគីជាតិដើរតួនាទីសំខាន់មិនអាចខ្វះបាននៅក្នុងក្រុមសហមេធាវីនាំមុខក្តី តែមិនអាចជំនួសភាពចាំបាច់ដែលត្រូវមានមន្ត្រីប្រឹក្សាអន្តរជាតិនោះទេ។ មួយផ្នែកដោយសារទំហំនៃបន្ទុកការងារតម្រូវឱ្យមានសមាជិកជាច្រើនកម្រិតនៅក្នុងក្រុម។ ហើយក៏ដោយសារតែតម្រូវការឱ្យមានកម្រិតជំនាញផ្សេងៗគ្នាផងដែរ ដូចបានពន្យល់ពីខាងលើ។

### ខ. ការប្រៀបធៀបជាមួយ ក.ស.ព

73. សហមេធាវីនាំមុខកត់សម្គាល់អំពីសេចក្តីថ្លែងការណ៍របស់ការិយាល័យរដ្ឋបាលដែលថា ការនិយាយយោងទៅការងារ ឬធនធានរបស់ ក.ស.ព "ពុំមានប្រយោជន៍ទេ"[80]។ សហមេធាវីនាំមុខមិនយល់ស្របទេ។ ពិតហើយដែលថា ធនធានរបស់ ក.ស.ព ពុំមែនជាកត្តាកំណត់ ដោយសារ ក.ស.ព និង សហមេធាវីនាំមុខមានកាតព្វកិច្ចខុសគ្នា។ ឧទាហរណ៍៖ ក.ស.ព ពុំចាំបាច់ធ្វើការរៃអង្គាសថវិកាពីខាងក្រៅ ឬព្យាយាមសម្របសម្រួលការជួបប្រជុំជាមួយមនុស្សរាប់ពាន់នាក់នោះទេ។ ទោះជាយ៉ាងណាក្តី ចំណុចនេះមិនមែនមានន័យថា ការផ្តល់ធនធាន និងការងាររបស់ ក.ស.ព មិនពាក់ព័ន្ធនោះទេ។ វិធាន ២១(១) នៃវិធានផ្ទៃក្នុងតម្រូវថា ត្រូវរក្សាឱ្យមានតុល្យភាពរវាងភាគីនានា។ បើភាគីមួយបានទទួលធនធានដើម្បីបំពេញភារកិច្ចណាមួយ (ឧទាហរណ៍ ការធ្វើចំណាត់

---

[79] ឧបសម្ព័ន្ធ ឆ៖ អនុស្សរណៈទី២ របស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៨។

[80] ឧបសម្ព័ន្ធ ឆ៖ អនុស្សរណៈទី២ របស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ១២។

ប្រភេទឯកសារឡើងវិញ ឬការដាក់ឯកសារក្នុងបណ្ណសារ និងការកាត់បន្ថយបុគ្គលិក[81]) តែភាគីផ្សេងទៀតដែលត្រូវបានបដិសេធមិនផ្តល់ធនធានដើម្បីបំពេញភារកិច្ចទាំងនោះ វានឹងបង្កឱ្យមានការចោទសួរពាក់ព័ន្ធនឹងតុល្យភាពនោះមិនខាន។ ជាងនេះទៀត ទោះបីភារកិច្ចមួយចំនួនមានដូចគ្នារវាង ក.ស.ព និង សហមេធាវីនាំមុខ (ឬ ចំពោះបញ្ហានោះ ក៏ចំពោះមេធាវីការពារក្តី) ឬយ៉ាងហោចណាស់ក៏ស្រដៀងគ្នាក៏ដោយ ក៏អ្នកធ្វើសេចក្តីសម្រេចមានសុភវិនិច្ឆ័យអាចយល់ថា វាជាសូចនាករមួយដែលតម្រូវឱ្យផ្តល់ធនធានស្រដៀងគ្នាដែរសម្រាប់កិច្ចការងារទាំងនោះ។

### គ. ទស្សនៈ "សហ"

74. ការដែលការិយាល័យរដ្ឋបាលសំអាងទៅលើទស្សនៈ "សហ" គឺគ្មានសំអាងត្រឹមត្រូវទេ។ ការណ៍ដែលថា ការតែងតាំងសហមេធាវីនាំមុខពីរនាក់ជាលក្ខខណ្ឌចាំបាច់នោះ មិនបានកំណត់ដល់ធនធានដែលត្រូវបែងចែកដល់ពួកគេទេ។ វាពុំមែនជាមូលហេតុដើម្បីបដិសេធមិនឱ្យមានបុគ្គលិកជំនួយទេ ជាពិសេសបើយោងទៅតាមអត្ថន័យនៃវិធាន ១២*ស្ទួនពីរ*(៤) នៃវិធានផ្ទៃក្នុង ("គាំពារដោយបុគ្គលិកមួយចំនួនទៀតតាមការចាំបាច់") និងវិធាន ១២ នៃវិធានផ្ទៃក្នុង (ដែលតម្រូវឱ្យបង្កើតផ្នែកមួយសម្រាប់សហមេធាវីនាំមុខ)។ វាមិនសមហេតុផលទេដែលនៅតែទទូចថា ការងារ*ទាំងអស់*ត្រូវបំពេញដោយសហមេធាវីនាំមុខ ឬសហមេធាវីគួរធ្វើការពេញម៉ោងនោះឡើយ។ ប្រសិនបើមានករណីនោះមែន គេមិនដឹងច្បាស់ថាហេតុអ្វីបានជាផ្តល់ឱ្យមានមន្ត្រីប្រឹក្សាមកដល់ពេលនេះ ឬមូលហេតុអ្វីដែលសហមេធាវីនាំមុខបច្ចុប្បន្នបានទទួលប្រាក់កម្រៃទៅតាមម៉ោងបំពេញការងារចាប់តាំងពីបានទទួលការតែងតាំងមកនោះ។ គែគួរកត់សម្គាល់ផងដែរថា ផែនការផ្តល់ជំនួយផ្នែកច្បាប់ដល់ការការពារក្តីបានទទួលស្គាល់យ៉ាងច្បាស់ថា សហមេធាវីមិនសុទ្ធតែបំពេញការងារពេញម៉ោងនោះឡើយ[82]។

### ឃ. ការចងចាំជារួម

75. ការពន្យារពេលដែលបានបង្កឡើង តាមរយៈការបាត់បង់សមាជិកសំខាន់ៗក្នុងក្រុមការងារបានបង្កការលំបាកដល់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិនានា ដោយសារទំហំនៃរឿងក្តី និងថិរវេលាចាំបាច់ដើម្បីបន្សាំនឹងរឿងក្តីទាំងនោះ ហើយបញ្ហានេះអាចកាន់តែគួរឱ្យកត់សម្គាល់ទៅទៀត នៅពេល

---

[81] នេះជាចំណុចដែលសហមេធាវីអន្តរជាតិនាំមុខ បានយោងទៅ ក.ស.ព។ សូមមើល ឧបសម្ព័ន្ធ ឃ៖ អនុស្សរណៈទី២ របស់សហមេធាវីអន្តរជាតិនាំមុខ កថាខណ្ឌ ២៥។

[82] ឧបសម្ព័ន្ធ ជ៖ ផែនការផ្តល់ជំនួយផ្នែកច្បាប់នៅ អ.វ.ត.ក (ត្រូវបានធ្វើវិសោធនកម្មនៅខែធ្នូ ឆ្នាំ២០១៤) ផ្នែក ក ចំណុច ៣។

តុលាការជិតបញ្ចប់ការងាររបស់ខ្លួន[83]។ តុលាការអន្តរជាតិផ្សេងទៀតបានដោះស្រាយបញ្ហានេះនៅក្នុងក្រុមការពារក្តី និងក្រុមជនរងគ្រោះ ដោយអនុញ្ញាតឱ្យមេធាវីមានភាពបត់បែនច្រើនជាងមុនក្នុងការបែងចែកធនធាន[84]។

76. សំណើសុំធនធានដោយសហមេធាវីអន្តរជាតិនាំមុខ បានលើកឡើងម្តងហើយម្តងទៀតពីភាពចាំបាច់ ដើម្បីការពារការចងចាំជារួមរៀបចំដោយទីប្រឹក្សាអន្តរជាតិរបស់សហមេធាវីនាំមុខ[85]។ ការងារមួយចំនួន ដូចជាការដោះស្រាយគម្រោងផ្តល់សំណង ការស្រាវជ្រាវ និងការគ្រប់គ្រងកម្មវិធី Casemap ត្រូវបានបំពេញជាចម្បងដោយទីប្រឹក្សាអន្តរជាតិ។

77. សហមេធាវីនាំមុខដឹងច្បាស់ថា ដោយពុំមានមន្ត្រីប្រឹក្សាអន្តរជាតិ ការងាររបស់ខ្លួននឹងមានភាពយឺតយ៉ាវជាងខ្លាំង ជាពិសេសពាក់ព័ន្ធនឹងការរាយការណ៍អំពីការផ្តល់សំណង ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ និងការជួបប្រាស្រ័យទាក់ទងជាមួយដើមបណ្តឹងរដ្ឋប្បវេណី ដែលបទពិសោធន៍ដ៏ទូលំទូលាយរបស់លោកស្រី បានផ្តល់គុណប្រយោជន៍យ៉ាងធំធេង។ ការិយាល័យរដ្ឋបាលដោះស្រាយបញ្ហានេះ ដោយគ្រាន់តែអះអាងថា "ការចងចាំជារួមគឺជាសមិទ្ធផលរបស់បុគ្គលិក*គ្រប់រូប*មិនមែនជារបស់បុគ្គលិកជាក់លាក់ណាម្នាក់ទេ"[86] ជាសេចក្តីថ្លែងការណ៍បែបទូទៅ ដែលមិនយកចិត្តទុកដាក់ដល់ករណីជាក់ស្តែង។ ក្រុមសហមេធាវីនាំមុខជាក្រុមការងារតូចមួយ ហើយពុំមានបុគ្គលិកណាផ្សេងដែលចែករំលែកចំណេះដឹង និងជំនាញពិសេស ដូចមន្ត្រីប្រឹក្សាយោបល់របស់យើងទេ។ សហមេធាវីនាំមុខអាចធ្វើការងារដែលខ្លួនអាចធ្វើបាន ដើម្បីថែរក្សាការចងចាំ តាមរយៈធ្វើការកំណត់ហេតុនានា ដែលមានតែបុគ្គលិកដែលអាចភ្ជាប់យ៉ាងឆាប់រហ័សរវាងការងារបច្ចុប្បន្នទៅនឹងលទ្ធផលការងារពីមុនទេ ទើបមានចំណេះដឹងជាក់លាក់មួយចំនួន ដើម្បីអាចប្រើ

---

[83] សូមមើលឧទាហរណ៍ យោបល់អំពីការពន្យារពេលដែលបង្កឡើងដោយបញ្ហានេះនៅក្នុង ការវាយតម្លៃ និងរបាយការណ៍របស់ចៅក្រម Theodor Meron ប្រធានតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលផ្តល់ជូនក្រុមប្រឹក្សាសន្តិសុខ អនុលោមតាមកថាខណ្ឌ ៦ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៥៣៤ (ឆ្នាំ២០០៤) ដែលគ្របដណ្តប់ទៅលើចិរវេលាពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៥ ដល់ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារលេខ S/2015/874 ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ កថាខណ្ឌ ១៥, ១៧។

[84] សូមមើលឧទាហរណ៍៖ តុលាការ ICC កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីគោលនយោបាយផ្តល់ជំនួយផ្នែកច្បាប់ ទំព័រ ៥០ បន្ទាត់ ៨-១២ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨។

[85] ឧបសម្ព័ន្ធ ក៖ អនុស្សរណៈទី១ របស់សហមេធាវីនាំមុខអន្តរជាតិ ទំព័រ ៧។ ឧបសម្ព័ន្ធ ឃ៖ អនុស្សរណៈទី២ របស់សហមេធាវីនាំមុខអន្តរជាតិ កថាខណ្ឌ ២៨(ក)។ ឧបសម្ព័ន្ធ ច៖ អនុស្សរណៈទី៣ របស់សហមេធាវីនាំមុខអន្តរជាតិ ទំព័រ ៣។

[86] ឧបសម្ព័ន្ធ ឆ៖ អនុស្សរណៈទី២ របស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ១៤។

ប្រាស់ធនធានឱ្យមានតែមានប្រសិទ្ធផល។ ការមិនគិតដល់ចំណុចនេះ ការិយាល័យរដ្ឋបាលមិនយកចិត្តទុកដាក់ដល់ការពិចារណាពាក់ព័ន្ធមួយ។ ទោះបីសហមេធាវីនាំមុខដឹងថា ការកាត់បន្ថយបុគ្គលិកជាការចាំបាច់នាពេលណាមួយក៏ដោយ តែការិយាល័យរដ្ឋបាលមិនបានពន្យល់ថា ហេតុអ្វីបានជាចាំបាច់បង្កឱ្យមានព្យសនកម្មនេះដល់ការចងចាំរបស់ក្រុមការងារ ប្រសិនបើអាចរក្សាទុកមន្ត្រីប្រឹក្សាយោបល់ដោយគ្មានចំណាយបន្ថែមនោះទេ (សូមមើលខាងក្រោម)។

### ច. អាចនាំឱ្យមានការពន្យារពេល

78. ការងារមួយចំនួនបើមិនបញ្ចប់នាពេលនេះទេ ចាំបាច់នឹងត្រូវបញ្ចប់នាពេលណាមួយ អាចក្រោយពេលចេញសាលដីកាស្ថាពរទៀតផង។ ការពន្យារពេលធ្វើការងារនេះ បង្កជាហានិភ័យដោយការអូសបន្លាយថិរវេលាការងារ និងមុខងារដែលនៅសេសសល់របស់តុលាការ លើសពីបីឆ្នាំ ទៅតាមការគ្រោងទុកក្នុងសេចក្តីព្រាងនៃកិច្ចព្រមព្រៀង។

79. ចៅក្រមនៅក្នុងតុលាការនេះបានពិចារណាឃើញថា បញ្ហាទាំងនេះពាក់ព័ន្ធទៅនឹងការផ្តល់ធនធានដល់ក្រុមការងាររបស់ភាគីនានា។ ឧទាហរណ៍ នៅពេលសម្រេចទៅលើសំណើសុំធនធានសម្រាប់ក្រុមមេធាវីការពារក្តីនៃសំណុំរឿង ០០៤ ស.ច.ស អន្តរជាតិបានពន្យល់ថា៖

> ... យើងរម្លឹកថា ជនត្រូវចោទនៅ អ.វ.ត.ក មានសិទ្ធិជាមូលដ្ឋានដើម្បីទទួលបានពេលវេលាគ្រប់គ្រាន់ ក្នុងការត្រៀមរៀបចំការការពារក្តីរបស់ខ្លួន។ ទន្ទឹមនឹងនេះ ពួកគាត់មានសិទ្ធិជាមូលដ្ឋានដើម្បីទទួលបានការជំនុំជម្រះក្នុងរយៈពេលសមស្របមួយ។ សិទ្ធិទាំងនេះ និងសិទ្ធិក្នុងពេលស៊ើបអង្កេតផង តម្រូវឱ្យមានមេធាវីការពារក្តីទទួលបានធនធានសម្រាប់ការពារក្តី។ កាលណាការស៊ើបអង្កេតកាន់តែយូរ ការចំណាយរបស់ អ.វ.ត.ក និង រដ្ឋដែលជាម្ចាស់ជំនួយក៏កាន់តែអស់ច្រើន។ ដូច្នេះ មានតែវិធានការដែលអាចបង្រួញពេលវេលា ដែលតម្រូវឱ្យមេធាវីការពារក្តីចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការប៉ុណ្ណោះ មានប្រយោជន៍ដល់ទាំង យឹម ទិត្យ អ.វ.ត.ក និងសហគមន៍អន្តរជាតិទាំងមូល[87]។

80. នាពេលនេះ បញ្ហាប្រហាក់ប្រហែលគ្នានេះបានកើតឡើង ទាក់ទិននឹងការងារជាច្រើនពាក់ព័ន្ធនឹងការបង្ហាញព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនគួរផ្សព្វផ្សាយជាសាធារណៈ (ការធ្វើ

---

[87] **សំណុំរឿង ០០៤ – ឯកសារ D312/1** ដីកាសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ ទាក់ទិននឹងធនធានរបស់ក្រុមមេធាវីការពារក្តី ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ កថាខណ្ឌ ៥។

ចំណាត់ប្រភេទឡើងវិញ)។ ការងារនេះនឹងត្រូវបំពេញនៅដំណាក់កាលណាមួយ បើមិនធ្វើនៅពេលនេះ មានតែនៅក្រោយពេលចេញសាលដីកាស្ថាពរលើសំណុំរឿង ០០២/០២។ ហេតុនេះ សហមេធាវីនាំមុខយល់ឃើញថា មានគុណប្រយោជន៍យ៉ាងធំធេងបើបំពេញការងារនេះនៅពេលនេះ ដោយសារបញ្ហានេះនៅថ្មីៗ ហើយខណៈពេលដែលសហមេធាវីនាំមុខមានមន្ត្រីប្រឹក្សាដែលដឹងច្បាស់ពីបញ្ហាទាំងនេះ។

81. ការសម្រេចរបស់ការិយាល័យរដ្ឋបាល នឹងធ្វើឱ្យការងាររបស់សហមេធាវីនាំមុខមានភាពយឺតយ៉ាវដោយសារ (i) ការកាត់បន្ថយធនធានមនុស្សដែលខ្លួនមានយ៉ាងធំធេង និង (ii) ការបង្កឱ្យបាត់បង់ការចងចាំជារួមដូចបានលើកឡើងខាងលើ។ ទោះបីធនធានផ្នែកប្រឹក្សាអាចនឹងមានឡើងវិញនាពេលអនាគតក្តី (ដូចបានស្នើឡើងដោយការិយាល័យរដ្ឋបាល[88]) តែចំណុចនេះនឹងមិនអាចដោះស្រាយព្យសនកម្មដែលបង្កឡើងឱ្យបានពេញលេញទេ។ ដំណើរការឱ្យសុំទៅនឹងសំណុំរឿង ០០២ ព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងការងាររបស់តុលាការតម្រូវឱ្យចំណាយពេលវេលាជាច្រើន។

### ឆ. វិធីសាស្ត្របែងចែកការងារដែលពុំមានប្រសិទ្ធផល

82. ដូចដែលបានពន្យល់ក្នុងអនុស្សរណៈនានារបស់សហមេធាវីអន្តរជាតិនាំមុខ សំណើរបស់លោកស្រីសុំបែងចែកការងារនឹងធ្វើឱ្យដំណើរការបំពេញភារកិច្ចមិនសូវស្មុគ្រស្មាញ ឬជាយុទ្ធសាស្ត្រដោយមានការចំណាយតិច[89]។ ការតម្រូវថា ការងារ*ទាំងអស់*របស់ភាគីអន្តរជាតិត្រូវបំពេញដោយសហមេធាវីអន្តរជាតិនាំមុខ ជាជាងដោយមន្ត្រីប្រឹក្សា បានបង្កើនអត្រាប្រាក់កម្រៃរបស់សហមេធាវីអន្តរជាតិនាំមុខដល់ទៅ ៥០% ដែលធ្វើឱ្យប៉ះពាល់ដល់ការគ្រប់គ្រងយ៉ាងសមរម្យទៅលើថវិកាសាធារណៈ ពុំមែនធ្វើឱ្យប្រសើរឡើងនោះទេ[90]។ នោះមានន័យថា ភារកិច្ចជាមូលដ្ឋានជាច្រើន ជាពិសេសនៅពេលត្រូវរៀបចំឯកសារជាភាសាអង់គ្លេស នឹងត្រូវធ្វើឡើងដោយសមាជិក

---

[88] ឧបសម្ព័ន្ធ ង៖ ការឆ្លើយឆ្លងសារអ៊ីមែលរវាងការិយាល័យរដ្ឋបាល និងសហមេធាវីនាំមុខអន្តរជាតិ ទំព័រ ៣-៤ (សារអ៊ីមែលពីការិយាល័យរដ្ឋបាល ផ្ញើជូនសហមេធាវីនាំមុខអន្តរជាតិ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១)។ ឧបសម្ព័ន្ធ ឆ៖ អនុស្សរណៈទី២ របស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៣០។

[89] ឧបសម្ព័ន្ធ ឃ៖ អនុស្សរណៈទី២ របស់សហមេធាវីនាំមុខអន្តរជាតិ កថាខណ្ឌ ២៨(ខ)។ ឧបសម្ព័ន្ធ ច៖ អនុស្សរណៈទី៣ របស់សហមេធាវីនាំមុខអន្តរជាតិ ទំព័រ ៣។

[90] សូមមើល ឧបសម្ព័ន្ធ ឆ៖ អនុស្សរណៈទី២ របស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ២៣, ២៨ ដែលយោងដល់សារៈសំខាន់នៃការបំពេញការងារដោយយកចិត្តទុកដាក់ ក្នុងការគ្រប់គ្រងថវិកាសាធារណៈ។

ក្រុមការងារដែលទទួលប្រាក់កម្រៃខ្ពស់ជាងគេក្នុងក្រុមសហមេធាវីនាំមុខ។ ភារកិច្ចទាំងនេះរួមមាន៖ ការស្រាវជ្រាវលើប្រព័ន្ធ Zylab ការទាញយកព័ត៌មានចេញ ឬបញ្ចូលព័ត៌មានចូល ក្នុងឃ្លាំងផ្ទុកទិន្នន័យផ្ទៃក្នុងរបស់កូនក្តី រៀបចំនិងការពិនិត្យលើឯកសាររាប់ពាន់ ដើម្បីស្វែងរកសម្ភារៈដែលមានភាពរសើបពាក់ព័ន្ធដល់នីតិវិធីនៃការធ្វើចំណាត់ប្រភេទឡើងវិញ ការសម្របសម្រួលជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងផ្នែកគាំពារជនរងគ្រោះ ស្តីពីផ្នែកភស្តុភារ និងបញ្ហានានានៅកម្រិតការងារធម្មតា ការដាក់បញ្ចូលព័ត៌មានជាច្រើនសន្លឹកសន្ធាប់ដែលទទួលបានតាមរយៈការជួបប្រជុំជាមួយដើមបណ្តឹងរដ្ឋប្បវេណី ការស្រាវជ្រាវផ្នែកច្បាប់ ការអានឯកសារនានា ការរៀបចំតារាងបញ្ជីឯកសារ និងបញ្ជីនៃឯកសារភ្ជាប់សម្រាប់ការដាក់ឯកសារ ការសម្របសម្រួលនិងការតាមដានការងារជាមួយដៃគូគម្រោង និងការដាក់ឯកសារជូនភាគី ឬការស្នើសុំបកប្រែ។

83. សហមេធាវីនាំមុខកត់សម្គាល់ថា នៅខាងការពារក្តី ផែនការផ្តល់ជំនួយផ្នែកច្បាប់*ហាមឃាត់*ដោយផ្ទាល់នូវភារកិច្ចមួយចំនួនដែលត្រូវបំពេញដោយសហមេធាវីការពារក្តី និងកំណត់ថា ការងារទាំងនោះគួរតែបំពេញដោយមន្ត្រីប្រឹក្សាច្បាប់ ឬមន្ត្រីគ្រប់គ្រងសំណុំរឿង។ ភារកិច្ចទាំងនោះរួមមាន៖ ការស្រាវជ្រាវផ្នែកច្បាប់ ការពិនិត្យលើភស្តុតាងបឋម ការរៀបចំសំណុំឯកសារ ការស្នើសុំការបកប្រែ ការប្រើប្រាស់ប្រព័ន្ធ zylab និង Casemap ការថតស្កេនឯកសារ និងការងាររដ្ឋបាលនានា[91]។ ពុំមានផ្តល់ហេតុផលណាមួយថា ហេតុអ្វីបានជាវិធីសាស្ត្រដូចគ្នានេះ មិនគួរយកមកអនុវត្តចំពោះភាពជាតំណាងផ្លូវច្បាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីទេ។

### ជ. ការចំណាយដែលបានកំណត់

84. សហមេធាវីនាំមុខសូមលើកឡើងថា កត្តាទាំងអស់ខាងលើត្រូវតែផ្តល់ទម្ងន់ក្នុងកម្រិតណាមួយនៅពេលពិចារណាផ្នែកថវិកា ដោយសារថវិកាមានកំណត់ជាចាំបាច់។ ទោះជាយ៉ាងណាក្តី នៅក្នុងឧទាហរណ៍នេះ ការិយាល័យរដ្ឋបាលកំពុងសម្រេចទៅលើធនធាន ដែលផ្ទុយពីការស្នើសុំរបស់មេធាវីឯករាជ្យ ដែលនឹងបង្កឱ្យបាត់បង់ធនធានមនុស្ស និងការចងចាំជារួម ហើយស្ទើរតែនាំឱ្យមានការពន្យារពេល និងការចំណាយបន្ថែម *ទោះបីសហមេធាវីអន្តរជាតិនាំមុខបានស្នើសុំឱ្យមានដំណោះស្រាយដែលចំណាយតាមការកំណត់ក៏ដោយ*។

[91] ឧបសម្ព័ន្ធ ជ៖ ផែនការផ្តល់ជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក (ត្រូវបានធ្វើវិសោធនកម្មនៅខែធ្នូ ឆ្នាំ២០១៤) កថាខណ្ឌ ង(៨) និង ង(៩)។

85. សហមេធាវីអន្តរជាតិនាំមុខបានស្នើសុំនូវដំណោះស្រាយ បង្កើនធនធានដែលមានស្រាប់របស់ក្រុមការងារ ដោយគ្មានការចំណាយបន្ថែម។ គេអាចធ្វើបែបនេះបាន ដោយមានការចូលរួមចំណែកយ៉ាងធំធេងដោយមន្ត្រីប្រឹក្សារបស់ក្រុមការងារ ដែលអាចមានការចូលរួមចំណែកបានតិចតួច ប្រសិនបើត្រូវបំពេញដោយសហមេធាវីអន្តរជាតិនាំមុខ (ដែលអត្រាប្រាក់កម្រៃខ្ពស់ជាង)[92]។ ឬគេអាចធ្វើបាន ដោយការផ្លាស់ប្តូរកិច្ចសន្យាការងាររបស់សហមេធាវីអន្តរជាតិនាំមុខ ដើម្បីឱ្យស្រីទទួលបានប្រាក់កម្រៃប្រចាំខែ និងមានសេរីភាពក្នុងការចុះកិច្ចសន្យាជ្រើសរើសបុគ្គលិកឱ្យមកបំពេញការងារ[93]។ ដំណោះស្រាយនេះក៏នឹងធានាថា ភារកិច្ចបន្ទាប់បន្សំមិនត្រូវបានបំពេញដោយការចំណាយមិនសមាមាត្រទៅនឹងតុលាការទេ (សូមមើលខាងលើ នៅត្រង់ ៨៣-៨៤)។

86. ធ្លាប់មានការសម្រេចពីមុនមកថា ការិយាល័យរដ្ឋបាលមិនគួរបដិសេធសំណើសុំធនធានដែលមិនប៉ះពាល់ដល់ផ្នែកហិរញ្ញវត្ថុរបស់តុលាការឡើយ លុះត្រាតែសំណើទាំងនោះផ្ទុយពីវិធានជាក់ស្តែង និងសំខាន់៖

> សំណើរបស់មេធាវីការពារក្តី ដែលមិនធ្វើឱ្យ អ.វ.ត.ក ខាតបង់អ្វី មិនគួរត្រូវបានបដិសេធ លើកលែងតែវាមានការលោភវិធានជាក់លាក់ណាមួយ ដែលសំខាន់ស្មើនឹងសិទ្ធិជាមូលដ្ឋានដែលត្រូវបានគាំទ្រ និង ការពារដោយបញ្ញត្តិពាក់ព័ន្ធនឹងធនធានដែលបានដោយឥតចំណាយប្រាក់[94]។

87. នៅក្នុងករណីនេះ ការិយាល័យរដ្ឋបាលបានសម្រេចចិត្តដែលបង្កឱ្យមានព្យសនកម្មច្បាស់លាស់ដល់ភាពជាតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងដែលគ្មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុអ្វីទេ។ ពុំមានផ្តល់ការពន្យល់ថា ហេតុអ្វីបានជាដំណោះស្រាយដែលចំណាយតាមការកំណត់ដែលបានស្នើឡើងដោយសហមេធាវីនាំមុខ មិនអាចទទួលបានការអនុម័តនោះឡើយ។

88. សហមេធាវីនាំមុខសូមលើកឡើងថា បញ្ហានានាដែលបានលើកឡើងនៅផ្នែក VII ក ដល់ ឆ បង្ហាញថា ក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួន ការិយាល័យរដ្ឋបាលបានពិចារណាទៅលើចំណុចនានាដែលមិនពាក់ព័ន្ធ មិនបានយកចិត្តទុកដាក់លើចំណុចពាក់ព័ន្ធ និង ធ្វើការសម្រេចដែលអ្នកសម្រេច

---

[92] ឧបសម្ព័ន្ធ ច៖ អនុស្សរណៈទី៣ របស់សហមេធាវីនាំមុខអន្តរជាតិ ទំព័រ ៣។

[93] ឧបសម្ព័ន្ធ ច៖ អនុស្សរណៈទី៣ របស់សហមេធាវីនាំមុខអន្តរជាតិ ទំព័រ ៤។

[94] **សំណុំរឿង ០០៤ – ឯកសារ D312/1** ដីកាសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ ទាក់ទិននឹងធនធានរបស់ក្រុមមេធាវីការពារក្តី ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ កថាខណ្ឌ ៧។

សេចក្ដីមានសុភវិនិច្ឆ័យមិនគួរធ្វើ។ ផ្អែកលើមូលដ្ឋានទាំងនេះ សេចក្ដីសម្រេចនេះគួរត្រូវបានបដិសេធចោល។

## ៨. ក្ដីរំពឹងស្របច្បាប់៖ ការផ្លាស់ប្ដូរដែលគ្មានការពន្យល់ លើវិធីសាស្ត្រ និងការបដិសេធការសន្យារបស់ការិយាល័យរដ្ឋបាល

89. មុនពេលមានអនុស្សរណៈលើកទីមួយ របស់ការិយាល័យរដ្ឋបាល សហមេធាវីនាំមុខយល់ថា សំណើសុំធនធានរបស់សហមេធាវីអន្តរជាតិនាំមុខ នឹងត្រូវបានអនុញ្ញាតផ្ដល់ជូន ទោះបីជាអាចមានការកាត់បន្ថយលើកម្រិតខ្ពស់បំផុត នៃម៉ោងបំពេញការងាររបស់ សហមេធាវីអន្តរជាតិនាំមុខក្ដី។ ការរំពឹងទុកនេះគឺផ្អែកលើកត្តាចំនួនពីរ៖

១. វិធីសាស្ត្រដែលអនុវត្តកន្លងមក ទៅលើសំណើសុំធនធានកន្លងមកទាំងអស់ ភាគច្រើនគឺមានលក្ខណៈប្រហាក់ប្រហែលគ្នា និង

២. ការសន្យាជាក់លាក់ដែលមន្ត្រី ការិយាល័យរដ្ឋបាល បានធ្វើកន្លងមក ហើយដែលសហមេធាវីនាំមុខពឹងផ្អែកលើការសន្យានោះ។

90. ខាង UNAKRT តម្រូវឱ្យសហមេធាវីអន្តរជាតិនាំមុខ ដាក់សំណើសុំធនធានជារៀងរាល់ត្រីមាស។ ភារកិច្ចជាច្រើនបានលើកឡើងនៅក្នុង សំណើសុំធនធាន របស់សហមេធាវីអន្តរជាតិនាំមុខ ព្រោះបោះមិនមានធនធានគ្រប់គ្រាន់ ភារកិច្ចទាំងអស់នេះ នឹងត្រូវការពេលវេលាយ៉ាងច្រើនដើម្បីសម្រេច។ ជាឧទាហរណ៍ ការរាយការណ៍អំពីការអនុវត្តសំណង គឺជាផ្នែកនៃផែនការសកម្មភាព និងសំណើសុំធនធាន របស់សហមេធាវីអន្តរជាតិនាំមុខ តាំងពីឆ្នាំ២០១៩ រួមទាំងផែនការធ្វើបច្ចុប្បន្នភាព ព័ត៌មានគេហទំព័រសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី។ ការងារនេះមិនអាចបំពេញចប់សព្វគ្រប់ឡើយ ព្រោះមិនមានធនធានគ្រប់គ្រាន់។ ការចាត់ចំណាត់ថ្នាក់ឡើងវិញ និងការងារជាគេវ្ដីដំណែលក៏បានដាក់បញ្ចូលនៅក្នុងផែនការសកម្មភាពជាច្រើន របស់សហមេធាវីអន្តរជាតិនាំមុខ តាំងពីខែមករា ឆ្នាំ២០២១ និងខែសីហា ឆ្នាំ២០២០។ ទោះជាបែបនេះក្ដី នាពេលកន្លងមកមិនមានការលើកឡើងថា ភារកិច្ចទាំងអស់នោះ ស្ថិតក្រៅអាណត្តិការងារ របស់សហមេធាវីនាំមុខឡើយ។ ហើយក៏មិនដែលមានការបដិសេធ មិនទូទាត់កម្រៃដល់សហមេធាវីនាំមុខ សម្រាប់ការចំណាយពេលវេលាលើភារកិច្ចទាំងនោះដែរ។

91. បន្ថែមលើនេះ ហេតុផលជាច្រើនដែលការិយាល័យរដ្ឋបាលផ្តល់ សម្រាប់ការសម្រេចរបស់ខ្លួន គឺមិនដែលធ្លាប់បានលើកឡើងកន្លងមកទេ។ កន្លងមកមិនដែលមានការលើកឡើងថា សហមេធាវីនាំមុខគួរធ្វើប្រតិភូកម្មការងារ ទៅឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ហើយក៏មិនដែលមានការលើកឡើងថា មិនមានភាពចាំបាច់ដែល UNAKRT ត្រូវផ្តល់ធនធានប្រឹក្សាឡើយ ព្រោះសហមេធាវីនាំមុខ អាចពឹងផ្អែកទៅលើតែធនធានពីខាងភាគីជាតិក៏បាន។

92. សហមេធាវីនាំមុខទទួលស្គាល់ថា មានដែនកំណត់លើកម្រិតនៃការអនុវត្តកន្លងមក ដែលអាចយកមកប្រើប្រាស់ដើម្បីប៉ាន់ប្រមាណ លើសកម្មភាពនាពេលអនាគត។ ក៏ប៉ុន្តែបើកាលៈទេសៈផ្លាស់ប្តូរជាក់ស្តែង ការនេះតម្រូវឱ្យមានការផ្លាស់ប្តូរលើវិធីសាស្ត្រ។ ប៉ុន្តែមិនឃើញមានការផ្លាស់ប្តូរជាក់ស្តែង លើកាលៈទេសៈណាមួយបានកើតឡើងឡើយ។

93. បន្ថែមលើនេះ ការមិនមានក្របខណ្ឌជាធរមានណាមួយ បានធ្វើឱ្យសហមេធាវីនាំមុខ ដោយមិនអាចជៀសវាងបាន ត្រូវពឹងផ្អែកទៅលើការអនុវត្ត ដែលបានកត់សម្គាល់ថាជាសុចនាករ នៃអ្វីដែលខ្លួនអាចរំពឹងទុកពីការិយាល័យរដ្ឋបាល។ ផ្ទុយពីមេធាវីការពារក្តី ដែលមានកិច្ចសន្យាសេវាផ្លូវច្បាប់ ក្របខណ្ឌជំនួយការផ្លូវច្បាប់ និងបទបញ្ញត្តិរបស់អង្គភាពគាំពារការការពារក្តី សហមេធាវីនាំមុខមិនមានកិច្ចសន្យា ឬឯកសាររដ្ឋបាលដែលគ្រប់គ្រងទៅលើធនធានដែលត្រូវផ្តល់ជូនក្រុមខ្លួនឡើយ[95]។ បន្ថែមលើនេះមានការចេញសេចក្តីសម្រេចជាទៀងទាត់ដោយផ្ទាល់មាត់ ឬតាមសារអេឡិចត្រូនិកខ្លីៗ ដោយមិនមានសំអាងហេតុ។ បើទោះបីជាមានសំណើសុំជាក់លាក់ និងច្រើនដងក្តី ពីសំណាក់សហមេធាវីអន្តរជាតិនាំមុខ សម្រាប់សំអាងហេតុជាលាយលក្ខណ៍អក្សរ ដែលខ្លួនគិតថានឹងអាចផ្តល់ជាគោលការណ៍ណែនាំ ពាក់ព័ន្ធសេចក្តីសម្រេចនាអនាគតក្តី ក៏នៅតែមានការនេះកើតឡើង[96]។ ជារឿងអកុសលដែរ ដែលការនេះបណ្តាលឱ្យមានស្ថានភាពមួយ ដែលសហមេធាវីនាំមុខ

---

[95] សហមេធាវីអន្តរជាតិនាំមុខត្រូវបានផ្តល់ជូននូវកិច្ចសន្យាពិគ្រោះយោបល់ស្តង់ដាររបស់អង្គការសហប្រជាជាតិ ដែលជាធម្មតាមានរយៈពេលចន្លោះពីមួយខែទៅបីខែ។

[96] សំណើសុំផ្តល់ហេតុផលចំពោះសេចក្តីសម្រេចអវិជ្ជមានណាមួយ ត្រូវបានបញ្ចូលយ៉ាងជាក់ច្បាស់នៅក្នុងអនុស្សរណៈស្នើសុំធនធាន ដែលត្រូវបានបញ្ជូនទៅការិយាល័យរដ្ឋបាល នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១, ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១ និងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១។ នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ សហមេធាវីអន្តរជាតិនាំមុខ បានសរសេរទៅការិយាល័យរដ្ឋបាលថា៖ "ខ្ញុំចង់ស្នើជាថ្មីម្តងទៀតថា ប្រសិនបើសំណើសុំធនធានរបស់ខ្ញុំត្រូវបានបដិសេធ ទាំងស្រុងក្តី ឬមួយផ្នែកក្តី ខ្ញុំគួរទទួលបានហេតុផលជាលាយលក្ខណ៍អក្សរចំពោះការសម្រេចចិត្តនោះ។ នេះមិនមែនគ្រាន់តែជាការគួរសមចំពោះខ្ញុំទេ ដោយសារតែខ្ញុំក៏ត្រូវផ្តល់ហេតុផលចំពោះសំណើរបស់ខ្ញុំដែរ។ ប្រសិនបើខ្ញុំបានដឹងពីហេតុផលរបស់ការិយាល័យរដ្ឋបាល វានឹងមានប្រយោជន៍សម្រាប់

ចាំបាច់ត្រូវពឹងផ្អែកទៅលើការអនុវត្ត (និងការសន្យា) ព្រមទាំងការរំពឹងទុកដែលថា ការិយាល័យរដ្ឋបាល នឹងដំណើរការស្របគ្នាជាបន្តបន្ទាប់។

94. ក្នុងស្ថានភាពនេះ សហមេធាវីនាំមុខពឹងផ្អែកទាំងទៅលើការអនុវត្ត និងការសន្យាជាក់លាក់ចំនួនពីរ ដែលការិយាល័យរដ្ឋបាលបានធ្វើ ពាក់ព័ន្ធធនធាននាពេលអនាគត សម្រាប់ភាគីអន្តរជាតិ។

95. ទីមួយ បន្ទាប់ពីមានសំណើសុំជាបន្តបន្ទាប់ ពីសហមេធាវីអន្តរជាតិនាំមុខ លើធនធានទីប្រឹក្សាដែលត្រូវផ្តល់ជូន នៅកម្រិតជាន់ខ្ពស់ ដែលត្រូវមានការទូទាត់ខ្ពស់ កាលពីពាក់កណ្តាលខែមករា ឆ្នាំ ២០២១ នោះ ការិយាល័យរដ្ឋបាលបានផ្តល់ដល់ សហមេធាវីអន្តរជាតិនាំមុខ នូវជម្រើស៖ ការិយាល័យរដ្ឋបាលយល់ព្រមលើការផ្តល់ តំណែងទីប្រឹក្សាអន្តរជាតិ និងកម្រិតជាន់ខ្ពស់ ហើយទទួលបានអត្រាទូទាត់ខ្ពស់ ប៉ុន្តែតំណែងនេះនឹងត្រូវផ្តល់ជូនតែត្រឹមសវនាការបណ្តឹងសាទុក្ខ ហើយបន្ទាប់ពីនោះមកនឹងត្រូវបញ្ចប់។ ជាជម្រើសមួយផ្សេងទៀត សហមេធាវីអន្តរជាតិនាំមុខ អាចជ្រើសរើសយកការរក្សាទុក តួនាទីទីប្រឹក្សាចម្បងអន្តរជាតិ នៅកម្រិតតំណែង និងអត្រាការទូទាត់បច្ចុប្បន្ន ដែលក្នុងករណីនេះ *តួនាទីទីប្រឹក្សានឹងត្រូវបន្តរហូត ទោះក្រោយសវនាការបណ្តឹងសាទុក្ខ*។ មានការពិភាក្សាថា សម្រាប់ជម្រើសទីពីរនេះ តួនាទីទីប្រឹក្សាអាចត្រូវកាត់បន្ថយ មកត្រឹមបំពេញការងារក្រៅម៉ោង បន្ទាប់ពីបញ្ចប់សវនាការបណ្តឹងសាទុក្ខ ប៉ុន្តែការនេះនឹងត្រូវសម្រេច ដោយយោងទៅរកលក្ខខណ្ឌតម្រូវការងារនៅពេលនោះ[97]។

---

សំណើនាពេលអនាគត។ ហើយខណៈពេលដែលខ្ញុំក៏ត្រូវការហេតុផលជាលាយលក្ខណ៍អក្សរដើម្បីស្នើសុំការពិនិត្យរបស់អង្គជំនុំជម្រះទៅលើការសម្រេចចិត្តរបស់លោក ខ្ញុំជឿជាក់ថា ខ្ញុំទំនងជាមិនត្រូវការនូវការពិនិត្យបែបនេះទេ ប្រសិនបើខ្ញុំដឹងពីហេតុផលសមស្របចំពោះសំណើដែលត្រូវបានបដិសេធ"។ សូមមើល ឧបសម្ព័ន្ធ ខ៖ សារអេឡិចត្រូនិករបស់សហមេធាវីអន្តរជាតិ នាំមុខ ផ្ញើទៅការិយាល័យរដ្ឋបាល, ធនធានសម្រាប់សវនាការបណ្តឹងសាទុក្ខ ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១។ ពុំបានទទួលចម្លើយអ្វីទេ។

[97] ការសម្រេចចិត្តនេះត្រូវបានបញ្ជូនដោយផ្ទាល់មាត់ក្នុងករណីដំបូង ដែលជាការអនុវត្តជាទូទៅរបស់ការិយាល័យរដ្ឋបាល។ ទោះជាយ៉ាងនេះក្តី ការអះអាងអាចមាននៅក្នុងចម្លើយតបរបស់ការិយាល័យរដ្ឋបាលទៅនឹងសេចក្តីសង្ខេបនៃកិច្ចពិភាក្សា ដែលត្រូវបានបញ្ជូនដោយសហមេធាវីអន្តរជាតិនាំមុខ ។ សូមមើល ឧបសម្ព័ន្ធ ឍ៖ សារអេឡិចត្រូនិករបស់ការិយាល័យរដ្ឋបាលផ្ញើទៅសហមេធាវីអន្តរជាតិនាំមុខ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១។ បញ្ហានេះត្រូវបានដោះស្រាយយ៉ាងជាក់ច្បាស់នៅក្នុងសំណើសុំធនធានបន្ទាប់របស់សហមេធាវីអន្តរជាតិនាំមុខ ៖ ឧបសម្ព័ន្ធ ណ៖ អនុស្សរណៈរបស់សហមេធាវីអន្តរជាតិនាំមុខ ផ្ញើទៅការិយាល័យរដ្ឋបាល, កម្មវត្ថុ៖ ធនធានសម្រាប់ផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី - ខែមេសា ដល់ខែមិថុនា ឆ្នាំ២០២១ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ ទំព័រ ៥។

96. បន្ទាប់ពីមានការផ្តល់ជូននេះ សហមេធាវីអន្តរជាតិនាំមុខ បានស្នើសុំឱ្យមានការប្រជុំជាមួយ អ្នកសម្របសម្រួលរបស់ UNAKRT។ ការប្រជុំនេះធ្វើឡើងតាមរយៈ Zoom នៅថ្ងៃទី២៥ ខែមករា។ នៅក្នុងការប្រជុំនោះ អ្នកសម្របសម្រួលបានបញ្ជាក់ឡើងវិញពីការផ្តល់ជូន។ គាត់ក៏បានសន្យាផងដែរថា ប្រសិនបើសហមេធាវីអន្តរជាតិនាំមុខ សម្រេចបន្តរក្សាទីប្រឹក្សា បើទោះបីជានៅក្នុងកម្រិតទាបក្តី នៅក្រោយពេលបញ្ចប់សវនាការ នៅពេលដែលមានតម្រូវការកាត់បន្ថយធនធាន គឺអាស្រ័យទៅលើសហមេធាវីអន្តរជាតិនាំមុខ ក្នុងការសម្រេចថាតើត្រូវបែងចែកប៉ុន្មានម៉ោង សម្រាប់សហមេធាវីអន្តរជាតិនាំមុខ និងប៉ុន្មានម៉ោងសម្រាប់ទីប្រឹក្សាចម្បង ទៅតាមថវិកាដែលបានកំណត់ដោយការិយាល័យរដ្ឋបាល។ បញ្ហានេះត្រូវបានពិភាក្សាលម្អិតខ្លះៗ ពីព្រោះសហមេធាវីអន្តរជាតិនាំមុខ បានបញ្ជាក់ឡើងវិញពីសារសំខាន់សម្រាប់ក្រុមរបស់គាត់ ក្នុងការរក្សាទុកទីប្រឹក្សាអន្តរជាតិ។ មានការសន្យាយ៉ាងច្បាស់លាស់ថា ប្រសិនបើចាំបាច់ត្រូវកាត់បន្ថយថវិកា សហមេធាវីអន្តរជាតិនាំមុខ អាចរក្សាទីប្រឹក្សា ដោយកាត់បន្ថយម៉ោងការងាររបស់ សហមេធាវីអន្តរជាតិនាំមុខ វិញ។ ទោះបីជាការសន្យានេះធ្វើឡើងដោយផ្ទាល់មាត់ក្តី (ដែលជាការអនុវត្តរបស់ការិយាល័យរដ្ឋបាល) សហមេធាវីនាំមុខបានយោងទៅរកការសន្យានេះ នៅក្នុងសំណើសុំធនធាននាពេលបន្ទាប់របស់ខ្លួនដើម្បីធានាថាមានកំណត់ត្រា[98]។ ការិយាល័យរដ្ឋបាលមិនបានផ្តល់ ការឆ្លើយតបណាមួយដើម្បីជំទាស់គោលជំហរដែលបានលើកឡើងនៅក្នុង អនុស្សរណៈរបស់សហមេធាវីអន្តរជាតិនាំមុខឡើយ។ សហមេធាវីនាំមុខកត់សម្គាល់ថា អនុស្សរណៈទីពីររបស់ការិយាល័យរដ្ឋបាល ហាក់ដូចជាទទួលស្គាល់ថាមានការសន្យា បើទោះបីជាអនុស្សរណៈនោះ បានផ្តល់នូវអត្ថន័យផ្ទុយចំពោះការសន្យានោះក្តី (“លោកស្រីត្រូវបានជូនដំណឹងថា ធនធានដែលត្រូវបានអនុម័ត សម្រាប់ផ្នែករបស់លោកស្រី អាចបែងចែកតាមលក្ខណៈដែលងាយស្រួលសម្រាប់ប្រតិបត្តិការ។ ប៉ុន្តែលោកស្រីត្រូវ

[98] ឧបសម្ព័ន្ធ ត៖ អនុស្សរណៈរបស់សហមេធាវីអន្តរជាតិនាំមុខផ្ញើទៅការិយាល័យរដ្ឋបាល កម្មវត្ថុ៖ ធនធានសម្រាប់ផ្នែកសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី - ខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២១, ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ ទំព័រ ៥៖ “ខ្ញុំព្យាករថា នៅពេលណាមួយបន្ទាប់ពីសវនាការលើបណ្តឹងសាទុក្ខ ការិយាល័យរដ្ឋបាលនឹងមានបំណងកាត់បន្ថយធនធានរបស់ផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីខ្លះៗ មកជាការបំពេញការងារក្រៅម៉ោង ដើម្បីឆ្លុះបញ្ចាំងពីការកាត់បន្ថយការងារដោះស្រាយវិវាទ រហូតដល់ការចេញសាលដីការបស់ អ.ជ.ត.ក។ ពីមុន ខ្ញុំត្រូវបានធានាថា នៅពេលបញ្ហានេះកើតឡើង ខ្ញុំនឹងមានភាពបត់បែនក្នុងការកំណត់ពីរបៀបដែលធនធានដែលមាននឹងត្រូវបែងចែក រវាងរូបខ្ញុំផ្ទាល់ និងទីប្រឹក្សាច្បាប់អន្តរជាតិរបស់ខ្ញុំ។ ដូចដែលបានបញ្ជាក់រួចមកហើយ ខ្ញុំគ្រោងស្នើសុំឱ្យទីប្រឹក្សាច្បាប់អន្តរជាតិធ្វើការងារពេញម៉ោង ខណៈពេលដែលម៉ោងការងាររបស់ខ្ញុំអាចត្រូវបានកាត់បន្ថយ នៅពេលដែលសមស្រប អាស្រ័យទៅតាមបន្ទុកការងាររបស់យើង”។

បានជូនដំណឹងផងដែរថា ធនធានដែលបានស្នើឡើង ចាំបាច់ត្រូវមានយុត្តិកម្មពេញលេញ[99]")។ មានភាពមិនច្បាស់លាស់ថាតើ ធនធានដែលត្រូវបានអនុម័ត សម្រាប់សហមេធាវីអន្តរជាតិនាំមុខ អាច "បែងចែកតាមលក្ខណៈដែលងាយស្រួល សម្រាប់ប្រតិបត្តិការ" ដោយរបៀបណា ដោយសារតែការិយាល័យរដ្ឋបាល បានសម្រេចច្បាស់លាស់ថា ធនធាននោះនឹងត្រូវផ្តល់ជូន តែចំពោះការងាររបស់ សហមេធាវីនាំមុខ ចំណែកទីប្រឹក្សាមិនមានការអនុម័តយល់ព្រមឡើយ។ ការិយាល័យរដ្ឋបាល បានបដិសេធយ៉ាងដាក់លាក់ ចំពោះសំណើរបស់សហមេធាវីអន្តរជាតិនាំមុខ សុំជម្រើសផ្សេង ដើម្បីចែករំលែកថវិកានេះជាមួយទីប្រឹក្សា ដើម្បីរក្សាធនធានសម្រាប់ការប្រឹក្សាដែលចាំបាច់។ គួរកត់សម្គាល់ផងដែរថា បើទោះបីជាបានបដិសេធធនធាន សម្រាប់ការប្រឹក្សាក្តី ប៉ុន្តែការិយាល័យរដ្ឋបាល បានផ្តល់ម៉ោងការងារ*ច្រើនជាង*អ្វី ដែលសហមេធាវីអន្តរជាតិនាំមុខ បានស្នើសុំសម្រាប់ខ្លួនគាត់ នៅត្រីមាសនេះទៅទៀត។ នៅតែមានភាពមិនច្បាស់លាស់ និងមិនមានការពន្យល់ថា ហេតុអ្វីទើបថវិកាសម្រាប់ម៉ោងបន្ថែមទាំងអស់នោះ មិនអាចប្រើប្រាស់បាន សម្រាប់ទីប្រឹក្សា។

97. សហមេធាវីនាំមុខពឹងផ្អែកលើការសន្យាអស់ទាំងនេះ។ សហមេធាវីអន្តរជាតិនាំមុខ បដិសេធការផ្តល់ជូន នូវទីប្រឹក្សាជាន់ខ្ពស់ ច្បាស់លាស់ព្រោះគាត់អាច ពឹងផ្អែកទៅលើធនធានប្រឹក្សា ដែលត្រូវបន្តរទោះជាបញ្ចប់សវនាការបណ្តឹងសាទុក្ខ។ នៅក្នុងអនុស្សរណៈថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ សហមេធាវីអន្តរជាតិនាំមុខ ពន្យល់ថា៖

> នៅក្នុងអនុស្សរណៈប្រចាំត្រីមាសចំនួនបីចុងក្រោយរបស់ខ្ញុំ គឺខែមិថុនា កញ្ញា និងខែធ្នូ ឆ្នាំ២០២០ ខ្ញុំស្នើសុំឱ្យជំនួស ទីប្រឹក្សាដែលមានតំណែងស្មើកម្រិត P3 របស់ផ្នែក ជាមួយទីប្រឹក្សាដែលមានកម្រិតស្មើ P4 វិញ។ ពីដំបូងខ្ញុំទទួលបានព័ត៌មាន សំណើទាំងអស់នេះមិនអាចអនុម័តបានទេ ដោយសារតែការបង្កកការជ្រើសរើសបុគ្គលិក នៅក្នុងអង្គការសហប្រជាជាតិ។ បន្ទាប់ពីអនុស្សរណៈចុងក្រោយរបស់ខ្ញុំ ខ្ញុំទទួលបានព័ត៌មានថា ប្រសិនបើខ្ញុំនៅតែទទូចស្នើនូវសំណើនេះ អាចមានការពិចារណានៅពេលនេះ យ៉ាងហោចណាស់ត្រឹមពេលវេលាកំណត់មួយ រហូតដល់សវនាការបណ្តឹងសាទុក្ខ។
>
> ប៉ុន្តែខ្ញុំទទួលបានព័ត៌មានថា សំណើអាចត្រូវបានពិចារណា ត្រឹមតែលើមូលដ្ឋានដែលថាការនេះនឹងបណ្តាលឱ្យមានការបញ្ចប់ទាំងស្រុង ទៅលើធនធានទីប្រឹក្សារបស់ខ្លួន នៅក្រោយបញ្ចប់សវនាការបណ្តឹងសាទុក្ខ ដោយមិនគិតថាមានការងារអ្វីដែលចាំបាច់

[99] ឧបសម្ព័ន្ធ ធ៖ អនុស្សរណៈទី២ កថាខណ្ឌ ១៧។

សម្រាប់ផ្នែកឡើយ នៅក្រោយពេលបញ្ចប់សវនាការនោះ។ ផ្ទុយទៅវិញ ខ្ញុំទទួលបានការធានាថា ប្រសិនបើខ្ញុំដកសំណើសុំបុគ្គលិកកម្រិត P4 ខ្ញុំនឹងត្រូវបានអនុញ្ញាត ឱ្យរក្សាធនធានប្រឹក្សារហូតដល់ក្រោយពេលសវនាការបណ្ដឹងសាទុក្ខ ហើយថាខ្ញុំនឹងទទួលបានភាពបត់បែន (ដោយសមហេតុផល) ក្នុងការសម្រេចថា ការបែងចែក "ម៉ោង" ឬទំហំការងារបែបណា សម្រាប់ទីប្រឹក្សា និងសម្រាប់ខ្ញុំនៅពេលនោះ។ *ដោយសារតែខ្ញុំពិចារណាថា មិនមានលទ្ធភាពដែលថាផ្នែកនឹងអាចបំពេញអាណត្តិការងារខ្លួន នៅក្រោយពេលសវនាការបាន ប្រសិនបើមិនមានធនធានទីប្រឹក្សាទេនោះ ការនេះធ្វើឱ្យខ្ញុំគ្មានជម្រើសអ្វី ក្រៅពីដកសំណុំសុំឡើយ*[100]។ (ដោយគូសបញ្ជាក់បន្ថែម)

98. ហេតុដូច្នេះការិយាល័យរដ្ឋបាល បានដឹងថា សហមេធាវីអន្តរជាតិនាំមុខ បំពេញកិច្ចដោយផ្អែកទៅលើការសន្យានេះយ៉ាងច្បាស់លាស់ ដើម្បីធានាថា ធនធានប្រឹក្សាដែលចាំបាច់ សម្រាប់ការងាររបស់សហមេធាវីនាំមុខ នឹងអាចបន្តនៅក្រោយសវនាការបណ្ដឹងសាទុក្ខ។ ផ្នែកផ្សេងទៀតនៃអនុស្សរណៈ បានបង្ហាញពីភារកិច្ចដែលចាំបាច់ត្រូវបំពេញ បន្ទាប់ពីសវនាការ ព្រមទាំងអង្គហេតុដែលថាភារកិច្ចទាំងនោះត្រូវប្រមូលផ្ដុំគ្នា ដោយសារតែកង្វះខាតធនធាន និងភាពចាំបាច់ក្នុងការផ្ដោតទៅលើ កិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ[101]។

99. ជាទូទៅ សហមេធាវីនាំមុខមានគម្រោង និងកំណត់អាទិភាពការងាររបស់ខ្លួនយន ដោយផ្អែកលើការសន្យាទាំងពីរនេះ ដែលបញ្ជាក់យ៉ាងច្បាស់ថា ធនធានទីប្រឹក្សាអន្តរជាតិនឹងត្រូវបន្ត។ សហមេធាវីនាំមុខមិនបានកំណត់អាទិភាពចំពោះភារកិច្ច ដែលទីប្រឹក្សាអន្តរជាតិ ត្រូវបំពេញជាពិសេសឡើយ។ សហមេធាវីនាំមុខក៏មិនបានកំណត់ភារកិច្ចទីប្រឹក្សា ដើម្បីត្រួតពិនិត្យលើសារអេឡិចត្រូនិក និងក្រដាសស្នាមរបស់ខ្លួន ក្នុងពេលបំពេញការងារជិត៧ឆ្នាំ ដើម្បីរក្សាទុកនូវព័ត៌មានគន្លឹះ ឬត្រៀមរៀបចំកំណត់ត្រាលម្អិត លើបញ្ហាដែលជាការដឹងឮផ្ទាល់របស់គាត់ដែរ។ ភារកិច្ចទាំងអស់នេះ គឺមិនអាចបញ្ចប់បានឡើយ នៅក្នុងខែតុលា។

---

[100] ឧបសម្ព័ន្ធ ណ៖ ឧបសម្ព័ន្ធរបស់សហមេធាវីអន្តរជាតិនាំមុខផ្ញើទៅការិយាល័យរដ្ឋបាល កម្មវត្ថុ៖ ធនធានសម្រាប់ផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី - ខែមេសា ដល់ខែមិថុនា ឆ្នាំ២០២១ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ ទំព័រ ៥។

[101] ដូចខាងលើ ទំព័រ ៦៖ "នៅខែមិថុនា ឆ្នាំ២០២១ ផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនឹងមានទំហំការងារគួរសម ដែលត្រូវបានផ្អាកក្នុងអំឡុងពេលរៀបចំសវនាការ។ នេះរួមបញ្ចូលជាពិសេស (i) ការបញ្ចប់ការដាក់ឯកសារនៅសេសសល់ ដែលទំនងជាតម្រូវឱ្យមានការងារច្រើន (ii) ការសម្របសម្រួលការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី (iii) ការបញ្ចូលព័ត៌មានស្ដីពីកេរដំណែល និងការធ្វើបច្ចុប្បន្នភាពគេហទំព័រ"។

100. ទោះបីជាមានការចង្អុលបង្ហាញជាលាយលក្ខណ៍អក្សរចំនួនពីរ ដោយសហមេធាវីអន្តរជាតិនាំមុខ នៅក្នុងខែមីនា និងខែមិថុនា ឆ្នាំ២០២១ ក្តី ថាសហមេធាវីអន្តរជាតិនាំមុខរំពឹងថា នឹងមានការគោរព ទៅតាមសន្យាក្តី[102] សញ្ញាដំបូង អំពីចេតនារបស់ការិយាល័យរដ្ឋបាល លើការបដិសេធនេះ ត្រូវបាន ទទួលនៅក្នុងអនុស្សរណៈការិយាល័យរដ្ឋបាលលើកទីមួយ នៅថ្ងៃទី២៣ ខែកញ្ញា ហើយបន្ទាប់មក គឺសេចក្តីសម្រេចតាមសារអេឡិចត្រូនិក នៅថ្ងៃទី១ ខែតុលា។ ការព្យាយាមសុំការបញ្ជាក់បំភ្លឺលើ សារអេឡិចត្រូនិក ដើម្បីសម្រេចថាតើពិតជាមានចេតនា ក្នុងការបញ្ចប់ទីប្រឹក្សាដែរឬអត់នោះ គឺ មិនត្រូវបានទទួលនូវការឆ្លើយតបឡើយ[103]។ លទ្ធផលគឺថា សហមេធាវីនាំមុខ និងទីប្រឹក្សាខ្លួនឯង ផ្ទាល់ មានពេលវេលាដ៏ខ្លីត្រឹមបីសប្តាហ៍ ក្នុងការព្យាយាមលើការប្រគល់ និងការត្រៀមរៀបចំការ ចាកចេញរបស់ទីប្រឹក្សា បន្ទាប់ពីបំពេញការងាររយៈពេលប្រាំពីរឆ្នាំនៅ អ.វ.ត.ក។

101. សហមេធាវីនាំមុខកត់សម្គាល់ថា នៅក្នុងច្បាប់រដ្ឋបាលអន្តរជាតិ អ្នកធ្វើការសម្រេចអាចចង កាតព្វកិច្ចខ្លួនគាត់ តាមរយៈការបង្កើតនូវ ក្តីរំពឹងទុកដែលស្របច្បាប់ សម្រាប់អ្នកដទៃ៖

> “ក្តីរំពឹងទុកដែលស្របច្បាប់ អាចបណ្តាលឱ្យកើតមាននូវ កាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ច កិច្ចសន្យា នៅពេលដែលភាគីមួយធ្វើសកម្មភាព ក្នុងលក្ខណៈមួយដែលជាតំណាងឱ្យអំពើ ឬពាក្យសម្តី ដែលមានចេតនា ឬប្រហែលជាអាចជម្រុញដោយសមហេតុផល ដល់ភាគី ដទៃទៀតឱ្យធ្វើសកម្មភាពក្នុងលក្ខណៈមួយ ដោយពឹងផ្អែកលើការតំណាង និងថាភាគីដទៃ ទៀតនឹងធ្វើដូច្នោះ"[104]

---

[102] ដូចខាងលើ ទំព័រ ៥-៦។ ឧបសម្ព័ន្ធ គ៖ អនុស្សរណៈរបស់សហមេធាវីអន្តរជាតិនាំមុខផ្ញើទៅការិយាល័យរដ្ឋបាល កម្មវត្ថុ៖ ធនធានសម្រាប់ផ្នែកសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី - ខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២១, ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០២១ ទំព័រ ៥។

[103] ឧបសម្ព័ន្ធ ង៖ ការឆ្លើយឆ្លងសារអេឡិចត្រូនិករវាងការិយាល័យរដ្ឋបាល និងសហមេធាវីអន្តរជាតិនាំមុខ ទំព័រ ១-៣ (សារអេ ឡិចត្រូវនិករបស់សហមេធាវីអន្តរជាតិនាំមុខផ្ញើទៅការិយាល័យរដ្ឋបាល នៅថ្ងៃទី០២ ខែតុលា, ថ្ងៃទី០៤ ខែតុលា, ថ្ងៃទី០៦ ខែ តុលា ឆ្នាំ២០២១)។

[104] UNDT សំណុំរឿងលេខ UNDT/NY/2009/051/JAB/2008/098 រឿងក្តី *Sina តទល់នឹងអគ្គលេខាធិការអង្គការសហប្រជា ជាតិ* សាលក្រម សាលក្រមលេខ UNDT/2010/060, ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១០ កថាខណ្ឌ ៣៥។

102. ការរំពឹងទុកដោយស្របច្បាប់ អាចកើតឡើងពី "ការប្រើប្រាស់ការអនុវត្តទូទៅ ឬតាមរយៈការសន្យាច្បាស់លាស់"[105]។

103. នៅចំពោះមុខ UNDT ការសន្យាជាទូទៅគួរធ្វើឡើងជាលាយលក្ខណ៍អក្សរ ដើម្បីបង្កើតនូវការរំពឹងទុកដោយស្របច្បាប់ ប៉ុន្តែការសន្យាដោយផ្ទាល់មាត់ បង្កើតបានជា "ការប្តេជ្ញាចិត្តម៉ឺងម៉ាត់" ក៏អាចគ្រប់គ្រាន់[106]។ នៅចំពោះមុខវេទិកាដទៃទៀត មានការកំណត់ច្បាស់លាស់ថា ការសន្យាផ្ទាល់មាត់គឺអាចគ្រប់គ្រាន់[107]។ ទោះជាក្នុងករណីណាក្តី នៅក្នុងបរិបទនេះការសន្យាទាំងពីរ ត្រូវបានផ្ទុះបញ្ជាំងជាបន្តបន្ទាប់ នៅក្នុងការទំនាក់ទំនងជាលាយលក្ខណ៍អក្សរ។

104. ទោះបីជាមានការកើតឡើងជាញឹកញាប់ នៅក្នុងរឿងក្តីរដ្ឋបាលអន្តរជាតិ ពាក់ព័ន្ធជម្លោះកិច្ចសន្យាបុគ្គលិកក្តី តែគោលការណ៍នៃការរំពឹងទុកដោយស្របច្បាប់ មិនកម្រិតកំណត់សម្រាប់បរិបទនោះទេ។ មានការកើតឡើងផងដែរនៅក្នុង ស្ថាប័នច្បាប់ជាតិនិងអន្តរជាតិនានា[108]។ តុលាការ ICTR ក៏បានអនុវត្តផងដែរចំពោះ ការរំពឹងទុកដោយស្របច្បាប់ របស់ជនជាប់ចោទ ពាក់ព័ន្ធការតែងតាំងមេធាវីការពារក្តី[109]។ ទស្សនៈនេះគឺពាក់ព័ន្ធជាមួយទ្រឹស្តីផ្អែកលើការជឿជាក់ ដូចជាកាមិនអាច

---

[105] UNDT សំណុំរឿងលេខ UNDT/NY/2011/073 រឿងក្តី *Candusso ទល់នឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ* សាលក្រម សាលក្រមលេខ UNDT/2013/090 ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ កថាខណ្ឌ ៣៩។

[106] UNDT សំណុំរឿងលេខ UNDT/NBI/2010/09/ UNAT/1582, រឿងក្តី *ទល់នឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ* សាលក្រម សាលក្រមលេខ UNDT/2010/197 កថាខណ្ឌ ៥១។ ("ថាតើបុគ្គលិកមានការរំពឹងទុកស្របច្បាប់ឬទេ គឺអាស្រ័យទៅលើថាតើ គេអាចបង្ហាញឱ្យឃើញថា អ្វីមួយត្រូវបាននិយាយ ឬធ្វើដោយរដ្ឋបាលដែលមានការប្តេជ្ញាចិត្តម៉ឺងម៉ាត់ក្នុងការបន្តកិច្ចសន្យា ដើម្បីឱ្យបុគ្គលិកអាចរំពឹងថានឹងមានការបន្តកិច្ចសន្យា ទោះបីកិច្ចសន្យារបស់គាត់ចែងដូច្នេះក៏ដោយ។ សេចក្តីប្រកាសផ្ទាល់មាត់របស់អ្នកគ្រប់គ្រងដែលបង្ហាញថា ការងារនឹងត្រូវបានពន្យារពេលលើសពីកាលបរិច្ឆេទផុតកំណត់ដែលបានបញ្ជាក់យ៉ាងច្បាស់ ឧទាហរណ៍ ជាទង្វើដែលនឹងផ្តល់ឱ្យបុគ្គលិកនូវការរំពឹងទុកស្របច្បាប់ថាកិច្ចសន្យារបស់គាត់នឹងបន្ត")។

[107] សូមមើល ឧទាហរណ៍៖ តុលាការរដ្ឋបាលរបស់អង្គការ ILO, *In re Geiser*, សាលក្រមលេខ ៧៨២ (ឆ្នាំ១៩៨៦) កថាខណ្ឌ ១៖ "ទោះបីជាការសន្យាមានទម្រង់អ្វីក៏ដោយ វាមិនសំខាន់ទេ៖ ការសន្យាអាចជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ជាក់ច្បាស់ ឬបង្កប់ន័យ។ អ្នកដែលធ្វើការសន្យាត្រូវបានចងកាតព្វកិច្ចក្នុងការរក្សាភាពស្មោះត្រង់ ទោះបីជាគាត់សន្យាដោយផ្ទាល់មាត់ក្តី ឬទោះបីជាការសន្យានោះគ្រាន់តែជាការសន្និដ្ឋានដែលកើតចេញពីកាលៈទេសៈ ឬអាកប្បកិរិយារបស់គាត់ក្តី"។

[108] សូមមើល L. Otis និង J. Boulanger-Bonnelly, "The Protection of Legitimate Expectations in Global Administrative Law" នៅក្នុង G. P. Politakis, T. Kohiyama and T. Lieby (eds), LO100 - Law for Social Justice (ហ្សឺណែវ៖ ការិយាល័យពលកម្មអន្តរជាតិ ឆ្នាំ២០១៩) លេខ ៣៩៥ [ឯកសារភ្ជាប់លេខ ២]។

[109] តុលាការ ICTR រឿងក្តី *Akayesu ទល់នឹងរដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-96-4-A សេចក្តីសម្រេចទាក់ទងនឹងការចាត់តាំងមេធាវី ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៩ ទំព័រ ៣។

បដិសេធសន្យា (promissory estoppel) ហើយក៏អាចកើតឡើងផងដែរ នៅពេលដែលការរំពឹងទុកកើតចេញពី អាជ្ញាធរសាធារណៈ ហើយមានលក្ខណៈទូលំទូលាយ ដោយសារតែវារួមបញ្ចូលទាំងការរំពឹងទុក ដែលផ្អែកលើការសន្យាច្បាស់លាស់ និងការរំពឹងទុកដែលកើតឡើង ដោយសារតែការអនុវត្តស្របគ្នា[110]។

105. សហមេធាវីនាំមុខសូមលើកឡើងថា ទស្សនៈនេះគឺអាចអនុវត្តបានចំពោះករណីបច្ចុប្បន្ន។ ការិយាល័យរដ្ឋបាលបានធ្វើការសន្យាម៉ឺងម៉ាត់ ជាក់លាក់ និងច្បាស់លាស់ ចំពោះសហមេធាវីអន្តរជាតិនាំមុខ។ សហមេធាវីនាំមុខពឹងផ្អែកលើការសន្យាទាំងអស់នេះ។ ការិយាល័យរដ្ឋបាលបានដឹងឮយ៉ាងច្បាស់ អំពីការពឹងផ្អែកទាំងនេះ។ ប្រសិនបើអនុញ្ញាតឱ្យការិយាល័យរដ្ឋបាលធ្វើការបដិសេធ នឹងមានការខូចខាតកើតឡើង។ សហមេធាវីនាំមុខនឹងបាត់បង់ឱកាស ក្នុងការប្រើប្រាស់ទីប្រឹក្សាសម្រាប់ការងារជាក់លាក់មួយចំនួន នៅក្នុងអំឡុងពេលដែល សហមេធាវីនាំមុខមានទីប្រឹក្សា ព្រោះសហមេធាវីនាំមុខយល់ថា តំណែងទីប្រឹក្សានឹងត្រូវបន្ត។

106. ស្ថានភាពនេះកាត់តែច្បាស់លាស់ ដោយសារការពិតដែលថា ការមិនគោរពសន្យាទាំងអស់នេះរបស់ការិយាល័យរដ្ឋបាល កើតឡើងស្របគ្នាជាមួយ ការងាកចេញជាក់ច្បាស់ពី សេចក្តីសម្រេចលើធនធានកន្លងមករបស់ខ្លួន ពាក់ព័ន្ធភារកិច្ចដែលត្រូវបានពិចារណាថា ស្ថិតនៅក្នុងអាណត្តិការងារ របស់សហមេធាវីនាំមុខ និងវិធីសាស្ត្រក្នុងការសម្រេចលើធនធាន។ សហមេធាវីនាំមុខមានសិទ្ធិរំពឹងទុកថា ភារកិច្ចដែលស្ថិតក្នុងអាណត្តិការងារខ្លួន នឹងត្រូវបន្តស្ថិតក្នុងអាណត្តិការងារនាពេលនេះ។ សហមេធាវីនាំមុខមានសិទ្ធិរំពឹងទុកថា ការយល់ដឹងរបស់ការិយាល័យរដ្ឋបាល ទៅលើទំនាក់ទំនងរវាងសហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងនៅតែបន្តដោយគ្មានការផ្លាស់ប្តូរ។

107. ហេតុដូច្នេះសេចក្តីសម្រេចរបស់ការិយាល័យរដ្ឋបាល គួរត្រូវបានច្រានចោល ដោយសារតែផ្ទុយទៅនឹងការរំពឹងទុកដោយស្របច្បាប់ របស់សហមេធាវីនាំមុខ ដែផ្អែកលើការសន្យាច្បាស់លាស់ និងពិតប្រាកដទាំងពីរ។ ការិយាល័យរដ្ឋបាលគួរត្រូវបានតម្រូវ ឱ្យអនុវត្តតាមសន្យារបស់ខ្លួន ដើម្បី

[110] ការពិភាក្សាអំពីទំនាក់ទំនងរវាងសញ្ញាណទាំងនេះ អាចរកបាននៅក្នុងសាលដីការបស់តុលាការកំពូលឥណ្ឌា នៅក្នុងរឿងក្តីរដ្ឋ Jharkhand and Ors. តទល់នឹង Brahmaputra Metallics Ltd. And Ors. សំណុំរឿងលេខ 2021 (1) SCJ 131 កថាខណ្ឌ ៣២-៣៥ [ឯកសារភ្ជាប់លេខ ៣]។

(ក) អនុញ្ញាតឱ្យបន្តធនធានប្រឹក្សា និង (២) អនុញ្ញាតឱ្យសហមេធាវីនាំមុខ សម្រេចលើការបែងចែកធនធានដែលមាន សម្រាប់សហមេធាវីអន្តរជាតិនាំមុខ និងទីប្រឹក្សា។

108. ដើម្បីកាត់បន្ថយជាអតិបរមា នូវការលំបាកបែបនេះនាពេលខាងមុខ អង្គជំនុំជម្រះគួរពិចារណាបង្គាប់ដល់ការិយាល័យរដ្ឋបាល ឱ្យបង្កើតកិច្ចសន្យាសេវាផ្លូវច្បាប់ និងគម្រោងជំនួយការផ្លូវច្បាប់សម្រាប់សហមេធាវីនាំមុខ ដែលមានលក្ខណៈប្រហាក់ប្រហែលជាមួយអ្វី ដែលកំពុងអនុវត្តជាមួយមេធាវីការពារក្តី។ ទោះបីជាតុលាការអាចនឹងជិតដល់ពេលបញ្ចប់ការងារខ្លួនក្តី តែនេះមិនមែនជាហេតុផលសម្រាប់ ការបន្តការអនុវត្តដែលជម្រុញឱ្យមាន ការសម្រេចដែលមិនស៊ីសង្វាក់គ្នា និងមិនមានគណនេយ្យភាពឡើយ។ ការមិនមានប្រព័ន្ធដែលមានតម្លាភាព និងអាចប្រមើលមើលបាន នៅតែអាចបណ្តាលឱ្យមានទំនាស់ និងបង្ករនូវការពន្យាពេល និងចំណាយបន្ថែម សូម្បីនៅក្នុងអំឡុងពេលដែលនៅសល់របស់តុលាការ និងអំឡុងពេលមុខងារសេសសល់របស់ខ្លួនក្តី។

## ៩. សំណើសុំ

109. សម្រាប់សំអាងហេតុទាំងអស់ដូចបានរៀបរាប់ខាងលើ សហមេធាវីនាំមុខស្នើសុំដល់អង្គជំនុំជម្រះបញ្ជាក់អំពីអាណត្តិរបស់សហមេធាវីនាំមុខ ហើយបង្គាប់ឱ្យការិយាល័យរដ្ឋបាលផ្តល់ធនធានចាំបាច់សម្រាប់បំពេញការងាររបស់ខ្លួន ។ ដើម្បីជៀសវាងការពន្យាពេលបន្ថែម សហមេធាវីនាំមុខស្នើដល់អង្គជំនុំជម្រះ បង្គាប់ដល់ការិយាល័យរដ្ឋបាល ឱ្យបន្តធនធានទីប្រឹក្សាអន្តរជាតិ របស់សហមេធាវីនាំមុខ និងគោរពតាមការព្រមព្រៀងរបស់ខ្លួន ដោយអនុញ្ញាតឱ្យសហមេធាវីអន្តរជាតិនាំមុខសម្រេចលើការបែងចែកម៉ោងបំពេញការងារ រវាងសហមេធាវីអន្តរជាតិនាំមុខ និងទីប្រឹក្សាអន្តរជាតិ។

ហេតុដូច្នេះសហមេធាវីនាំមុខ ស្នើសុំដោយគោរពចំពោះ អង្គជំនុំជម្រះតុលាការកំពូល៖

(១) **តម្កល់** សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះការតំណាងដោយប្រសិទ្ធភាពអនុលោមតាមវិធាន ១២ *ស្ទួនពីរ* និងវិធាន ២៣ (៣)

(២) **ច្រានចោល** សេចក្តីសម្រេចរបស់ការិយាល័យរដ្ឋបាលលើបញ្ហាធនធានរបស់ ក្រុមការងារសហមេធាវីនាំមុខ សម្រាប់រយៈពេលខាងមុខ និង

(៣) **បង្គាប់** ដល់ការិយាល័យរដ្ឋបាល ឱ្យធ្វើការពិចារណាដោយត្រឹមត្រូវ ទៅលើកត្តាពាក់ព័ន្ធ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន លើបញ្ហាធនធាន

(៤) **បង្គាប់** ដល់ការិយាល័យរដ្ឋបាលឱ្យផ្តល់ធនធានគ្រប់គ្រាន់ ដើម្បីបំពេញអាណត្តិការងាររបស់សហមេធាវីនាំមុខ

(៥) **បង្គាប់** ដល់ការិយាល័យរដ្ឋបាលឱ្យផ្តល់ការជូនដំណឹងគ្រប់គ្រាន់ អំពីសេចក្តីសម្រេចលើបញ្ហាធនធាន ជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យសហមេធាវីនាំមុខ អាចរៀបចំផែនការសកម្មភាពរបស់ខ្លួនផ្អែកតាមនោះ។